# ការលើកកំពស់ឯករាជ្យភាព
# នៃ
# ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា













របាយការណ៍ស្រាវជ្រាវនេះ បោះពុម្ពដោយ មជ្ឈមណ្ឌលកម្ពុជា
ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ក្រោមការឧបត្ថម្ភថវិកាពី
សហភាព អឺរ៉ុប

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

CCIM

cambodian center for independent media

# ការលើកកំពស់ឯករាជភាព
# នៃ
# ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា

ឧបត្ថម្ភថវិកាដោយៈ

សហភាពអឺរ៉ុប

ខែកក្កដា ឆ្នាំ២០០៩

# ការលើកកំពស់ឯករាជភាពនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា

បោះពុម្ពដោយៈ
មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

សូមមេត្តាទាក់ទងៈ
មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ
ផ្ទះលេខ១៤អា ផ្លូវលេខ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន
រាជធានីភ្នំពេញ។
អ៊ីម៉ែលៈ info@ccimcambodia.org

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះបុគ្គល និង អង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលបានចូលរួមនៅក្នុងដំណើរការស្រាវជ្រាវនេះនិងគំរោងមូលនិធិរបស់សហភាពអឺរ៉ុប។

បោះពុម្ពនៅរាជធានីភ្នំពេញ, ប្រទេសកម្ពុជា

# មាតិកា

**សេចក្តីផ្តើម៖ ក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន**…………១

**វិធីសាស្ត្រក្នុងការស្រាវជ្រាវ**……………………………២

**របកគំហើញ៖ ប្រព័ន្ធផ្សព្វផ្សាយបែបប្រជាធិបតេយ្យ**……៤

ការទទួលបានព័ត៌មាន……………………………………៥

ប្រាក់ខែទាប ភាពក្រីក្រ និង សំណូក ………………………៦

ទីផ្សារឧនាភិវឌ្ឍន៍(មិនទាន់មានការអភិវឌ្ឍពេញលេញតែកំពុង
ដំណើការ)………………………………………………៦

ការសំឡុត និង ការគំរាមកំហែង……………………………៨

វិជ្ជាជីវៈ ឬ ជាតិនិយម……………………………………៩

ការហាមមិនឲ្យមានការរិះគន់លើអ៊ីនធឺណែត…………………១០

**អនុសាសន៍**…………………………………………**១១**

ចំពោះអ្នកប្រកបមុខរបរប្រព័ន្ធផ្សព្វផ្សាយ…………………១១

រដ្ឋាភិបាល………………………………………………១២

សង្គមស៊ីវិល និង ម្ចាស់ជំនួយ……………………………១៣

**ឯកសារយោង**…………………………………………**១៣**

សៀវភៅ…………………………………………………១៤

របាយការណ៍……………………………………………១៥

**ប្រវត្តិ៖អាទិករនៃប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសកម្ពុជា..១៧**
រវាងឆ្នាំ១៩២០ដល់ឆ្នាំ១៩៥៣ អាណានិគមបានលើកតំកើងការផ្សព្វ-ផ្សាយ នូវសិល្បៈ និងអក្សរសាស្ត្រ……………………………..១៨
រវាងឆ្នាំ១៩៥៣ ដល់ឆ្នាំ ១៩៧០ វប្បធម៌របស់សម្តេចសីហនុ………..១៩
រវាងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ របបទាហ៊ាន លន់ នល់ ……………២០
រវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ របបខ្មែរក្រហម……………………..២១
រវាងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩២ ប្រទេសកម្ពុជាស្ថិតក្រោមឥទ្ធិពលរបស់ប្រទេសវៀតណាម………………………………………………..២២
រវាងឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៨ UNTAC បានបន្ធូបន្ថយនូវការច្បាមយកប្រព័ន្ធផ្សព្វផ្សាយ……………………………………………..២៣

**ច្បាប់សារព័ត៌មាន៖ សេរីភាពតែលើក្រដាសតែមានភាពផ្តាច់ការនៅពេលអនុវត្តន៍**……………………………….២៤

**ប្រវត្តអ្នកកាសែត**………………………………………………..២៥
លោក យុត សុខឿន មណ្ឌលព័ត៌មានស្ត្រីកម្ពុជា…………………..២៥
លោក ម៉ែន គឹមសេង សំឡេងសហរដ្ឋអាមេរិក…………………….២៧
លោកស្រី ជូឌីស ខ្លាក មកពីមហាវិទ្យាល័យហុងកុង………………២៩
លោក ខៀវ កូឡា ស្ថាបនិកសារព័ត៌មានដើមអំពិល…………………៣២
លោក ប៉ែន សមិទ្ធិ (ប៉ែន ផេង) និពន្ធនាយកកាសែតរស្មីកម្ពុជា………៣៤
លោក ប្រាជ្ញ ស៊ីម និពន្ធនាយកទស្សនាវដ្តីប្រជាប្រិយ………………..៣៥
លោក ម៉ម សុណង់ដូ ប្រធានវិទ្យុសំបុកឃ្មុំ FM 105MHz……………៣៧
ឯកឧត្តម ប៊ុត បូរ៉ុត អគ្គនាយកផ្នែកព័ត៌មាន និងការផ្សព្វផ្សាយនៃក្រសួងព័ត៌មាន…………………………………………………………៣៩

លោក មាស គឹមសួន ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលព័ត៌មាន..........................................................................៤០
លោក មឿន ឈានណារិទ្ធ អ្នកបណ្តុះបណ្តាលខាងសារព័ត៌មាន...........................................................................៤១
កញ្ញា អ៊ុង ចាន់សុភា កាសែតកំបូជស្វ័រ និងវិទ្យុបារាំងអន្តរជាតិ.........៤៣
លោក សយ សុភាព ទូរទស្សន៍CTN........................................៤៤
លោក ស៊ិន សុផាត ប៉ុស្តិ៍លេខ ៥..........................................៤៥
កញ្ញា ឯក ហុង វិទ្យុFM 102...............................................៤៦
លោក ងួន សេរ៉ាត់ កាសែតរស្មីកម្ពុជា ....................................៤៧

## ការបណ្តុះបណ្តាលផ្នែកសារព័ត៌មានៈ នៅតែមានកង្វះខាត ប៉ុន្តែមានការរីកចំរើនជាសន្សឹមៗ.............................៤៩

ក្លឹបអ្នកកាសែតកម្ពុជា.............................................................៥៣
មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មាន...................៥៤
សាកលវិទ្យាល័យភូមិន្ទភ្នំពេញៈ ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍...............................................................៥៥
យែមបូឌាញស៍........................................................................៥៦
សមាគមអ្នកថតរូបកម្ពុជា.......................................................៥៨
សមាគមកម្ពុជាការពារអ្នកកាសែត..........................................៥៩
វិទ្យាស្ថានកម្ពុជាសម្រាប់ការសិក្សាផ្នែកសារព័ត៌មាន...............៦០
មូលនិធិអ្នកសារព័ត៌មានឯករាជ្យ...........................................៦០

# សេចក្តីផ្តើម ៖ ក្រមសីលធម៌វិជ្ជាជីវៈសារព័ត៌មាន

ដើម្បីពង្រឹងការអនុវត្តក្រមសីលធម៌ក្នុងវិជ្ជាជីវៈសារព័ត៌មាន នៅក្នុងប្រទេសកម្ពុជាឆ្នាំ២០០៩ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ បានផ្តួចផ្តើមនូវគំរោងមួយដែលមានឈ្មោះថា **ការលើកកំពស់ឯករាជភាពនៃប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា** ក្រោមការឧបត្ថម្ភមូលនិធិពីសហភាពអឺរ៉ុប។

របាយការណ៏មួយនេះ គឺជាដំណាក់កាលទីមួយនៃគំរោងទាំងមូល។ របាយការណ៏នេះមានគោលបំណងក្នុងការកំណត់នូវបញ្ហាវិភាគ និងផ្តល់នូវដំណោះស្រាយចំពោះជំរើសរបស់អ្នកសារព័ត៌មានកម្ពុជាទាក់ទងនឹងក្រមសីលធម៌ ។

## បញ្ហាដែលទាក់ទងនឹងក្រមសីលធម៌មាន៖

១-ពង្រឹងកំរងផ្លូវច្បាប់សំរាប់ផ្តល់អោយមាននូវសកម្មភាពប្រព័ន្ធផ្សព្វផ្សាយដោយសេរី ជាពិសេសវិទ្យុតាមរយៈការដាក់នូវគោលការណ៏ជារួម និងក្រមច្បាប់។

២- លើកកំពស់ការយល់ដឹងដល់អ្នកកាសែតកម្ពុជាអំពីទំនួលខុសត្រូវ និងការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន។

៣-បង្កើតឡើងនូវក្រមសីលធម៌ជាមាត្រដ្ឋានគំរូមួយសំរាប់អ្នកសារព័ត៌មានកម្ពុជា ដើម្បីឆ្លុះបញ្ចាំងពីវិជ្ជាជីវៈមួយដែលមានភាពឯករាជ្យ ក្នុងការរាយការណ៏ ព្រមទាំងផ្តល់ការគោរពដល់សិទ្ធិរបស់អ្នកសារព័ត៌មាន។

ដោយការកំណត់បាននូវបញ្ហា និងដៅចំបញ្ហារបស់វិជ្ជាជីវៈសារព័ត៌មាន មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ អាចសំរេចបាននូវបំណងរបស់ខ្លួនក្នុងកម្មវិធីជាច្រើន ដើម្បីបំពេញចន្លោះប្រហោងដែលរារាំងបរិយាកាសប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា។

# វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ក្រុមអ្នកស្រាវជ្រាវរបស់មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ បានធ្វើបទសម្ភាសន៍ចំនួន៣៣អស់រយៈពេលបីខែ។ បទសម្ភាសន៍ដែលក្រុមការងារយើងបានធ្វើជាមួយនឹងអ្នកសារព័ត៌មាន និពន្ធនាយក ពាណិជ្ជករ ផ្នែកប្រព័ន្ធផ្សព្វផ្សាយ អ្នកសិក្សា និងគ្រូបណ្តុះបណ្តាលផ្នែកប្រព័ន្ធផ្សព្វផ្សាយ។ ក្រុមអ្នកស្រាវជ្រាវរបស់យើងមិនបានធ្វើការស្ទង់មតិដោយខ្លួនឯងទេ ព្រោះកន្លងមកអង្គការ និងស្ថាប័នជាច្រើនបានធ្វើការស្ទង់មតិ និង បោះពុម្ពផ្សាយនូវទិន្នន័យដែលទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយនេះរួចហើយ។

ការចុះសម្ភាសដល់កន្លែង បន្ថែមការយល់ដឹងស៊ីជម្រៅទៅលើទិន្នន័យស្ទង់មតិដែលមានស្រាប់។ ហើយការសម្ភាសនេះក៏បានផ្តល់នូវរូបភាព និងភាពស្មុគស្មាញនៃបញ្ហាដែលកើតមានឡើង ព្រោះអ្នកដែលឆ្លើយសំណួរអាចផ្តល់យោបល់លើសពីការឆ្លើយសំណួរលើក្រដាស អំពីអារម្មណ៍របស់ពួកគេផ្ទាល់លើបញ្ហាដែលកើតមានឡើងនោះ។ ម្យ៉ាងវិញទៀតគេនឹងជួបប្រទះនូវបញ្ហាជាច្រើនលើការជឿទុកចិត្តអំពីចំលើយទាំងឡាយ នៅពេលគេធ្វើការស្ទង់មតិលើប្រធានបទរសើបមួយចំនួនដូចជាបញ្ហាអំពើពុករលួយ និងក្រមសីលធម៌របស់អ្នកសារព័ត៌មាន។ អ្នកឆ្លើយសំណួរអាចនឹងស្ថិតក្នុងសំពាធពីនិពន្ធនាយក និងសហការីនៅពេលគេឆ្លើយសំណួរ។ ដូច្នេះហើយការពឹងផ្អែកលើស្ថិតិតែមួយមិនអាចផ្តល់អោយអ្នកស្រាវជ្រាវនូវរូបភាពច្បាស់លាស់នៃស្ថានភាពទាំងឡាយបានទេ។

បទសម្ភាសនៅក្នុងរបាយការណ៍នេះ គឺគ្រាន់តែសំរាប់ជាការបន្ថែមនូវទិន្នន័យផ្សេងៗដែលបានប្រមូលដោយអង្គការ ស្ថាប័នមួយចំនួនក្នុងឆ្នាំកន្លងទៅថ្មីៗនេះ។ទិន្នន័យទាំងនេះមិនត្រូវបានផ្លាស់ប្តូរឡើយ។ គ្រប់បទសម្ភាសន៍ទាំងអស់ត្រូវបានធ្វើឡើងនៅកន្លែងឯកជន។

ប្រភពដែលត្រូវបានជ្រើសរើសសំរាប់ធ្វើការសម្ភាស គឺសុទ្ធសឹងតែជាអ្នកស្រាវជ្រាវ រឺ គ្រូបណ្តុះបណ្តាលសារព័ត៌មាន រឺអ្នកសារព័ត៌មានដែលមានបទពិសោធន៍មានសមត្ថភាព ដែលជាបុគ្គលមិនសូវជាស្ថិតក្រោមសំពាធពីសហការី

របស់ខ្លួន។ បុគ្គលទាំងនេះជាធម្មតាតែងតែសង្កេតអំពីទិដ្ឋភាពបរិយាកាសនៃប្រព័ន្ធផ្សព្វផ្សាយក្នុងស្រុក។

ដោយសារកត្តាខាងលើនេះហើយ ទើបជួយសំរួលក្នុងការផ្តល់លទ្ធភាពដល់អ្នកឆ្លើយសំណួរអាចរៀបរាប់នូវសំពាធ និងបញ្ហាទាំងឡាយនៅក្នុងបរិកាសប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាអោយបានគ្រប់ជ្រុងជ្រោយ។ ដូច្នេះហើយទើបរបាយការណ៏នេះអាចបំពេញបន្ថែមយ៉ាងល្អប្រសើរ ដល់ចំនួនទិន្នន័យដែលបានប្រមូលមកជាច្រើនរួចស្រេចនោះ។

បន្ទាប់ពីធ្វើបទសម្ភាសន៏ក្រុមរបស់យើងពិចារណាលើយោបល់ ការព្រួយបារម្ភ និងបទពិសោធន៏របស់អ្នកសារព័ត៌មានទាំងឡាយដែលបាននិយាយពន្យល់។ ហើយបទសម្ភាសន៏ទាំងនោះត្រូវបានដកស្រង់តែចំនុច សំខាន់ៗតែប៉ុណ្ណោះដើម្បីយកមកចុះផ្សាយ។

ក្រុមការងាររបស់យើងបានជួបប្រទះ នូវបញ្ហាមួយចំនួននៅពេលធ្វើបទសម្ភាស។ ពេលខ្លះប្រភពដែលយើងបានសម្ភាសមានភាពអល់ឯក នៅពេលយើងជជីកសួរអំពីរឿងដែលទាក់ទងនឹងបញ្ហានយោបាយ និងអំពើពុករលួយ។ ចំណែកឯប្រភពដែលមិនសូវជាជាប់ពាក់ព័ន្ធនឹងកាសែត ទូរទស្សន៍ រឺ វិទ្យុក្នុងស្រុកនោះ តែងតែអាចឆ្លើយនូវសំណួរដែលទាក់ទងនឹងនយោបាយបានយ៉ាងស៊ីជំរៅ។

លើសពីនេះអ្នកសារព័ត៌មាន ដែលត្រូវបានសួរអំពីកំរិតនៃការប្រព្រឹត្តវិជ្ជាជីវៈរបស់ពួកគេ អ្នកកាសែតទាំងអស់នោះសុទ្ធសឹងតែបានអះអាងថាខ្លួនបានរក្សានូវកំរិតដ៏ខ្ពស់មួយនៃវិជ្ជាជីវៈរបស់ខ្លួន ហើយពួកគេបានបន្ទោសដល់អ្នកសារព័ត៌មានដទៃទៀតដែលមិនគោរពវិជ្ជាជីវៈរបស់ខ្លួន។ និន្នាការនៃការចោទប្រកាន់ខ្លួនឯងមិនត្រូវបានរកឃើញទេ នៅក្នុងរបាយការណ៏ដែលផ្អែកលើការសម្ភាសទាំងស្រុងនេះ។

## របកគំហើញ៖ ប្រព័ន្ធផ្សព្វផ្សាយបែបប្រជាធិបតេយ្យ?

ក្នុងចំណោមមនុស្សដែលត្រូវគេបានសម្ភាសចំនួន៣៣នាក់ និង ការស្ទាបស្ទង់មតិបរិមាណចំនួន៥ ទទួលបានពីអង្គការផ្សេងៗមួយចំនួន និងអ្នកផ្តល់ចំលើយទាំងនេះបានលើកឡើងពីការរីកចំរើនរបស់សិទ្ធិសេរីភាពសារព័ត៌មាន នៅក្នុងប្រទេសកម្ពុជា អំឡុង១០ឆ្នាំចុងក្រោយនេះ ដោយសារតែចំនួនអ្នកកាសែតត្រូវបានគេធ្វើឃាត និងគំរាមកំហែងមានការធ្លាក់ចុះ មិនតែប៉ុណ្ណោះទេប្រទេសកម្ពុជាហាក់ដូចជាបានរក្សានូវច្បាប់សារព័ត៌មានដ៏មានសេរីភាព។ នៅឆ្នាំ១៩៩៧ដែលជាឆ្នាំរដ្ឋប្រហារ អ្នកកាសែតចំនួន៤នាក់ត្រូវបានគេសំលាប់បើប្រៀបធៀបទៅនឹងចំនួនស្លាប់១នាក់នៅឆ្នាំ២០០៣ និង១នាក់នៅឆ្នាំ ២០០៨។

ទន្ទឹមនឹងនោះដែរក្រុមអ្នកជំនួញ និងអ្នកនយោបាយមួយចំនួននៅកម្ពុជាបានចាប់ផ្តើមប្រើប្រាស់ច្បាប់សារព័ត៌មានឆ្នាំ១៩៩៥ ដើម្បីប្តឹងនិងគំរាមកំហែងដល់អ្នកកាសែត។ ទាក់ទងទៅនឹងច្បាប់សារព័ត៌មាន ការរាយការណ៍ រឺផ្តល់ព័ត៌មានខុសគឺជាបទឧក្រិដ្ឋ។


បុរសម្នាក់នេះកំពុងស្វែងរកព័ត៌មានតាមតូបកាសែតក្នុងទីក្រុងភ្នំពេញ

ក្នុងចំណោមប្រព័ន្ធផ្សព្វផ្សាយដូចជាកាសែត ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ និង អ៊ីនធឺណែត អ្នកឆ្លើយតបភាគច្រើនចាត់ទុកថាវិទ្យុមានសេរីភាពខ្លាំងបំផុតជាមួយនឹងស្ថានីយ៍វិទ្យុដូចជា វិទ្យុអាស៊ីសេរី វិទ្យុសំឡេងប្រជាធិបតេយ្យ និងវិទ្យុសំលេងសហរដ្ឋអាមេរិក ដែលផ្សព្វផ្សាយព័ត៌មានរិះគន់រាជរដ្ឋាភិបាល។

កាសែតប្រឈមមុខនឹងការរិះគន់កំរិតខ្ពស់ជាងគេ បើតាមការសម្ភាសទាំងឡាយនេះមកពីមានប្រជាជនកម្ពុជាដែលអាចអានបានចាប់អារម្មណ៍អានជាមួយនឹងការយកចិត្តទុកដាក់ខ្ពស់ទៅលើរឿងនយោបាយដែលជំរុញអោយព័ត៌មាននៅក្នុងកាសែត ទំនងជាមានព័ត៌មាននយោបាយក្តៅគគុក។


អ្នករត់ម៉ូតូកង់បីនៅក្នុងទីក្រុងភ្នំពេញកំពុងស្តាប់ព័ត៌មានតាមវិទ្យុ

ហេតុនេះហើយ ទូរទស្សន៍ និងវិទ្យុ ផ្តោតសំខាន់លើព័ត៌មានកំសាន្តនិងយូរម្តងៗ គឺផ្សព្វផ្សាយពីរឿងនយោបាយ ។

នៅពេលធ្វើការស្រាវជ្រាវនេះនៅដើមឆ្នាំ២០០៩ អ៊ីនធឺណែតបានក្លាយជាប្រធានបទនៃការពិភាក្សា បន្ទាប់ពីក្រសួងព័ត៌មានបានបញ្ជាអោយបិទវិបសាយមានរូបអាសអាភាស មួយគឺវិបសាយរាហ៊ូ (reahu.net) ដែលជាវិបសាយបង្ហាញពីរូបគំនូររបាំអប្សរាក្នុងរាងកាយអាក្រាត។ បើទោះបីប្រព័ន្ធផ្សព្វផ្សាយអ៊ីនធឺណែតនៅកម្ពុជានៅមានទំហំតូចនៅឡើយ និងនៅមានកំរិតទាប សំរាប់កាសែតជាភាសាបារាំងនិងអង់គ្លេស យ៉ាងណាក៏ដោយវានៅមានសេរីភាពក្នុងការចុះផ្សាយព័ត៌មានដែលរសើប ពីមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ហើយមានការព្រួយបារម្ភថាការដាក់បញ្ជាពីរាជរដ្ឋា ភិបាលទៅលើអត្ថបទអាសអាភាសអាចនឹងជះឥទ្ធិពលទៅលើអត្ថបទរឿងនយោបាយ។

## ការទទួលបានព័ត៌មាន

អ្នកត្រូវបានសម្ភាសមួយចំនួនបាននិយាយថា មកទល់ពេលនេះមិនទាន់មានក្រសួងមួយណាមានមន្ត្រីទំនាក់ទំនងសារព័ត៌មានទេ ហើយមានអង្គការតិចណាស់ដែលផ្តល់វគ្គសិក្សាសំរាប់អាជីពជាអ្នក ទំនាក់ទំនងសាធារ ណៈនេះ ដូច្នេះហើយការទទួលបានព័ត៌មានទាក់ទងនឹងរាជរដ្ឋាភិបាល នៅតែមានកំរិតសំរាប់អ្នកកាសែតនៅកម្ពុជានៅឡើយ។

មន្ត្រីជាច្រើនកំរនឹងធ្វើសន្និសីទសារព័ត៌មានណាស់ និងមានទំនោររក្សាព្រឹត្តការណ៍ដែលនឹងអាចកើតឡើងតែនៅក្នុងចំណោមមន្ត្រីរាជរដ្ឋាភិបាលប៉ុណ្ណោះ ។នៅពេលសន្និសីទសារព័ត៌មានធ្វើឡើងដោយអ្នកជំនួញអ្នកកាសែត មួយចំនួនបានទទួលថវិកាដើម្បីចូលរួម។

ដូច្នេះមន្ត្រីរាជរដ្ឋាភិបាល ត្រូវធ្វើការសំរេចចិត្តដោយខ្លួនឯងទាក់ទងទៅនឹងព័ត៌មានដែលពួកគេផ្តល់ទៅអោយអ្នកកាសែត ជាជាងពឹងពាក់ទៅលើច្បាប់ដែល

បែងចែកប្រភេទព័ត៌មានរាជរដ្ឋាភិបាល។ ហើយមជ្ឈមណ្ឌលកម្ពុជា ដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ តែងតែជំរុញអោយក្រសួងទាំងឡាយរៀបចំ ដំណើរការច្បាប់សំរាប់និយាយជាមួយអ្នកកាសែតនិងជួលមន្រ្តីសារព័ត៌មាន។

## ប្រាក់ខែទាប ភាពក្រីក្រ និង សំណូក

ការផ្តល់សំណូកគឺជារឿងធម្មតានៅប្រទេសកម្ពុជា បើទោះបីជាមានការរីកចំរើននៅក្នុងផ្នែកផ្សេងៗនៃប្រព័ន្ធផ្សព្វផ្សាយក៏ដោយ។ ដោយសារអ្នកកាសែតជាច្រើនទទួលបានប្រាក់ខែទាបបំផុត ប្រហែលជា៦ដុល្លារក្នុងមួយរឿងសំរាប់អ្នកសរសេររឿងក្រៅក្របខណ្ឌ ដូច្នេះហើយអ្នកកាសែតជាច្រើនជារឿយៗ តែងតែគំរាមដើម្បីយកប្រយោជន៍ដោយបង្ខំ រឺក៏សំណូមពរការតបស្នងចំពោះការសរសេរបែបវិជ្ជមាន រឺទទួលប្រាក់ដើម្បីចូលរួមសន្និសីទកាសែត។

អ្នកត្រូវគេសម្ភាសមួយចំនួនបានកត់សំគាល់ឃើញថា អ្នកកាសែតទទួលការគោរពបន្តិចបន្តួចនៅកម្ពុជា ដោយសារប្រជាជនកម្ពុជាជាច្រើនចាត់ទុកសារព័ត៌មាននៅក្នុងអាជីពថ្នាក់ទាប។ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ បានជំរុញអោយប្រព័ន្ធផ្សព្វផ្សាយទាំងឡាយគួរតែតំឡើងប្រាក់ខែដល់អ្នកកាសែត ដើម្បីធ្វើអោយវិស័យនេះក្លាយទៅជាអាជីពដែលទទួលបានការគោរពខ្ពស់សំរាប់វណ្ណៈកណ្តាល ដូចនៅក្នុងប្រទេសអភិវឌ្ឍន៏ផងដែរ។

## ទីផ្សារខ្វះនាភិវឌ្ឍន៍ (មិនទាន់មានការអភិវឌ្ឍពេញលេញតែកំពុងដំណើរការ)

ទីផ្សារសារព័ត៌មាននៅកម្ពុជានៅតែមានទំហំតូច និងមិនទាន់មានការអភិវឌ្ឍពេញលេញជាសញ្ញានៃភាពក្រីក្រនៅក្នុងប្រទេស។ ប្រជាជនកម្ពុជាចំនួន៣៥ % អាចរកប្រាក់ចំណូលបាន១ដុល្លារក្នុងមួយថ្ងៃនៅក្នុងឆ្នាំ២០០៨ បើតាមស្ថិតិរបស់រាជរដ្ឋាភិបាល ដូចនេះហើយប្រជាពលរដ្ឋក្នុងស្រុកមួយចំនួនធំមិនអាចមាន

សមត្ថភាពទិញកាសែតទេ មានន័យថាអ្នកផ្សព្វផ្សាយពាណិជ្ជកម្ម ឃើញផលប្រយោជន៍តិចណាស់ក្នុងការចំណាយលុយទៅលើការផ្សព្វផ្សាយ។ មានតែការជួយឧបត្ថម្ភពីអ្នកនយោបាយ គឺជាជំរើសមួយដើម្បីធ្វើអោយកាសែតអាចរស់បាន។

ទោះបីជាយ៉ាងណាការផ្សព្វផ្សាយពាណិជ្ជកម្មនៅកម្ពុជា បានអភិវឌ្ឍនៅក្នុងឆ្នាំថ្មីៗកន្លងមកនេះ។ គឺពីឆ្នាំ ២០០៦-២០០៧ ចំនួនសរុបនៃការផ្សព្វផ្សាយពាណិជ្ជកម្មលើប្រព័ន្ធបោះពុម្ពផ្សាយ និង ទូរទស្សន៍បានកើនឡើងរហូតដល់១៨% និងកើនឡើង ៦% ថែមទៀតនៅឆ្នាំ២០០៨ ។ ទំនោរចំពោះការផ្សព្វផ្សាយជាជាងទំនាក់ទំនងនយោបាយ ប្រហែលជានឹងធ្វើឲ្យអ្នកសារព័ត៌មានមានសេរីភាពក្នុងការនិយាយពីវិបត្តិនយោបាយ បើទោះជាពេលនោះប្រព័ន្ធផ្សព្វផ្សាយត្រូវតែរាយការណ៍ដំណឹងវិជ្ជមាន អំពីម្ចាស់ពាណិជ្ជកម្មក៏ដោយ ។

ក្នុងចំណោមប្រព័ន្ធផ្សព្វផ្សាយទាំងឡាយ វិទ្យុ និងទូរទស្សន៍ជាជម្រើសរបស់ប្រជាជនកម្ពុជា។ ក្នុងចំណោមអ្នកឆ្លើយសំណួរ ២០០០នាក់ ដែលធ្វើការស្ទង់មតិដោយអង្គការអន្តរជាតិ IRI នៅឆ្នាំ ២០០៨ មាន៥១% បានអះអាងថាវិទ្យុជាប្រភពចម្បងនៃព័ត៌មាន ហើយ៣៧% បាននិយាយថា ទូរទស្សន៍ មានតែ១% ប៉ុណ្ណោះបាននិយាយថាកាសែត ហើយ ០,២% បាននិយាយថាអ៊ីនធឺណែតជាប្រភពព័ត៌មានសំខាន់។ ប៉ុន្តែសំរាប់កាសែតនិងអ៊ីនធឺណែតភាគច្រើន គឺសម្រាប់ប្រជាជនក្នុងក្រុងដែលធូរធារប៉ុណ្ណោះ ។


ជាទូទៅទូរទស្សន៍តែងតែចាក់ផ្សាយព័ត៌មានកម្មវិធីចែកអំណោយជូនប្រជាពលរដ្ឋពីសំណាក់មន្ត្រីរដ្ឋាភិបាល

ការកើនឡើងយ៉ាងរហ័ស នៃការផ្សព្វផ្សាយពាណិជ្ជកម្មនៅលើប្រព័ន្ធបោះពុម្ពផ្សាយដូចជា កាសែត និងទស្សនាវដ្ដីជាដើម មានន័យថាកាសែត និងទស្សនាវដ្ដី កំពុងតែរីកចំរើន ប៉ុន្តែប្រព័ន្ធផ្សព្វផ្សាយខាងបោះពុម្ពបន្តនៅក្រៅសង្វៀន និង បន្តទទួលយកការឧបត្ថម្ភពីអ្នកនយោបាយ ។ នៅឆ្នាំ ២០០៧ ការចំណាយលើ

ការផ្សាយពាណិជ្ជកម្មតាមទូរទស្សន៍សរុបគឺ ៤១៨,៤៦៤ស្ពត ស្មើនឹងតម្លៃ ៧០,៥លានដុល្លារសហរដ្ឋអាមេរិក បើប្រៀបធៀបទៅនឹងការផ្សព្វផ្សាយពាណិជ្ជកម្មលើប្រព័ន្ធបោះពុម្ពផ្សាយចំនួន ២៤,៩៣១ស្ពត ស្មើនឹងតម្លៃ ៦,២ លានដុល្លារ (Indochina Citation) ។

## ការសំឡុត និង ការគំរាមកំហែង

ការសម្ភាសភាគច្រើនបញ្ជាក់ថា កម្ពុជាហាក់ដូចជាមានប្រព័ន្ធផ្សព្វ ផ្សាយដែលមានប្រជាធិបតេយ្យគួរសម ជាមួយច្បាប់សារព័ត៌មានដែលមានសេរីភាពក្នុងកម្រិតមួយបង្គួរ បើប្រៀបធៀបទៅនឹងប្រទេសដទៃនៅតំបន់អាស៊ីអាគ្នេយ៍។ បើទោះបីជាយ៉ាងណាក៏ដោយការសំឡុតនិងគំរាមកំហែងក្នុងរូបភាពជាការគំរាមលើរូបរាងកាយ ការសំលាប់ ឬ ការគំរាមបញ្ឈប់ពីការងារ ការក្លែងបន្លំសាច់រឿងដោយសារលុយ ឬ ទំនាក់ទំនងនយោបាយបានទប់ ស្កាត់ការរីកចំរើននៃសេរីភាពសារព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា។

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ មានការព្រួយបារម្ភអំពីចំនួនអ្នកស្លាប់ដែលមិនទាន់បានដោះស្រាយនៅឡើយ ដូចជាករណីអ្នកកាសែតប្រឆាំង គឺលោក ឃឹម សំបូរ នៅក្នុងអំឡុងពេលបោះឆ្នោតសកលកាលពីខែកក្កដាឆ្នាំ ២០០៨ ។ លោក ឃឹម សំបូរ ដែលបានសរសេរអំពីការរឹបអូសដីធ្លី អំពើពុករលួយ សំរាប់កាសែតប្រឆាំង"មនសិការខ្មែរ" ត្រូវបានបាញ់សំលាប់នៅលើផ្លូវអ៊ូរអរមួយក្បែរពហុកីឡាដ្ឋានជាតិអូឡាំពិកជាមួយនឹងកូនប្រុសរបស់គាត់។ ហេតុការណ៍នេះទំនងជាមានលោកមេប៉ូលីស ហុក ឡុងឌី ដែលបានស្លាប់ទៅជាអ្នកបញ្ជាពីក្រោយខ្នងក្នុងការសំលាប់នេះ ដោយសារលោក ឃឹម សំបូរ បានសរសេរពីការគំរាមកំហែងរបស់ប៉ូលីសនៅកាស៊ីណូព្រំដែន ។

មកទល់នឹងខែឧសភា ឆ្នាំ២០០៩ គ្មាននរណាម្នាក់ត្រូវបានគេចោទប្រកាន់ទេ បើទោះបីជាមានការជួយជ្រោមជ្រែងពីការិយាល័យសហព័ន្ធស៊ើបអង្កេត

របស់សហរដ្ឋអាមេរិកក៏ដោយ។ និទ្ទណ្ឌភាពនេះបានក្លាយជាលំនាំមួយនៅក្នុងប្រទេសកម្ពុជា។ អ្នកកាសែតចំនួន១២នាក់ ត្រូវបានគេសំលាប់ចាប់តាំងពីឆ្នាំ ១៩៩២ ប៉ុន្តែគ្មានជនដៃដល់ណាម្នាក់ត្រូវបានផ្តន្ទាទោសទៅតាមផ្លូវច្បាប់ឡើយ ។

## ទង្វាជីវៈ ឬ ជាតនិយម

ជំលោះព្រំដែនរវាងប្រទេសកម្ពុជា និង ប្រទេសថៃលើបញ្ហាប្រាសាទព្រះវិហារដែលកើតឡើងនៅខែកក្កដា ឆ្នាំ២០០៨ កន្លងមកនេះ បានបង្ហាញអំពីភាពទោរទន់របស់អ្នកកាសែតនៅពេលមានវិបត្តិ។ ទូរទស្សន៍ ប្រព័ន្ធបោះពុម្ពកាសែតបានផ្សាយដំណឹងដែលបង្ហាញពីការគាំទ្រយ៉ាងច្បាស់ចំពោះរដ្ឋាភិបាលកម្ពុជា និង គណបក្សប្រជាជន។ បើទោះបីជាប្រព័ន្ធផ្សព្វផ្សាយទាំងនោះគាំទ្រ ឬប្រឆាំងរដ្ឋាភិបាលពីមុនក៏ដោយ នៅពេលនេះពួកគេមានរឿងប្រាសាទព្រះវិហារប្រហាក់ប្រហែលគ្នា។ ចំណែកអ្នកកាសែតកម្ពុជាដែលរាយ ការណ៍ឲ្យប្រព័ន្ធផ្សព្វផ្សាយបរទេសវិញ បានផ្សាយរឿងដែលមានអព្យាក្រិត និង មានការវិភាគច្បាស់លាស់ជាងកាសែតក្នុងស្រុក ។

អ្នកកាសែតជាច្រើនដែលត្រូវបានសម្ភាសអះអាងថា ជាតិនិយមគឺជាគុណសម្បត្តិដ៏មានតម្លៃ ហើយក្រមសីលធម៌វិជ្ជាជីវៈត្រូវបានគេទុកវាដោយឡែក ក្នុងពេលជាតិមានវិបត្តិបែបនេះ ។

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ មានកង្វល់យ៉ាងខ្លាំងចំពោះទំនោររបស់អ្នកកាសែតជាច្រើនដែលសរសេររឿងមានភាពលំអៀង និង ពោរពេញដោយជាតិសាសន៍និយម។ មជ្ឈមណ្ឌលនេះសូមជំរុញឲ្យអ្នកបណ្តុះបណ្តាលខាងប្រព័ន្ធផ្សព្វផ្សាយ និងនិពន្ធនាយកផ្តោតសំខាន់លើព័ត៌មានដែលច្បាស់លាស់ និងមិនមានភាពលំអៀងគ្រប់កាលៈទេសៈ បើទោះបីជាពួកគេមានអារម្មណ៍ថាបូរណភាពទឹកដីកំពុងជួបវិបត្តិក៏ដោយ ។

## ការហាមមិនឲ្យមានការរិះគន់លើអ៊ីនធឺណែត

ខណៈពេលសរសេររបាយការណ៍នេះនៅឆ្នាំ២០០៩ ប្រទេសកម្ពុជាជាប្រទេសចុងក្រោយគេ ដែលជួបប្រទះនឹងការហាមមិនឲ្យមានការរិះគន់លើអ៊ីនធឺណែតដែលកើតឡើងទូទាំងទ្វីបអាស៊ី។ ការរីកចំរើនយ៉ាងលឿនរបស់អ៊ីនធឺណែតនៅតំបន់អាស៊ីចាប់តាំងពីឆ្នាំ២០០០មក បង្ហាញថាអ៊ីនធឺណែតជាឧបករណ៍សំរាប់អ្នកជំទាស់ប្រឆាំងរដ្ឋាភិបាល នឹង បាតុករដើម្បីចែកចាយព័ត៌មាន ដូចជានៅប្រទេសចិន ភូមា ថៃ វៀតណាម និង ម៉ាឡេស៊ី ។ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ពិតជាមានការព្រួយបារម្ភក្រោយពេលក្រសួងព័ត៌មានបានបញ្ជាឲ្យបិទវិបសាយ reahu.net ដែលជាវិបសាយបង្ហាញរូបរចាំអប្សរាក្នុងរាងកាយអាក្រាត។ ការបញ្ជាឲ្យបិទនេះកើតឡើង បើទោះបីជាអត្រាប្រើប្រាស់អ៊ីនធឺណែតទាបស្មើនឹង 0,៤៨ ភាគរយ ឬ ៧0,000ក្នុងចំណោម១៤លាននាក់។ សរុបមកវាបង្ហាញថារូបភាពអប្សរាទាំងនេះនឹងមិនទៅដល់ទស្សនិកជនអោយបានទូលំទូលាយឡើយ។ អត្រាប្រើប្រាស់អ៊ីនធឺណែតរបស់ប្រទេសកម្ពុជាទាបជាងគេនៅក្នុងតំបន់អាស៊ី ។ ហើយ ការបញ្ជាអោយបិទវិបសាយអាសអាភាសនេះ ពិតជាអាចជះឥទ្ធិពលដល់រឿងនយោបាយ ។



ហាងអ៊ីនធឺណែតមួយក្នុងទីក្រុងភ្នំពេញដែលមានអតិថិជនជាប្រចាំ

ចាប់តាំងពីប្រទេសកម្ពុជាមានទំនាក់ទំនងជិតស្និទ្ធជាមួយប្រទេសចិន មកដែលត្រូវគេស្គាល់ថាត្រួតត្រាយ៉ាងតឹងរ៉ឹងលើប្រព័ន្ធអ៊ីនធឺណែតតាមរយៈ Great Firewall of China មានន័យថាប្រទេស ទាំង២នេះ នឹងសហការគ្នាទៅលើបញ្ហាទាក់ទងនឹងព័ត៌មានវិទ្យា និង ទូរទស្សន៍។ ភូមាដែលរក្សាទំនាក់ទំនងជាមួយប្រទេសចិន ក៏បានបញ្ជូនមន្ត្រីទៅកាន់ប្រទេសចិន ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលខាងប្រព័ន្ធបច្ចេកទេស និងការប្រើប្រាស់ជំនាញការរបស់ប្រទេសចិន ដើម្បីធ្វើការវាយប្រហារទៅនិងវិបសាយប្រឆាំងរដ្ឋាភិបាលរបស់ខ្លួននៅប្រទេសណ៍រវ៉េស។ ចំណែកប្រទេសវៀតណាមវិញក៏បានទទួលយកជំនាញការចិន ដើម្បីបង្កើនប្រព័ន្ធ ការពារ Firewall

របស់ខ្លួនសំរាប់ទប់ស្កាត់ព័ត៌មានណាដែលរិះគន់រដ្ឋាភិបាលផងដែរ ។

## អនុសាសន៍

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ សូមផ្តល់អនុសាសន៍ខាងក្រោមដើម្បីកែប្រែប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសកម្ពុជា៖

## ចំពោះអ្នកប្រកបមុខរបរដែលទាក់ទងនឹងប្រព័ន្ធផ្សព្វផ្សាយ

១-បើកវគ្គបណ្តុះបណ្តាលជាប្រចាំដល់អ្នកសារព័ត៌មាន ព្រមទាំងត្រួតពិនិត្យយ៉ាងសកម្មលើចំណេះដឹង និងការអនុវត្តក្រមសីលធម៌នៃវិជ្ជាជីវៈរបស់ពួកគេនៅពេលពួកគេចុះយកព័ត៌មាន។

២-តំឡើងប្រាក់ខែដល់អ្នកសារព័ត៌មាន ដល់កំរិតមួយដែលអនុញ្ញាតអោយគេមានជីវភាពរស់នៅសមរម្យ ដូច្នេះពួកគេនឹងមិនពឹងផ្អែកលើការរកប្រាក់ចំណូល តាមរយៈការចុះផ្សាយព័ត៌មានបែបផ្សាយពាណិជ្ជកម្មដល់បុគ្គល រឺក្រុមណាមួយ។

៣-ធ្វើការយ៉ាងជិតស្និទ្ធជាមួយសមាគមសារព័ត៌មាន មជ្ឈមណ្ឌលបណ្តុះបណ្តាល និងសាកលវិទ្យាល័យដើម្បីត្រួតពិនិត្យមើលដល់គុណភាព និងភាពត្រឹមត្រូវនៃការរាយការណ៍។

៤-បង្កើតស្ថាប័នការពារឯករាជ្យមួយដើម្បីជួយដល់កាសែត ទស្សនាវដ្តី និងស្ថានភាពនៃការផ្សព្វផ្សាយរបស់ស្ថានីយ៍ផ្សេងៗ ជាមួយនិងការធ្វើទីផ្សារតាមរយៈការបង្កើនទំនុកចិត្តរវាងប្រព័ន្ធផ្សព្វផ្សាយ។

## រដ្ឋាភិបាល

១-លុបបំបាត់ចោលបទបញ្ជានៃការហាមប្រាម វិបសាយអាសអាភាស

ដូចជាវិបសាយដ៏ចំរូងចំរាសមួយដែលមាន ឈ្មោះថារាហ៊ូ reahu.net ដើម្បីការពារសេរីភាព ប្រព័ន្ធផ្សព្វផ្សាយតាមរយៈអ៊ីនធឺណេត ក៏ដូចជាការលើកតំកើងនូវការបង្កើនចំនួនវិបសាយ ជាភាសាខ្មែរនៅក្នុងប្រព័ន្ធអ៊ីនធឺណេត។

២-អនុម័តច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន ដែលជាលក្ខណៈនៃច្បាប់ជាមូលដ្ឋានមួយនៃលិទ្ធិប្រជាធិបតេយ្យ ដើម្បីផ្តល់គោលការណ៏ជាមូលដ្ឋានមួយ ដល់មន្ត្រីរដ្ឋាភិបាលមានលទ្ធភាពបង្ហាញជូននូវឯកសារដែលមិនត្រូវបានចាត់ទុកថាជាការសំងាត់របស់រដ្ឋាភិបាល។

៣-មន្ត្រីរដ្ឋាភិបាលគួរតែបង្ហាញពីឆន្ទៈ និងកាតព្វកិច្ចដែលកត្តានេះគឺជាចរិតលក្ខណៈនៃការកសាងប្រជាធិបតេយ្យ។ រដ្ឋាភិបាលត្រូវនិយាយទៅកាន់អ្នកសារព័ត៌មាន និងផ្តល់នូវដំណឹងណាដែលមិនត្រូវបានចាត់ទុកថាជាការសំងាត់របស់រដ្ឋាភិបាលនៅក្រោមច្បាប់ប្រទេសកម្ពុជា។

៤-លុបបំបាត់ចោលនូវច្បាប់បរិហាកេរ្តិ៍ និងច្បាប់ផ្សព្វផ្សាយព័ត៌មានមិនពិតពីក្រមព្រហ្មទណ្ឌកម្ពុជា ដោយកែប្រែទោសព្រហ្មទណ្ឌទាំងនោះអោយទៅជាទោសរដ្ឋប្បវេណីវិញ។

៥-លុបបំបាត់ចោលនូវមាត្រា១២ នៃច្បាប់សារព័ត៌មានដែលតែងតែយកមកប្រើខុសដោយរដ្ឋាភិបាល។ ក្នុងមាត្រា១២សំដៅលើការហាមប្រាមមិនអោយផ្សាយព័ត៌មានដែលគំរាមដល់សន្តិសុខជាតិ និងអស្ថេរភាពនយោបាយដែលអត្ថន័យនេះមានភាពមិនច្បាស់លាស់។

៦-បង្កើតគណៈកម្មការមួយដែលអាព្យាក្រិត និងមានតម្លាភាពមានតួនាទីផ្តល់សិទ្ធិអោយមានការបង្កើតវិទ្យុ និងទូរទស្សន៍ទៅតាមខ្នាតអន្តរជាតិ។

៧-ផ្តល់ជូនធនធានបន្ថែមទៀតដល់ការស៊ើបអង្កេតរកឃាតករសំលាប់អ្នកកាសែតនៅក្នុងប្រទេសកម្ពុជា ដែលក្នុងករណីឃាតកម្មទាំងអស់ កន្លងមកមិនមានករណីណាមួយត្រូវបានដោះស្រាយនៅឡើយទេ។

៨-គ្រប់ក្រសួងនានារបស់រដ្ឋាភិបាលគួរតែបែងចែកចំណែកនៃថវិកា ដើម្បីតែងតាំងប្រធានមន្ត្រីព័ត៌មានដែលមានភារកិច្ច ក្នុងការនិយាយជាមួយអ្នកសារព័ត៌មាន។

## សង្គមស៊ីវិល និងម្ចាស់ជំនួយ

១-សូមអង្គការក្រៅរដ្ឋាភិបាលទាំងអស់ ចូលរួមសកម្មភាពផ្សព្វផ្សាយពីសេរីភាពសារព័ត៌មាន ដែលជាធាតុដ៏ចាំបាច់មួយនៃលិទ្ធិប្រជាធិបតេយ្យ។
២-ប្រជុំជាមួយរដ្ឋាភិបាលដើម្បីធានាអោយបាននូវសេរីភាពសារព័ត៌មាន ។ចូលរួមស៊ើបអង្កេតឃាតកម្ម និងការគំរាមកំហែងចំពោះអ្នកសារព័ត៌មាន និងរក្សាអោយបាននូវសេរីភាពនៃច្បាប់សារព័ត៌មានដូចជាប្រាក់ឈ្នួលរបស់ម្ចាស់ជំនួយ។
៣-ស្វែងរកការសហការគ្នា និងការទំនាក់ទំនងគ្នាជាមួយក្រុមដែលជួយតស៊ូមតិអោយ រីភាពជាអ្នកសារព័ត៌មានត្រួតពិនិត្យយ៉ាងទៀងទាត់លើសេចក្តីបារម្ភហើយនិងកម្មវិធីរបស់ក្រុមទាំងនោះ។
៤-ចូលរួមទាមទារអោយរដ្ឋាភិបាលលុបបំបាត់នូវច្បាប់ និងមាត្រាដែលបានលើកមកបញ្ជាក់ខាងលើនេះ។
៥-ចូលរួមជួយដឹកនាំក្នុងការបង្កើតសមាគមការពារអ្នកសារព័ត៌មាន ដើម្បីការពារនិងលើកកំពស់ដល់សេរីភាពប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា។

## ឯកសារយោង

របាយការណ៍នេះគឺជារបាយការណ៍សង្ខេប និងវិភាគលើទិដ្ឋភាពបរិយាកាសប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសកម្ពុជាប៉ុណ្ណោះ ដែលបំពេញបន្ថែមលើការសិក្សាដទៃទៀតកន្លងមក។ សំរាប់អ្នកស្រាវជ្រាវណាដែលមានបំណងស្រាវជ្រាវអោយបានល្អិតល្អន់ជាងនេះទៅទៀត មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ

ផ្តល់យោបល់អោយអ្នកអាននូវឯកសារសិក្សាខាងក្រោម៖

## សៀវភៅ

Gan, Steven, and James Gomez, et al, eds, Asian Cyberactivism: Freedom of Expression and Media Censorship. Bangkok: Friedrich Haumann Foundation, 2004

ជាមួយនឹងអត្ថបទចំនួន១៨ ដែលបង្ហាញពីចំនុចនៃបញ្ហានៃការត្រួតពិនិត្យលើប្រព័ន្ធអ៊ីនធឺណេតក្នុងទ្វីបអាស៊ី។ អ្នកនិពន្ធបានបង្ហាញពីរូបភាពដែលនៅក្នុងទ្វីបមួយគេប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេត ដើម្បីតស៊ូទាមទារប្រជាធិបតេយ្យក្នុងអត្ថបទទាំងនោះមានអត្ថបទមួយនិយាយពីប្រទេសកម្ពុជា ឯកសារចងក្រងទាំងនេះផ្តល់អោយអ្នកអាននូវបរិបទដ៏ថ្មីនៃតំបន់មួយដែល ប្រទេសកម្ពុជាស្ថិតនៅ ហើយក៏បង្ហាញអោយយើងបានឃើញពីអនាគតរបស់ ប្រទេសកម្ពុជា ដែលទាក់ទងនឹងការត្រួតពិនិត្យលើប្រព័ន្ធ អ៊ីនធឺណេត ។

Balgos, Cecil, ed. *Across the Border: Southeast Asian Chronicles.* Bangkok: Shoutheast Asian Press Alliance, 2005

អត្ថបទទាំងអស់នៅក្នុងឯកសារនេះ ត្រូវបានសរសេរឡើងដោយអ្នកសារព័ត៌មានចំរុះនៅក្នុង SEAPA ក្នុងចន្លោះឆ្នាំ ២០០២ និង២០០៤ ។ អត្ថបទទាំងនេះរួមបញ្ចូលទាំងស្នាដៃដ៏ល្អប្រសើរដែល រៀបរាប់ពីឥទ្ធិពលរបស់ការផ្សព្វ-ផ្សាយតាមវិទ្យុនៅកម្ពុជា។

Mehta, Harish C. *Cambodia Silenced: The Press Under Six Regimes.* Bangkok: White Lotus Press, 1997.

លោក Mehta គឺជាអ្នកសរសេរជីវប្រវត្តិរបស់លោកហ៊ុន សែន និងទ្រង់នរោត្តម រណប្ញទ្ធិ។ នៅក្នុងសៀវភៅនេះក៏បានរៀបរាប់យ៉ាងស៊ីជំរៅអំពីប្រវត្តិនៃប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសកម្ពុជា។ ទោះបីលោក Mehta មានទំនាក់ទំនង

ផ្ទាល់ខ្លួនជាមួយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និងទ្រង់ រណឫទ្ធិ យ៉ាងណាក៏ដោយ ក៏សៀវភៅនេះនៅតែរក្សាបាននូវអព្យាក្រឹត្យភាព ព្រមទាំងក្តោបយកអត្ថន័យទាំងស្រុងនៃការកាត់បន្ថយសេរីភាពសារព័ត៌មានខ្មែរនាសម័យអាណានិគមនិយមបារាំង។ សៀវភៅនេះត្រូវបានបោះពុម្ពឡើងនៅឆ្នាំ១៩៩៧។

Mendel, Toby. *Freedom of Information: A Comparative Legal Survey.* New Delhi: UNESCO, 2003.

សៀវភៅនេះពិនិត្យពីច្បាប់នៃសេរីភាពសារព័ត៌មាន ទូទាំងពិភពលោក ហើយទោះបីជាប្រទេស កម្ពុជាមិនត្រូវបានលើកមកនិយាយក្នុងសៀវភៅនេះក៏ដោយ ក៏សៀវភៅនេះបានឆ្លុះបញ្ចាំងនូវការងារជាមូលដ្ឋានយ៉ាងលំអិតនៃច្បាប់សិទ្ធិទទួលព័ត៌មាននាថ្ងៃអនាគត។

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ តស៊ូមតិក្នុងការបង្កើតនូវច្បាប់ប្រភេទនេះ ដែលនឹងទាមទារអោយរដ្ឋាភិបាលលាតត្រដាងនូវព័ត៌មានដល់អ្នកសារព័ត៌មាន។

Puy Kea. *Radio Profile in Cambodia,* Reahoo Publishing, 2007.

ដោយមានការចូលរួមគាំទ្រពី Korad Adenauer Foundation, សៀវភៅនេះផ្តល់ឯកសារលំអិតអំពីស្ថានីយ៍វិទ្យុ និងច្បាប់ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា។

## របាយការណ៍

Southeast Asian Press Alliance. *Reporting Free Expression Violations in Southeast Asia:*

*A Manual,* 2005.

ឯកសារយោងនេះលំអិតអំពីជំហ៊ានប្រកបដោយសុវត្ថិភាពនៃរបាយការណ៍រំលោភសិទ្ធិសេរីភាពប្រព័ន្ធផ្សព្វផ្សាយ។ ក្នុងរបាយការណ៍នេះក៏មានរៀបរាប់ផងដែរនូវច្បាប់សារព័ត៌មាននៅគ្រប់ប្រទេសក្នុងអាស៊ីអាគ្នេយ៍ ព្រមជាមួយនឹងការស្ទង់

មើលអំពីភាពអសកម្ម និងប្រសិទ្ធិភាពរបស់ច្បាប់នេះ នៅ ក្នុងប្រទេសទាំងនោះ។

Journalism and Media Studies Centre at The University of Hong Kong, et al *Southeast Asia Media Defence Litigation Conference,* 2007.

សាកលវិទ្យាល័យហុងកុងបានចងក្រងនូវឯកសារយោងដែលបានមកពីសន្និសីទស្តីពីច្បាប់សារព័ត៌មានក្នុងឆ្នាំ២០០៧។ នៅក្នុងឯកសារយោងទាំងនោះមានរបាយការណ៍មួយនិយាយអំពីប្រទេសកម្ពុជា ដែលសរសេរដោយ លោក Michael Fowler និយាយអំពីប្រវិត្តិច្បាប់សារព័ត៌មាននៅប្រទេសកម្ពុជា យ៉ាងលំអិតជាពិសេសបន្ទាប់ពីសម័យអ៊ុនតាក់ UNTAC។

LICADHO *Reading Between the Lines: How Politics, Money and Fear Control Cambodia's Media,* 2008.

របាយការណ៏របស់អង្គការលីកាដូ បានផ្តោតលើការរំលោភសិទ្ធិមនុស្សចំពោះអ្នកសារព័ត៌មាន។ ក្នុងរបាយការណ៍នេះប្រមូលឯកសារអំពីឃាតកម្មលើអ្នកសារព័ត៌មានតាំងពីឆ្នាំ១៩៩៤ ។ ហើយក្នុងរបាយការណ៍នេះ ក៏លើកឡើងយ៉ាងសង្ខេបអំពីច្បាប់ និងប្រវត្តិសារព័ត៌មាន ដូចនេះហើយទើបឯកសារនេះមានតំលៃសំរាប់អ្នកស្រាវជ្រាវអំពីប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា ដើម្បីចាប់ផ្តើមនូវការស្រាវជ្រាវដំបូងរបស់ខ្លួន។

Dietz, Bob and Shawn W. Crispin. Media Freedoms Stall as China Sets the Course (from Attacks on the Press, 2008). Committee to Protect Journalists (http://cpj.org/2009/02/media-freedom-china.php), 2008

គណកម្មាធិការដើម្បីការពារអ្នកសារព័ត៌មាន បានដាក់ស្ថានភាព សារព័ត៌-មានកម្ពុជា ទៅក្នុងបរិបទតំបន់ដោយលើកឡើងថាប្រទេសចិនបានរុញអោយប្រទេសនៅអាស៊ីអាគ្នេយ៍ចាកឆ្ងាយពីលទ្ធិប្រជាធិបតេយ្យហើយបាន ផ្តួចផ្តើមអោយប្រព័ន្ធផ្សព្វផ្សាយមានសភាពរឹតត្បិតដោយបរិកាសនយោបាយ។ ក្នុងរបាយការណ៍នេះ ថ្វីត្បិតតែពិនិត្យស្វែងរកភាពអសកម្មយ៉ាងជិតដល់ក្តី តែវាមានភាពសុក្រឹតហើយ

ទោះជាមិនសូវជាលើកពីប្រទេសកម្ពុជាយ៉ាងណាក៏ដោយ ប៉ុន្តែគោលការណ៍ដ៏គួរអោយជឿជាក់មួយដែលវិភាគអំពីសារ ព័ត៌មាន។

Chhay, Sophal and Steven Pak. *Safe Sex and the Media in Southeast Asia: Sex Without Substance,* 2004, AIDS Society of the Philippines.

ក្នុងរបាយការណ៍នេះពិនិត្យអំពីវិធីដែលអាចចូលទៅជិតការផ្សព្វផ្សាយបញ្ហាផ្លូវភេទ ដោយបានលើកឡើងថាអ្នកសារព័ត៌មានមិនសូវជាបានរាយការណ៍ប្រកបដោយប្រសិទ្ធិភាពអំពីបញ្ហាផ្លូវភេទទេ។ ក្នុងរបាយការណ៍នេះបានពន្យល់ពីបញ្ហាជំងឺអេដស៍ និងបញ្ហាផ្លូវភេទជាបរិបទមួយក្នុងតំបន់។

Javis, Helen, and Peter Arfanis, et al. *Publishing in Cambodia.* Center for Khmer Studies, 2006.

Javis និងArfanis បង្ហាញយ៉ាងលំអិតអំពីប្រវត្តិការបោះពុម្ពនៅប្រទេសកម្ពុជា។ ហើយក្នុងរបាយការណ៍នេះ ក៏បានពន្យល់អំពីដំណាក់កាលផ្សេងៗដែលនាំអោយការបោះពុម្ពត្រូវបានដាក់កំហឹតដោយច្បាប់។ ប្រទេសកម្ពុជាបានបង្ហាញអោយឃើញនូវសហគមន៍នៃអ្នកបោះពុម្ពដ៏តូចមួយ ក្នុងន័យដែលថាប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជានៅតែមិនទាន់មានការអភិវឌ្ឍ ហើយធនធានដូចជា សៀវភៅនានាជាភាសាខ្មែរនៅខ្វះខាតនៅឡើយ។

## ប្រវត្តិ: អាទិករនៃប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសកម្ពុជា

ក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជាទាំងមូល ប្រព័ន្ធផ្សព្វផ្សាយរបស់ខ្លួនកំរនឹងមានភាពឯករាជ្យ ហើយថែមទាំងជាឧបករណ៍ឃោសនាដល់របបនីមួយៗជាបន្តបន្ទាប់។ នៅមុនឆ្នាំ១៩៩៥ ដែលច្បាប់សារព័ត៌មានបានត្រូវអនុម័តប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាមានសភាពតិះដៀលគ្នា ហើយម្យ៉ាងទៀតស្ថានីយ៍ ឬកន្លែងបោះពុម្ពផ្សាយមួយចំនួនសុទ្ធសឹងតែជាកម្មសិទ្ធិរបស់បុគ្គលនៅក្នុងរដ្ឋាភិបាល។

ការរំលោភសេរីភាពនៃប្រព័ន្ធផ្សព្វផ្សាយ ចាប់ផ្តើមឡើងនៅក្នុងសម័យ

អាណានិគមនិយមបារាំង ប៉ុន្តែត្រូវបានរឹតបន្តឹងនៅសម័យសង្គមរាស្ត្រនិយមរបស់សម្តេចឪនរោត្តម សីហនុ ក្នុងទសវត្សទី៦០ ក្រោយមកនៅក្នុងសម័យសេនាប្រមុខលន់ នល់ ចាប់ពីឆ្នាំ១៩៦៩ ដល់ឆ្នាំ១៩៧៥ រួចបន្ទាប់មកទៀត នៅក្នុងសម័យខ្មែរក្រហមពួកនិយមផ្តាច់ការម៉ៅ ក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និងក្រោយគេគឺក្នុងសម័យរដ្ឋាភិបាលដែលទ្រទ្រង់ដោយប្រទេសវៀតណាម ចាប់ពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩១។

នៅពេលធ្វើការប្រៀបធៀបក្នុងសម័យកាលកន្លងមកខាងលើនេះ ជាមួយនឹងស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធផ្សព្វផ្សាយ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វ-ផ្សាយឯករាជ្យទទួលស្គាល់ថាមានភាពរីកចំរើននិងមានការផ្លាស់ប្តូរ ចាប់តាំងពីឆ្នាំ១៩៩៣មក ក៏ប៉ុន្តែពួកយើងនៅតែទទូចអោយអ្នកសារព័ត៌មានទាំងឡាយបន្តធ្វើសេរីកម្មច្បាប់សារព័ត៌មាន និងលើកកំពស់អោយបាននូវកំរិតវិជ្ជាជីវៈរបស់ខ្លួនអោយខ្ពស់ជាងមុនបន្តទៅទៀត។

**រវាងឆ្នាំ១៩២០ ដល់ ឆ្នាំ១៩៥៣ អាណានិគមបានលើកតំកើងការផ្សព្វផ្សាយនូវសិល្បៈ និងអក្សរសាស្ត្រ**

គេសង្កេតឃើញថា សារព័ត៌មាននៅសម័យអាណានិគមត្រូវបានលើកតំកើងផ្សព្វផ្សាយនូវសិល្បៈនិងអក្សរសាស្ត្រ ប៉ុន្តែការផ្សព្វផ្សាយដែលទាក់ទងនឹងនយោបាយពុំសូវជាមានទេ។ កម្ពុជសុរិយាត្រូវបានបោះពុម្ពផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិតឈានមុខគេនៅឆ្នាំ១៩២០ ដើម្បីចាប់ផ្តើមឡើងវិញនូវវប្បធម៌របស់ប្រទេសកម្ពុជា។ ហើយព្រឹត្តិប័ត្រនេះត្រូវបានអនុញ្ញាតបោះពុម្ពផ្សាយដោយអាជ្ញាធរបារាំងជាបន្តបន្ទាប់មកដោយគ្មានការរំខានឡើយ។

បន្ទាប់ពីកាសែតជាភាសាខ្មែរលើកដំបូង ដែលមានឈ្មោះថា **នគរវត្ត** មានប្រជាប្រិយក្នុងចំណោម ប្រជាពលរដ្ឋខ្មែរដោយបានបោះពុម្ពចំនួន ៥០០០ ច្បាប់រៀងរាល់ថ្ងៃ កាសែតនេះបានក្លាយទៅជាកាសែតជាតិនិយម និងរកចាប់

កំហុសរដ្ឋបាលបារាំង។ ហើយនៅក្នុងកាសែតនេះក៏មានអត្ថបទមួយចំនួនប្រឆាំងនឹងប្រជាជាតិវៀតណាមដែរ។ រដ្ឋាបាលបារាំងបានបិទកាសែតនេះនៅ ឆ្នាំ១៩៤២ នៅពេលដែលដឹងថានិពន្ធនាយកនៃកាសែតនេះ ចូលរួមដឹកនាំចលនាប្រឆាំងបារាំង។

ក្នុងខណៈពេលនេះដែរ អាជ្ញាធរបារាំងក៏នៅតែត្រួតពិនិត្យយ៉ាងតឹងរឹងដល់វិទ្យុ រួមបញ្ចូលទាំងវិទ្យុរបស់រដ្ឋាភិបាលពោលគឺវិទ្យុជាតិខ្មែរ។ ប្រព័ន្ធផ្សព្វផ្សាយតាមរលកធាតុអាកាសជាទូទៅមិនសូវជាជាតិនិយម ឬប្រឆាំងនឹងបារាំងនោះទេ ក្នុងកំឡុងពេលនោះក៏ប៉ុន្តែអត្ថបទបោះពុម្ពផ្សាយទេដែលជាគោលដៅរបស់អាជ្ញាធរ។

**ស៊ឺន ង៉ុកថាញ់** ដែលជាអតីតនិពន្ធនាយករបស់កាសែតនគរវត្ត ហើយក្រោយមកទៀតនោះ ជានាយករដ្ឋមន្ត្រីនៃប្រទេសកម្ពុជាបានត្រឡប់ពីនិរទេសខ្លួនមកពីជប៉ុនក្នុងឆ្នាំ១៩៤២ ដើម្បីចាប់ផ្តើមបង្កើតកាសែតមួយទៀត ឈ្មោះខ្មែរក្រោក។ បន្ទាប់ពីអាណានិគមបារាំងនិងជប៉ុន ប្រទេសកម្ពុជាបានទទួលឯករាជ្យមិនពេញលេញក្នុងឆ្នាំ១៩៥៣ ហើយក្រោយមកទទួលឯករាជ្យបរិបូរណ៍នៅឆ្នាំ១៩៥៤។

## រវាងឆ្នាំ១៩៥៣ដល់ឆ្នាំ១៩៧០វប្បធម៌របស់សម្តេចសីហនុ

ក្នុងកំឡុងពេលបន្ទាប់ពីបានទទួលឯករាជ្យ ទីផ្សារប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសកម្ពុជាបានដុះជាពន្លក ដែលយ៉ាងហោចណាស់ក៏មានកាសែតប្រចាំថ្ងៃចំនួន ១៣ និងទស្សនាវដ្តីប្រចាំខែចំនួន២ដែរ។

យ៉ាងណាមិញ ក្នុងចន្លោះទស្សវត្សទី៥០ និងទី៦០នេះ ទោះបីជាមានការរីកចំរើននូវចំនួនយ៉ាងណាក៏ដោយ ក៏មានការដាក់កំរិតជាច្រើន និងការបិទដល់ស្ថាប័ន ឬហាមចុះផ្សាយអត្ថបទណាដែលទាក់ទងនឹងនយោបាយ។ បើតាមបញ្ញវ័ន្តមួយចំនួនបានអោយដឹងថា ការរឹតត្បិតនូវបរិកាសនយោបាយបណ្តាលមកពីសម្តេចនរោត្តមសីហនុបានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ សំរាប់បំរើអោយរបប

ផ្ទាល់ព្រះកាយរបស់ព្រះអង្គ ពោលគឺរបបសង្គមរាស្ត្រនិយម។

បន្ទាប់ពីមានការចាប់ដាក់គុកអ្នកសារព័ត៌មានមួយចំនួនដែលក្នុងនោះ មានអ្នកកាសែត២រូប គឺ សាឡុត ឆាយ និងខៀវ សំផន ដែលក្រោយមកជាប់ទាក់ទងនឹងខ្មែរក្រហម ប្រព័ន្ធផ្សព្វផ្សាយបានដាក់បន្ទុកខ្លួនឯងចំពោះអត្ថបទមួយចំនួន។

ដោយសម្តេចសីហនុ បានកំនត់នូវគោលនយោបាយក្រៅប្រទេសយ៉ាងម៉ឺងម៉ាត់ជាប្រទេសមិនចូលបក្សសម្ព័ន្ធក្នុងកំឡុងឆ្នាំ១៩៦០ ពីព្រោះព្រះអង្គខ្លាចប្រទេសធ្លាក់ចូលក្នុងសង្គ្រាមតាមប្រទេសជិតខាង។អ្នកកាសែត បរទេសមួយចំនួនក្នុងប្រទេសកម្ពុជាបានជួបនឹងការរំលោភបំពានសិទ្ធិ។ ក្នុងឆ្នាំ១៩៦៥ ព្រះអង្គបានហាមឃាត់អ្នកកាសែតលោកខាងលិចទាំងអស់ ទោះបីជាការហាមប្រាមនេះមិនសូវជាបានអនុវត្តពេញលេញយ៉ាងណាក៏ដោយ។ នៅក្នុងចំណោមអ្នកកាសែតទាំងនោះគេឃើញមាន Bernard Krisher ដែលជាអ្នកកាសែត News week ក៏ត្រូវបានចោទប្រកាន់ថាបានប្រមាថដល់ព្រះមហាក្សត្រិយានី ក្នុងអត្ថបទរបស់លោកដែរ។

ក្នុងឆ្នាំ១៩៦៦ ទូរទស្សន៍ជាតិកម្ពុជាបានចាប់ផ្តើមផ្សាយក្រោមការត្រួតពិនិត្យយ៉ាងតឹងរឹងពីសំណាក់រដ្ឋាភិបាល។

## រវាងឆ្នាំ១៩៧០ ដល់ឆ្នាំ១៩៧៥ របបទាហ៊ាន លន់ នល់

រដ្ឋប្រហាររបស់លោកលន់ នល់ ទំលាក់សម្តេចព្រះសីហនុក្នុងឆ្នាំ ១៩៧០ បង្ហាញនូវសញ្ញាណមួយនៃការកាត់បន្ថយយ៉ាងគំហុក នៃសេរីភាពសារព័ត៌មានដោយមានការចាប់ដាក់គុកអ្នកកាសែតជាច្រើន។ ក្នុងអត្ថបទកាសែតកោះសន្តិភាពនគរធំ និងខ្មែរឯករាជ្យសុទ្ធតែត្រូវបានដកនូវពាក្យថា រដ្ឋប្រហារតែក្នុងរយៈពេលមួយថ្ងៃ ហើយបានត្រូវបង្ខិតបង្ខំអោយសរសេរនូវ វិចារណកថាដែលគាំទ្រដល់ លន់ នល់ ។ យ៉ាងណាមិញទោះបីជាមានសារព័ត៌មានជាច្រើនគាំទ្រលោកលន់ នល់ ក៏ក្រសួងព័ត៌មាននៅតែចាប់ផ្តើមត្រួត ពិនិត្យយ៉ាងរឹតត្បិតចំពោះកាសែតប្រចាំថ្ងៃ

ក្នុងនោះមានទាំងកាសែតកោះសន្តិភាពដែលជាកាសែតប្រចាំថ្ងៃដ៏ធំមួយផងដែរ។ កាសែតកោះសន្តិភាពបានប្រឆាំងនឹងការរឹតត្បិតទាំងនេះ ដោយបោះពុម្ពនូវកាសែតដែលមានក្រដាសសទទេរ។

ក្នុងច្បាប់សារព័ត៌មានថ្មីរបស់ប្រទេសកម្ពុជានាឆ្នាំ១៩៧២ ហាមមិនអោយមានការចុះផ្សាយអត្ថបទណាដែលបំផ្លាញដល់កេរ្តិ៍ឈ្មោះរបស់បុគ្គលណាមួយ ដើម្បីបិទបាំងនូវរឿងជាច្រើនទាក់ទងនឹងអំពើពុករលួយ។ បើតាមបញ្ញវ័ន្តនាសម័យនោះរបប លន់ នល់ ជារបបមួយដែលរាតត្បាតដោយជំងឺពុករលួយ ហើយមានកាសែតខ្លះសរសេរដោយចំហអំពីរឿងនេះ។

វិទ្យុ និងទូរទស្សន៍នៅតែបន្តត្រួតពិនិត្យយ៉ាងតឹងរឹងពីសំណាក់រដ្ឋាភិបាលដោយមានស្ថានីយ៍មួយចំនួនគ្រប់គ្រងផ្ទាល់ពីក្រសួងព័ត៌មាន។ ក្នុងឆ្នាំ១៩៧២ វិទ្យុជាតិកម្ពុជាមិនបានបង្កើតនូវកម្មវិធីថ្មីៗទេ គឺគ្រាន់តែបានចាក់សារឡើងវិញនូវចំរៀង និងល្ខោននិយាយចាស់ពីមុនមក ព្រោះខ្លាចប៉ះពាល់ដល់ច្បាប់សារ-ព័ត៌មានថ្មី។

## រវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ របបខ្មែរក្រហម

អ្នកសារព័ត៌មានស្ទើរតែទាំងអស់ ត្រូវបានសំលាប់ក្រោមរបបកុម្មុយនីស្តខ្មែរក្រហម ហើយភ្លាមនោះប្រព័ន្ធផ្សព្វផ្សាយក្លាយជាឧបករណ៍ឃោសនានយោ-បាយ។ ទស្សនាវដ្តីយុវជន និងយុវនារីបដិវត្តន៏ និងទស្សនាវដ្តី ទង់បដិវត្តន៏ បោះពុម្ពផ្សាយកំណាព្យបដិវត្តន៏ និងនយោបាយកុម្មុយនីស្តដល់អ្នកអានក្មេងៗ។

អ្នកសារព័ត៌មានបរទេសត្រូវបានហាមឃាត់ លើកលែងតែក្នុងករណីមួយចំនួន។ អ្នកថតរូបបរទេសម្នាក់ត្រូវបានបញ្ជាអោយសំលាប់ចោលដោយ ប៉ុល ពត ដោយពុំ ទាន់បានដឹងពីមូលហេតុរហូតដល់សព្វថ្ងៃនេះ។

ខ្មែរក្រហមបានកេងចំណេញពីអនុភាពផ្សព្វផ្សាយឆ្ងាយរបស់វិទ្យុជាតិនៅខណៈពេលដែលប្រជាជនជាច្រើនមិនអាចអាន រឺសរសេរបាន។ វិទ្យុជាតិបានផ្សាយ

ពីនយោបាយរបស់បក្សកុម្មុយនីស្ត និងចំរៀងរបស់កសិករដែលពន្លិចពន្លង់ទីជនបទដោយគំនិតបដិវត្តន៍។

យ៉ាងណាមិញរបបប្រល័យពូជសាសន៍នេះ បានសំលាប់អ្នកចេះអក្សរដែលមានចំណេះដឹងក្នុងការរាយការណ៍ ហើយប្រព័ន្ធផ្សព្វផ្សាយតាមវិទ្យុជាញឹកញាប់តែងតែមានការកាត់ផ្តាច់ដោយបញ្ហាបច្ចេកទេស។

**រវាងឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩២ ប្រទេសកម្ពុជាស្ថិតក្រោមឥទ្ធិពលរបស់ប្រទេសវៀតណាម**

កងទ័ពវៀតណាមបានដណ្តើមកាន់កាប់បានទីក្រុងភ្នំពេញ នៅឆ្នាំ ១៩៧៩ ហើយវិទ្យុ និងទូរទស្សន៍ ភ្លាមៗនោះស្ថិតក្រោមការគ្រប់គ្រងពីរដ្ឋាភិបាលកុម្មុយនីស្តថ្មីនេះ។ រដ្ឋាភិបាលបានចាប់ផ្តើមទីភ្នាក់ងារយកព័ត៌មានរដ្ឋ ដោយមានឈ្មោះថា សារព័ត៌មានកម្ពុជា (SPK)។

កាសែតឃោសនានយោបាយរបស់គណបក្ស របស់រដ្ឋាភិបាលដែលបានបោះពុម្ព ៥០០០០ច្បាប់ ប្រចាំខែត្រូវបានចែកចាយដោយឥតគិតថ្លៃ។ ការបង្កើតនូវទស្សនាវដ្តី ជាសញ្ញាណមួយនៃការងើបឡើងវិញនៃវិជ្ជាជីវៈសារព័ត៌មានបន្ទាប់ពីរបបខ្មែរក្រហមបានបំផ្លាញនូវវិជ្ជាជីវៈនេះ។

កម្ពុជានៅតែបិទជិតពីពិភពខាងក្រៅ នៅក្រោមការគ្រប់គ្រងកុម្មុយនីស្ត អ្នកសារព័ត៌មានបរទេសជាធម្មតាតែងតែត្រូវបានហាមឃាត់។ អ្នកសារព័ត៌មានបរទេសមួយចំនួនពឹងផ្អែកលើអ្នកយកការណ៍របស់ខ្លួន នៅទីក្រុងបាងកក និងហុងកុង។ រដ្ឋាភិបាលក៏បានហាមមិនអោយផ្សាយពាណិជ្ជកម្ម ពីព្រោះទង្វើទាំងនេះគឺជាទំរង់នៃមូលធននិយម ប៉ុន្តែក្រោយមក ហ៊ុន សែន បានលប់បំបាត់នូវការហាមឃាត់នេះក្នុងឆ្នាំ១៩៨៧ ។

**រវាងឆ្នាំ១៩៩២ ដល់ឆ្នាំ១៩៩៨ UNTAC បានបន្ធូបន្ថយនូវការច្បាមយកប្រព័ន្ធផ្សព្វផ្សាយ**

វិទ្យុUNTAC នាំយកនូវប្រព័ន្ធផ្សព្វផ្សាយសេរីមួយមកដល់ប្រទេសកម្ពុជា។ វិទ្យុនេះចាប់ផ្តើមផ្សាយនៅឆ្នាំ១៩៩២ ក្នុងគោលបំណងចង់អោយប្រជាជនខ្មែរបានស្តាប់នូវបទយកការណ៍អំពីការបោះឆ្នោត និងសិទ្ធិមនុស្សអង្គការសហប្រជា-ជាតិបានចែកជូនប្រជាជននូវវិទ្យុជិត៤០០០០០គ្រឿង។ សារព័ត៌មានបោះពុម្ពនៅតែក្រោមការគ្រប់គ្រងរបស់រដ្ឋាភិបាលដោយកាសែត នៅតែបោះពុម្ពផ្សាយអត្ថបទគាំទ្រ គណបក្សកាន់អំណាច។

សមាគមអ្នកកាសែតខ្មែរ ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៣ បន្ទាប់ពី UNTAC ចាកចេញពីកម្ពុជា។ សមាគមនេះគឺជាសមាគមដំបូងដែលជួយតស៊ូមតិដើម្បីសិទ្ធិសេរីភាពសារព័តមាន ព្រមទាំងប្រឆាំងដល់ការរំលោភបំពានលើអ្នក-កាសែត។ សមាគមនេះបានរិះគន់ដល់គណបក្សប្រជាជន និងកាសែតដែលគាំទ្របក្សកាន់អំណាចនេះ រហូតទីបញ្ចប់សមាគមនេះបានបិទទ្វារ។

ក្នុងឆ្នាំ១៩៩៥ច្បាប់សារព័ត៌មានត្រូវបានបោះពុម្ពផ្សាយដោយមិនខ្វល់ ពីការព្រួយបារម្ភរបស់ម្ចាស់ជំនួយអំពីច្បាប់ដាក់ទោសឧក្រិដ្ឋពីបទផ្សព្វផ្សាយព័ត៌មានបង្ខូចកេរ្តិ៍ឈ្មោះ។

អ្នកសារព័ត៌មានមួយចំនួនត្រូវបានសំលាប់ក្នុងរយៈពេលនេះ។ ក្នុងឆ្នាំ ១៩៩៤ គឺជាឆ្នាំដ៏អាក្រក់របស់អ្នកសារព័ត៌មាន គឺមានអ្នកសារព័ត៌មានចំនួន៣រូបត្រូវបានសំលាប់។ ក្នុងឆ្នាំ១៩៩៦ និង ១៩៩៧ អ្នកសារព័ត៌មាន៥នាក់ទៀតត្រូវបានសំលាប់ ដោយក្នុងនោះមានអ្នកសារព័ត៌មាន៤នាក់ត្រូវបានស្លាប់ក្នុងការបោកគ្រប់បែកនៅមុខរដ្ឋសភានាឆ្នាំ១៩៩៧។

តាំងពីឆ្នាំ១៩៩២ រហូតមកដល់ឥឡូវនេះអ្នកសារព័ត៌មានចំនួន ១២រូបហើយដែលត្រូវបាន សំលាប់ដោយពុំទាន់ស្វែងរកឃាតករឃើញនៅឡើយ។ ស្ថានីយ៍ទូរទស្សន៍ និងវិទ្យុក៏បានជួបប្រទះនឹងការរំលោភបំពាន និងជំលោះនយោបាយផងដែរក្នុងកំឡុងពេលនេះ។ ក្នុងឆ្នាំ១៩៩៧ ពេលដែលមានជំលោះប្រដាប់អាវុធនៅទីក្រុងភ្នំពេញ កងកំលាំងប្រដាប់អាវុធរបស់គណបក្សប្រជាជនបាន

ដណ្តើមគ្រប់គ្រងស្ថានីយ៍ទូរទស្សន៍ដែលគាំទ្រគណបក្សហ៊្វុនស៊ីនប៉ិច។ ហើយស្ថានីយ៍ផ្សព្វផ្សាយផ្សេងៗ ដែលប្រឆាំងនឹងរដ្ឋាភិបាលត្រូវបានទទួលរងការព្រមាន និងប្រឈមមុខនឹងការបិទ។

## ច្បាប់សារព័ត៌មានៈ សេរីភាពតែលើក្រដាសតែមានភាពផ្តាច់ការនៅពេលអនុវត្ត

ច្បាប់សារព័ត៌មានបានអនុម័តនៅឆ្នាំ១៩៩៥ ក្រោមសំពាធពីម្ចាស់ជំនួយអន្តរជាតិ ដើម្បីជំនួសច្បាប់សារព័ត៌មានចាស់ដែលពោរពេញទៅដោយលទ្ធិសង្គមនិយមនាទសវត្សឆ្នាំ ១៩៨០សម័យរដ្ឋកម្ពុជា។ ទោះបីជាច្បាប់នេះមានលក្ខណៈសេរី បើប្រៀបធៀបទៅនឹងច្បាប់របស់ប្រទេសនៅអាស៊ីអាគ្នេយ៍ ប៉ុន្តែនៅពេលអនុវត្តន៍ មន្ត្រីរដ្ឋាភិបាលតែងតែមិនអើពើអំពីអត្ថន័យនៃច្បាប់នោះទេ ឬក៏ប្រើពាក្យមួយចំនួនមិនច្បាស់លាស់ដើម្បីធ្វើអន្តរាគមន៍ដល់អ្នកដែលប្រឆាំង។

ច្បាប់សារព័ត៌មានក៏មានផងដែរនូវសេចក្តីណែនាំមួយចំនួនដែលមិនច្បាស់លាស់ ដូចជាហាមមិនអោយមានការបោះពុម្ពផ្សាយព័ត៌មានមិនពិត ដែលបង្អាប់ដល់ស្ថាប័នជាតិ និងប៉ះពាល់ដល់ប្រពៃណីទំនៀមទំលាប់ល្អរបស់សង្គម ដូចជាពាក្យជេរប្រមាថ។

អ្នកសារព័ត៌មាន នៅតែជាប់បទឧក្រិដ្ឋពីបទផ្សព្វផ្សាយព័ត៌មានមិនពិត និងព័ត៌មានជេរប្រមាថ នៅក្នុងមាត្រា៦៣ នៃក្រមព្រហ្មទណ្ឌរបស់ UNTAC ។ មុនឆ្នាំ២០០៦បទល្មើសទាំងឡាយនេះ អាចប្រឈមមុខនឹងការជាប់ពន្ធនាគារ ប៉ុន្តែមាត្រានេះត្រូវបានធ្វើវិសោធនកម្មដោយគ្រាន់តែពិន័យជាប្រាក់ប៉ុណ្ណោះ។ មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យទទូចអោយរដ្ឋាភិបាលលុបបំបាត់ចោលទាំងស្រុងពីក្រមព្រហ្មទណ្ឌដោយអនុញ្ញាតអោយច្បាប់នេះនៅត្រឹមបទល្មើសរដ្ឋប្បវេណី ដើម្បីគ្រប់គ្រងនូវជំលោះទាក់ទងនឹងរឿងជេរប្រមាថ។

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ ក៏ព្រួយបារម្ភផងដែរ

ចំពោះអវត្តមាននូវច្បាប់ស្តីពីការផ្តល់សិទ្ធិក្នុងការផ្សព្វផ្សាយ ព្រោះកន្លងមកជាញឹកញយការផ្តល់សិទ្ធិផ្សព្វផ្សាយ ជាការសំរេចចិត្តតាមតែក្រសួងព័ត៌មាន។ លទ្ធផលទាំងនេះ មកពីប្រទេសកម្ពុជាមានចំនួនអ្នកមិនចេះអក្សរខ្ពស់ទើបធ្វើអោយប្រជាជនភាគច្រើនពឹងផ្អែកទាំងស្រុងទៅលើទូរទស្សន៍ និងវិទ្យុដោយ ហេតុនេះហើយទើបរដ្ឋាភិបាលកាន់អំណាចរក្សាយ៉ាងរឹងមាំ នូវការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយតាមវិទ្យុនិងទូរទស្សន៍។ ម្យ៉ាងទៀតចាប់តាំងពីឆ្នាំ១៩៩៥មក រដ្ឋាភិបាលបានសន្យាថានឹងអនុម័តច្បាប់ផ្តល់សិទ្ធិក្នុងការផ្សព្វផ្សាយ។

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ សូមសរសើរដល់ការអនុម័តនូវច្បាប់សិទ្ធិទទួលព័ត៌មាន ដើម្បីធានាអោយអ្នកសារព័ត៌មានទទួលបានព័ត៌មានពីរដ្ឋាភិបាលតែក្នុងរយៈពេលកន្លងមក តាមការអនុវត្តជាក់ស្តែងតែងតែមិនត្រូវបានអើពើពីសំណាក់មន្ត្រីរដ្ឋាភិបាល។ ការទទួលបានព័ត៌មានពីរដ្ឋាភិបាលគឺត្រូវបានគ្រប់គ្រងយ៉ាងតឹងរឹង ដូចជាការហាមមិនអោយអ្នកសារព័ត៌មានចូលរដ្ឋសភាបើគ្មានការអនុញ្ញាត និងការហាមមិនអោយមន្ត្រីរដ្ឋាភិបាលនិយាយពីរឿងពុករលួយ។

## ប្រវត្តអ្នកកាសែត៖

### យុត សុខឃឿន ៖ មណ្ឌលព័ត៌មានស្ត្រីកម្ពុជា

បន្ទាប់ពីរៀនចប់ភាសាអង់គ្លេសនៅសាកលវិទ្យាល័យបៀលប្រាយ លោកយុត សុខ ឃឿន បានស្ម័គ្រធ្វើជាអ្នកកាសែតនៅមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ឬវិទ្យុអេហ្វអេម១០២ ជាកន្លែងលោកទទួលបានការបណ្តុះបណ្តាលខាងផ្នែកសារព័ត៌មាន។ នៅឆ្នាំ២០០៦ នៅពេលរៀនបញ្ចប់វគ្គបណ្តុះបណ្តាលនេះ គាត់បានក្លាយទៅជាអ្នកកាសែតពេញសិទ្ធិនៅស្ថានីយវិទ្យុ១០២ ដែលមានជំនាញខាងរាយការណ៍ព័ត៌-មានពីនយោបាយ។ គាត់ត្រូវបានទទួលស្គាល់ បន្ទាប់ពីរាយការណ៍អំពីបញ្ហាក្តៅគគុកទាក់ទងនឹងការបណ្តេញចេញសមាជិកគណបក្សហ៊្វុនស៊ិនប៉ិចពីជួររាជរដ្ឋាភិ-

បាលនៅឆ្នាំ២០០៦ ។ សព្វថ្ងៃនេះគាត់ជាអ្នកផលិតកម្មវិធីការពិត ជាកម្មវិធីវិទ្យុដ៏មានប្រជាប្រិយស្តីអំពី តុលាការខ្មែរក្រហមដែលត្រូវបានចាក់ផ្សាយតាំងពីឆ្នាំ២០០៦ ទាក់ទងនិងដំណើរការកាត់ក្តីខ្មែរក្រហម។ នៅឆ្នាំ ២០០៧ គាត់ទទួលបានការបណ្តុះបណ្តាលអំពីការកាត់ទោសខ្មែរក្រហមនៅក្លឹបអ្នកកាសែតកម្ពុជា ហើយក្រោយមកទទួលបានជ័យលាភីលេខ៣ នៅក្នុងការប្រកួតសរសេរអត្ថបទពីខ្មែរក្រហមដែលរៀបចំដោយក្លឹប ។ក្រោយមកគាត់បានធ្វើដំណើរទៅរៀននៅទីក្រុងម៉ូណិច ទីក្រុងនូរ៉េមបឺក និងប៊ែរឡាំងនៅប្រទេសអាល្លឺម៉ង់ អស់រយៈពេល៣ខែ បន្ទាប់ពីចំណាយពេលរៀនច្បាប់សារព័ត៌មាននៅសកលវិទ្យាល័យចៅក្រមមួយ នៅទីក្រុងភ្នំពេញ ។ ថ្មីៗនេះគាត់ត្រូវបានគេជ្រើសរើសទៅចូលរួមការប្រជុំពីបំលាស់ប្តូរបរិយាកាស ដែលរៀបចំដោយអង្គការសហប្រជាជាតិរយៈពេល ១៥ថ្ងៃ នៅទីក្រុង ផូសនិន ប្រទេសប៉ូឡូញ។

## ការអធិប្បាយ ៖ អ្នកកាសែតដែលមានក្រមសីលធម៌

"អ្នកកាសែតជាមនុស្សដែលសរសេរនូវអ្វីដែលគេឃើញ ប៉ុន្តែពួកគេត្រូវតែស្ថិតក្រោមច្បាប់របស់ប្រទេសមួយ។ ខ្ញុំមិនដឹងថាតើរឿងរបស់ខ្ញុំអាចទទួលការប្រឈមមុខខ្ពស់ប៉ុណ្ណាទេ ដូច្នេះហើយទើបខ្ញុំព្យាយាមធ្វើអោយវាមានតុល្យភាពតាមរយៈការសម្ភាសគ្រប់ប្រភព។ បើសិនជាវាមានភាពលំអៀង នោះវានឹងមានការប្រថុយប្រថានដល់អ្នកកាសែត ។

អ្វីដែលធ្វើអោយបន្ទាបតំលៃរបស់អ្នកកាសែត គឺការកេងប្រវ័ញ្ចលុយពីអ្នកដទៃដែលធ្វើអោយអ្នកកាសែតបាត់បង់កិត្តិយស ។ ពួកគេគួរមានវិជ្ជាជីវៈត្រឹមត្រូវ និងមិនត្រូវទទួលយកសំណូកឡើយ។ អ្នកកាសែតត្រូវរាយការណ៍អ្វីដែលមានតុល្យ-ភាពត្រឹមត្រូវ និងការពិត តែមិនមែនជាការចាក់រុកឡើយ។ នៅពេលដែលខ្ញុំទៅតាមខេត្តធ្វើការ ខ្ញុំមិនមានការលំបាកដូចអ្នកកាសែតដទៃឡើយ។ ខ្ញុំមានវិធីរបស់ខ្ញុំក្នុងការធ្វើការងារ និងនិយាយជាមួយប្រជាជន ។ ខ្ញុំតែងប្រាប់គាត់ថា ខ្ញុំគឺជាអ្នកនាំសារ

របស់ពួកគាត់ តើគាត់ចង់និយាយពីអ្វី ដូច្នេះអ្វីក៏ដោយដែលពួកគាត់ចង់និយាយ នឹងទៅដល់ត្រចៀករបស់មនុស្សរាប់លាននាក់ ។"

**ម៉ែន គឹមសេង, សំឡេងសហរដ្ឋអាមេរិក**

ចាប់តាំងពីឆ្នាំ១៩៩៧ ដល់ ឆ្នាំ១៩៩៨ លោកម៉ែន គឹមសេង បានរៀនសារព័ត៌មាន ទំនាក់ទំនងអន្តរជាតិ និង សារគមនាគមន៍ នៅទីក្រុងប៉ារីស ប្រទេសបារាំង។ ក្រោយពេលត្រឡប់មកភ្នំពេញវិញ លោកធ្វើការអោយកាសែតរស្មីកម្ពុជាពីឆ្នាំ១៩៩៨ ដល់ ឆ្នាំ១៩៩៩ ហើយបន្ទាប់មកធ្វើការអោយទីភ្នាក់ងារសារព័ត៌មានបារាំង (AFP) រហូតដល់ឆ្នាំ២០០២។

បន្ទាប់មកទៀតគាត់ធ្វើការជាមន្ត្រីទំនាក់ទំនងអស់រយៈពេល៤ឆ្នាំ នៅអង្គការសហប្រជាជាតិនៃកម្មវិធីអភិវឌ្ឍន៍ (UNDP) រហូតដល់គាត់ទទួលបានការងារនៅវ៉ាស៊ីនតោនឌីស៊ី ជាអ្នករាយការណ៍ព័ត៌មានអោយវិទ្យុសំលេងសហរដ្ឋអាមេរិកភាសាអង់គ្លេសVOA។

**ការអធិប្បាយ៖ ការគំរាម និងការស្ទាត់ស្ទៀមនៅក្នុងប្រព័ន្ធផ្សព្វផ្សាយ**

*តើប្រព័ន្ធផ្សព្វផ្សាយមួយណានៅកម្ពុជា ដែលអ្នកមានអារម្មណ៍ថាមានសេរីភាពជាងគេ?*

"វាអាស្រ័យទេ បើទោះបីជាសារព័ត៌មាននៅកម្ពុជាមានសេរីភាពក៏ដោយ (បើប្រៀបធៀបទៅនឹងតំបន់ផ្សេងៗ) នៅតំបន់អាស៊ីអាគ្នេយ៍ក៏ដោយ ក៏នៅមានសេរីភាពតិចនៅឡើយនៅក្នុងទូរទស្សន៍ដោយ សារតែមានការហាមប្រាមនៃការរិះគន់ ។ ជាទូទៅប្រព័ន្ធបោះពុម្ព ក៏មានសិទ្ធិសេរីភាពដែរ ប៉ុន្តែវានៅមានកំរិត ពីព្រោះមនុស្សមានអំណាចមួយចំនួនមិនចង់អោយគេរិះគន់នៅក្នុងកាសែត ហើយអ្នកកាសែតអាចត្រូវគេដាក់ទោស។

ស្ថានីយ៍វិទ្យុមួយចំនួនមានសេរីភាព ប៉ុន្តែមានតែសំរាប់សំលេងសហរដ្ឋ

អាមេរិក វិទ្យុអាស៊ីសេរី វិទ្យុបារាំងអន្តរជាតិដែលមានសេរីភាពយ៉ាងពេញលេញ ។ ស្ថានីយ៍វិទ្យុមួយចំនួនក៏ត្រូវទទួលភ្លើងខៀវពីរាជរដ្ឋាភិបាលដែលអាច រឺមិនអាចផ្តល់អាជ្ញាប័ណ្ណ អាស្រ័យថាតើវិទ្យុនោះ នឹងបំរើរាជរដ្ឋាភិបាលរឺអត់ ។"

*តាមការសង្កេតរបស់លោក តើស្ថានភាពសារព័ត៌មាននៅកម្ពុជាតាំងពីអតីតកាលរហូតមកដល់ឥឡូវមានការរីកចំរើនដែររឺទេ?*

"ការរីកចំរើនគឺឆ្ពោះទៅមុខ ប៉ុន្តែវាដើរយ៉ាងសន្សឹមៗមិនលឿនដូចដែលយើងចង់បានឡើយ ជួនកាលវាសឹងតែដើរថយក្រោយទៅវិញ ។ បន្ទាប់ពីឆ្នាំ១៩៩៣ មក មានការគំរាម និងការសំលាប់ ប៉ុន្តែមនុស្សដែលមានបញ្ហាជាមួយអ្នកសារព័ត៌មានប្រើប្រាស់តុលាការដើម្បីកាត់ទោសអ្នកកាសែតចំពោះអ្វីដែលគេសរសេរ។ ទោះបីជាយ៉ាងណានោះគ្រាន់បើជាងការសំលាប់អ្នកកាសែត ដូច្នេះហើយតាមខ្ញុំយល់នោះមិនទាន់មានសេរីភាពទាំងស្រុងទេ។ បើសិនជាយើងគាំទ្រគណបក្សនយោបាយណាមួយ និងយកប្រយោជន៍ពីការវាយប្រហារគណបក្សដទៃទៀតនោះមិនមែនជាវិជ្ជាជីវៈទេ ។"

*តើប្រាក់ខែសព្វថ្ងៃនេះ អាចធ្វើអោយអ្នកកាសែតជាច្រើនឯករាជ្យពីការលំអៀងដែរឬទេ?*

"បើសិនជាយើងនិយាយអំពីទីផ្សារ កាសែតរស្មីកម្ពុជា កោះសន្តិភាព និងកម្ពុជាថ្មី បានផ្តល់ប្រាក់ខែមួយដ៏សមរម្យសំរាប់អ្នកកាសែតដើម្បីផ្គត់ផ្គង់ជីវភាពរបស់ពួកគាត់អោយបានគ្រប់គ្រាន់។ ជាការពិតណាស់អ្នកកាសែត មិនអាចក្លាយជាអ្នកមានបានឡើយ ។

បើសិនជាយើងយកកត្តាប្រាក់ខែជាម៉ែត្រវាស់ភាពឯករាជ ឬភាពមិនឯករាជវិញ ខ្ញុំមិនឯកភាពទាំងស្រុងនោះទេ ពីព្រោះមានអ្នកកាសែតមួយចំនួនដែលធ្វើការអោយកាសែតតូចតាចគិតថា បើទោះបីជាគាត់ទទួលបានប្រាក់ខែច្រើនប៉ុន្មានក៏ដោយ ក៏ពួកគាត់នៅតែទំលាប់គំរាមកំហែងគេយកលុយដដែល ។"

*តើអ្នកកាសែតខ្មែរមានភាពងាយស្រួលក្នុងការរកការងារដែររឺទេ? ហេតុអ្វី?*

"សំរាប់អ្នកកាសែតដើម្បីទទួលបានការងារ សូមកុំក្រឡេកមើលទៅលើការសរសេរកាសែតពេក មានការងារជាច្រើនទាក់ទងនឹងសារគមនាគមន៍ និងទំនាក់ទំនងសាធារណៈ។ មានអង្គការជាច្រើនដែលត្រូវការពួកយើង ប៉ុន្តែជាទូទៅអ្នកកាសែតតែងធ្វើការងារ២ រឺ ៣។"

*នៅពេលអ្នកធ្វើជាអ្នកកាសែតនៅទីនេះ តើអ្នកមានការងារតែមួយឬយ៉ាងណា? តើផ្នែកណាដែលអ្នកច្រើនសរសេរអំពី?*

"នៅពេលខ្ញុំមានការងារមួយ ខ្ញុំធ្វើការងារមួយនោះអោយល្អ។ ខ្ញុំភាគច្រើនសរសេរអំពីនយោបាយ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ។ ហើយនៅពេលខ្ញុំធ្វើការអោយទីភ្នាក់ងារសារព័ត៌មានបារាំង ខ្ញុំសរសេររឿងគ្រប់យ៉ាងដែលជាទីទាក់ទាញរបស់អ្នកអានអន្តរជាតិ ។"

*តើអ្នកធ្លាប់ទទួលការគំរាមកំហែងដែរឬទេ?*

"មិនដែលទេ។ ខ្ញុំតែងប្រកាន់វិជ្ជាជីវៈ ដូច្នេះ ខ្ញុំតែងមានសុវត្ថិភាព។"

*តើអ្នកមានដំបូន្មានអ្វីសំរាប់អ្នកកាសែតកម្ពុជាដែលអាចទទួលការគំរាមកំហែងពីការរាយការណ៍របស់គេ?*

"ជាទូទៅមនុស្សដែលគំរាមយើងច្រើនតែខ្លាចយើង នេះបង្ហាញពីសកម្មភាពដ៏ទន់ជ្រាយរបស់គេ ដោយការជួលគេអោយសំលាប់អ្នកកាសែតនោះ ដោយសារតែពួកគេមិនហ៊ានប្រើប្រាស់ប្រព័ន្ធតុលាការដើម្បីដាក់ទោសយើងចំពោះអ្វីដែលយើងនិយាយពីពួកគេនៅក្នុងកាសែត ។"

## ជូឌីស ខ្លាក មកពីមហាវិទ្យាល័យហុងកុង

លោកស្រីខ្លាកចាប់ផ្តើមអាជីពអ្នកកាសែតក្នុងស្ថានីយ៍របស់រដ្ឋាភិបាល ក្នុងតំបន់ Radio Hong Kong នៅឆ្នាំ១៩៨០ បន្ទាប់ពីបានបញ្ចប់កំរិតអនុបណ្ឌិតផ្នែកការសិក្សាពីអាស៊ី។ ដោយសារតែគាត់ចង់ធ្វើការអោយមានភាពទូលំទូលាយ ជុំវិញអាស៊ី នៅឆ្នាំ១៩៨១ គាត់ក្លាយជាអ្នកស្រាវជ្រាវនៅ Asia Week ជាទស្សនាវដ្តីដែល

មានមូលដ្ឋាននៅហុងកុង គ្របដណ្តប់តំបន់ទាំងមូល។ គាត់ក៏ក្លាយទៅជានិពន្ធនាយកកូពី រួចមកធ្វើជានាយិកាចាត់ការទូទៅ។ គាត់ចង់ធ្វើជាអ្នកកាសែតនៅពេលនោះ ហើយបន្ទាប់ពីធ្វើការបានយ៉ាងល្អ ក្នុងការធ្វើដំណើររាយការណ៍២អាទិត្យទៅប្រទេសស្រីលង្កា នៅឆ្នាំ១៩៨៤ គាត់ត្រូវបានគេតែងតាំងនៅបាងកក ឆ្នាំ១៩៨៥ ដើម្បីរាយការណ៍ពីតំបន់ឥណ្ឌូចិន។ នៅពេលនោះវាមានការលំបាកណាស់សំរាប់ជាតិសាសន៍ដែលមិនស្ថិតនៅក្នុង ប្លុកសូវៀត ដើម្បីចូលទៅកាន់ប្រទេសវៀតណាម កម្ពុជា និង ឡាវ ហើយមានតែជនជាតិខ្មែរប៉ុណ្ណោះដែលគាត់អាចទំនាក់ទំនងបាន គឺក្រុមអ្នកតស៊ូដែលរស់នៅទីក្រុងបាងកក និងជនភៀសខ្លួនរាប់ពាន់នាក់ដែលរស់នៅជំរុំព្រំដែនថៃ ។ គាត់ត្រូវរង់ចាំរហូតដល់ដើមឆ្នាំ១៩៨៦ មុនពេលទទួលបានវីសារទៅទីក្រុងភ្នំពេញ។ គាត់បានធ្វើដំណើរជាមួយអ្នកកាសែតលោកខាងលិចមួយក្រុមធំ ដើម្បីរាយការណ៍ពីការប្រជុំរបស់មន្ត្រីការបរទេសតំបន់ឥណ្ឌូចិន។ បន្ទាប់ពីរាយការណ៍នៅទីក្រុងភ្នំពេញអស់រយៈពេល៣ទៅ៤ឆ្នាំមក គាត់ក្លាយទៅជាអ្នកឆ្លើយឆ្លងរបស់ Asia Weekបន្ទាប់មកជានិពន្ធនាយកធំទទួលខុសត្រូវខាងការរាយការណ៍នៅប្រទេសចិន និង តំបន់ឥណ្ឌូចិន។ គាត់បានចាកចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៩០ ដើម្បីក្លាយជាគ្រូបង្រៀនសារព័ត៌មាននៅ មហាវិទ្យាល័យ Hong Kong Baptist រហូតមកដល់ពេលឥឡូវនេះ។ហើយគាត់បានត្រឡប់មកកម្ពុជា ២ ទៅ៣ ដង ដើម្បីធ្វើការលើគំរោងការស្រាវជ្រាវ សង្កេតពីការរីកចំរើននៃប្រព័ន្ធផ្សព្វផ្សាយនេះជាការធ្វើដំណើរដែលវែងបំផុតនៅឆ្នាំ១៩៩៤ និង ២០០៥។

## ការអធិប្បាយ ៖ ការរីកចំរើនខាង ប្រព័ន្ធផ្សព្វផ្សាយផ្នែកបោះពុម្ព

"ប្រជាជនកម្ពុជាមិនដែលស្គាល់សេរីភាពសារព័ត៌មានទេ នៅមុនឆ្នាំ១៩៩១ មានតែប្រជាជនកម្ពុជាដែលរស់នៅក្រៅប្រទេសប៉ុណ្ណោះ ប៉ុន្តែពួកគេបានស្គាល់វាក្នុងអំឡុងពេលការបោះឆ្នោតលើកដំបូងនៅឆ្នាំ១៩៩៣។ "ខ្ញុំបានធ្វើទស្សនកិច្ចទៅកាន់ទីស្នាក់ការកាសែត និងកន្លែងចាក់ផ្សាយជាច្រើននៅឆ្នាំ១៩៩៤ ហើយ

បុគ្គលិករបស់គេមានបទពិសោធន៍គ្រប់ប្រភេទ ប្រព័ន្ធផ្សព្វផ្សាយសីហនុឆ្នាំ១៩៦០ ប្រព័ន្ធផ្សព្វផ្សាយសាធារណរដ្ឋខ្មែរ ឆ្នាំ១៩៧០ ប្រព័ន្ធផ្សព្វផ្សាយបែបសូវៀត ឆ្នាំ១៩៨០ ក៏ដូចជាអ្នកដែលត្រឡប់មកពីប្រទេសផ្សេងៗដែរ ក៏មានអ្នកចូលរួមដែលធ្លាប់ធ្វើការជាមួយ UNTAC ដែរ ។"

"អ្នកកាសែតទាំងនោះពិតជាម៉ឺងម៉ាត់ និងមានសមត្ថភាព ហើយអ្នកកាសែតជាច្រើនបានចូលរួមវគ្គសិក្សាបណ្តុះបណ្តាល ដែលផ្តល់ដោយ UNESCO និងក្រុមផ្សេងទៀត។ ទោះបីជាយ៉ាងណា សេរីភាពសារព័ត៌មានដែលមានភាពច្រងេងច្រង៉ាង តែងតែប្រថុយនឹងការធ្វើអោយអ្នកដទៃអន់ចិត្ត ហើយអាជីពនេះបានក្លាយទៅជាការងារដ៏គ្រោះថ្នាក់មួយ ដោយសារតែនយោបាយជូរចត់នៅពេលនោះ។"

"បញ្ហាដ៏ធំមួយសំរាប់ប្រព័ន្ធផ្សព្វផ្សាយដែលកំពុងតែរីកលូតលាស់គឺការខ្វះខាតទីផ្សារនៅប្រទេសកម្ពុជា។ ជនជាតិខ្មែរជាច្រើនមានស្ថានភាពក្រីក្រលំបាក មិនអាចទិញកាសែត ដូច្នេះហើយទើបម្ចាស់ពាណិជ្ជកម្ម មិនឃើញប្រយោជន៍ក្នុងការទិញការផ្សាយលើប្រព័ន្ធផ្សព្វផ្សាយ ដូច្នេះហើយទើបការឧបត្ថម្ភពីអ្នកនយោបាយដែលជាវិធីតែមួយគត់ដើម្បីរស់បាន។ ទោះជាយ៉ាងណាក៏ដោយ កាលដែលនយោ-បាយកាន់តែគ្មានភាពប្រេះឆា ទីផ្សារកាន់តែរីកចំរើន ការបោះពុម្ពដែលមានវិជ្ជាជីវៈជាច្រើនកាន់តែកើនឡើង ហើយពួកគេកាន់តែអាចទាក់ទាញការផ្សាយពាណិជ្ជកម្មដើម្បីជួយខ្លួនគេបាន។"

"វាជារឿងដ៏គួរឲ្យរីករាយណាស់ ដែលសម្លេងខាងគណបក្សប្រឆាំងនៅមានក្នុងប្រព័ន្ធផ្សព្វផ្សាយទាំងក្នុងកាសែតប្រឆាំង និងនៅក្នុងស្ថានីយ៍វិទ្យុមួយចំនួនដែលមានការរិះគន់រដ្ឋាភិបាល ។"

"ចំណុចខ្សោយបំផុតរបស់ប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា គឺដំណឹងផ្សាយតាមទូរទស្សន៍ដែលយើងហៅថាដំណឹងពិធីការ ដែលទាក់ទងនឹងសកម្មភាពប្រចាំថ្ងៃរបស់អ្នកដឹកនាំ។នេះមិនមែនជាដំណឹងដែលគួរចុះផ្សាយទេ ដូច្នេះហើយរាជរដ្ឋា-ភិបាលគួរតែបន្ធូបន្ថយនូវមាតិកាព័ត៌មានបែបនេះ ។"

"គុណវិបត្តិមួយទៀតសម្រាប់អ្នកកាសែតនៅកម្ពុជាគឺថាៈប្រទេសកម្ពុជាមានការដើរយឺតជាង ប្រទេសអាស៊ីដទៃទៀតខាងផ្នែកបច្ចេកវិទ្យា ប៉ុន្តែវាក៏ជាផលប្រយោជន៍មួយផ្នែក ដោយសារតែប្រព័ន្ធផ្សព្វផ្សាយបែបប្រពៃណីទាំងនេះមិនរងគ្រោះពីការប្រកួតប្រជែងនៃប្រព័ន្ធអ៊ីនធឺណែតដូចដែលមាននៅក្នុង ប្រទេសអភិវឌ្ឍន៍មួយចំនួនឡើយ ។"

## លោក ខៀវ កូឡា ស្ថាបនិក សារព័ត៌មានដើមអំពិល

គាត់ចាប់ផ្តើមធ្វើជាអ្នកកាសែតឆ្នាំ១៩៨៨ នៅទស្សនាវដ្តីកម្ពុជាដែលជាទស្សនាវដ្តីឃោសនារបស់រដ្ឋាភិបាលនៅពេលនោះ។ ទស្សនាវដ្តីនេះរាយការណ៍គ្រប់យ៉ាងអំពីសកម្មភាពរបស់រដ្ឋាភិបាល និង ទំនាក់ទំនងការទូតជាមួយប្រទេសកុម្មុយនីស្តដទៃទៀត។ ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៣ គាត់ជាអ្នកបកប្រែឲ្យ UNTAC ។ បន្ទាប់ពីឆ្នាំ១៩៩៣ គាត់ក្លាយជាអ្នកកាសែតឲ្យ SPK ដែលគេស្គាល់ថាទីភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP) មកទល់សព្វថ្ងៃនេះ ។ ការរាយការណ៍របស់គាត់ច្រើនផ្តោតលើបញ្ហាសង្គម វប្បធម៌ និងនយោបាយ ។

នៅឆ្នាំ១៩៩៥ គាត់បានបិទថ្នាក់ភាសាអង់គ្លេសរបស់គាត់ ដោយសារគាត់បានយកអត្ថបទដំណឹងរបស់កាសែតភ្នំពេញប៉ុស្តិ៍ជាភាសាអង់គ្លេសមកបង្រៀនសិស្ស ។ អត្ថបទនោះមានចំណងជើងថា រាជរដ្ឋាភិបាលបានបំផ្លាញព្រៃឈើ។ ពីឆ្នាំ១៩៩៥ ដល់ ឆ្នាំ១៩៩៧ អត្ថបទនិពន្ធចំនួន២០ សរសេរឲ្យកាសែតរស្មីកម្ពុជា ។ អត្ថបទទាំងនោះនិយាយអំពីបញ្ហាសង្គម នយោបាយ និងយោបល់ចំៗរបស់គាត់អំពីស្ថានភាពរបស់ប្រទេសកម្ពុជានាពេលនោះ ។

នៅឆ្នាំ ១៩៩៥ គាត់ធ្វើជាអ្នកបកប្រែ និង អ្នកកាសែតឲ្យទស្សនាវដ្តីប្រជាប្រិយដែលស្ថាបនាដោយលោក ប្រាជ្ញ ស៊ីម ដែលជាអតីតអ្នកកាសែត (AKP)។ គាត់រាយការណ៍អំពីជីវិតរស់នៅរបស់តារាភាពយន្តខ្មែរឲ្យទស្សនាវដ្តីនោះ។ ពីចុងឆ្នាំ ១៩៩៧ ដល់ឆ្នាំ២០០២ គាត់បានរាយការណ៍ឲ្យកាសែតចិន South China

Morning Post និង ឲ្យវិទ្យុសម្លេងសហរដ្ឋអាមេរិកជាភាសាអង់គ្លេស ។

នៅឆ្នាំ២០០៥ លោក ឆាលស៍ រ៉េ ដែលជាអតីតឯកអគ្គរដ្ឋទូតរបស់សហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា បានអញ្ជើញលោកទៅទស្សនកិច្ចនៅសហរដ្ឋអាមេរិករយៈពេល ៣០ ថ្ងៃ នៅទីនោះគាត់បានចូលរួមវគ្គបណ្តុះបណ្តាលខាងសារព័ត៌មានស៊ើបអង្កេត ។ ពីឆ្នាំ២០០២ ដល់ឆ្នាំ២០០៨ គាត់ធ្វើការឲ្យទីភ្នាក់ងារសារព័ត៌មានអាឡឺម៉ង់ (DPA) ។ នៅថ្ងៃទី១៩ ខែធ្នូ ២០០៦ គាត់បានបង្កើតកាសែតដើមអំពិល ហើយសព្វថ្ងៃសរសេរសេចក្តីអធិប្បាយពីនយោបាយ ។

## ការអធិប្បាយ ៖ ផលវិបាកនៃការរាយការណ៍នៅកម្ពុជា

"អ្វីដែលអ្នកកាសែតដូចខ្ញុំចង់បានពីមុន គឺធ្វើម៉េចអោយអាចសំភាសសំខាន់បាន ។ បើសិនជាគេអនុញ្ញាតវិញ វាហាក់ដូចជាការប្រទានពីព្រះ ។"

"ប៉ុន្តែអ្នកកាសែតមួយចំនួនមិនសូវមានអាជីពសោះ ពួកគេទូរស័ព្ទហៅមនុស្សម្នាក់ដែលពួកគេអាចសរសេរ ដើម្បីទារយកលុយ ។"

"ខ្ញុំធ្លាប់បានទទួលនូវការគំរាមកំហែងរាប់មិនអស់ពីក្រុមនៃមនុស្ស មួយចំនួនដែលគិតពីផលប្រយោជន៍របស់គេជាជាងការអភិវឌ្ឍរបស់ប្រទេស ។ យើងត្រូវការការកែទម្រង់ពិតប្រាកដ មិនមែនគ្រាន់តែនិយាយតែមាត់នោះទេ ។"

"អ្នកកាសែតកម្ពុជាប្រឈមមុខនឹងផលវិបាកមួយចំនួន ទីមួយគឺប្រាក់ខែទាប ទីពីរគឺការពិចារណានៅទាប ។ ទាំងនេះទប់ស្កាត់មិនឲ្យពួកគេមានភាពឯករាជ ។ ចំណុចខ្សោយនោះគឺថា ពួកគេចូលចិត្តប្រើប្រាស់ស្រាមុនពេលសរសេរ ។ ស្រាងាយស្រួលធ្វើឲ្យពួកគេឈ្លោះប្រកែកគ្នា ។ ចំណុចខ្សោយគឺថាកាសែតក្នុងតំបន់ច្រើនតែគ្រប់គ្រងដោយគណបក្សនយោបាយ ។"

"អ្នកកាសែតភាគច្រើនជាអ្នកជាតិនិយម ខ្ញុំសូមសរសើរដោយស្មោះចំពោះការស្នេហាជាតិរបស់ពួកគេ ពីព្រោះបើទោះបីជាពួកគេមកពីកាសែតផ្សេងៗគ្នា កាន់កាប់ដោយគណបក្សនយោយបាយផ្សេងៗគ្នាក៏ដោយ ក៏ពួកគេបោះពុម្ពនូវមាតិកា

បង្ហាញនូវការស្នេហាជាតិនៅថ្ងៃតែមួយដែរ ។"

## លោក ប៉ែន សមិទ្ធិ (ប៉ែន ផេង) និពន្ធនាយកកាសែតរស្មីកម្ពុជា

នៅឆ្នាំ ១៩៨១ លោកសមិទ្ធិធ្វើការជាអ្នកកាសែតអោយកាសែតឈ្មោះថា ភ្នំពេញ ជាកាសែតដំបូងដែលបោះពុម្ពមួយដងក្នុងមួយសប្តាហ៍ក្រោយពីរបបខ្មែរក្រហមដួលរលំទៅ។

កាសែតនេះនៅក្នុងការត្រួតត្រារបស់បក្សប្រជាជនបដិវត្តន៏កម្ពុជា ឥឡូវនេះត្រូវបានគេស្គាល់ថាគណបក្សប្រជាជនកម្ពុជា ។

ពីឆ្នាំ១៩៨៦ ដល់ឆ្នាំ១៩៨៨ គាត់បានសិក្សាផ្នែកវិទ្យាសាស្ត្រនយោបាយនៅប្រទេសវៀតណាម ។ បន្ទាប់ពីត្រឡប់មកប្រទេសកម្ពុជានៅឆ្នាំ១៩៨៨ វិញ គាត់ត្រូវបានគេតែងតាំងជានិពន្ធនាយកឲ្យកាសែតភ្នំពេញ ។

ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៩ គាត់ធ្វើជានិពន្ធនាយកឲ្យកាសែតរស្មីកម្ពុជាក្រោមឈ្មោះថាប៉ែន ផេង ។ គាត់និយាយថាពីមុនអ្នកកាសែតកម្ពុជាមានទម្លាប់ប្រើប្រាស់ឈ្មោះផ្សេងនៅក្នុងអត្ថបទរបស់ពួកគេ ដោយសារតែភាពភ័យខ្លាចការធ្វើបាប ។ គាត់បានអះអាងថាគាត់ចង់ចាប់ផ្តើមឈ្មោះពិត ប៉ុន្តែឈ្មោះប៉ែនផេង ត្រូវបានអ្នកអានស្គាល់គ្រប់គ្នាទៅហើយ ។

## ការអធិប្បាយ៖ ការរីកចំរើនក្នុងប្រព័ន្ធឃោសនា

"សព្វថ្ងៃនេះស្ថានភាពប្រព័ន្ធផ្សព្វផ្សាយគឺគ្រាន់បើជាងពីមុន ពីព្រោះយើងមានទម្លាប់ល្អជាងមុន ហើយប្រជាជនចេះប្រើប្រាស់មធ្យោបាយដើម្បីដោះស្រាយបញ្ហា។ ហើយគំនិតដែលថាធ្វើអ្នកកាសែតត្រូវជាប់គុកក៏លែងមានដែរ ។"

"ឥឡូវបើកាសែតរបស់ខ្ញុំ មានរឿងទាក់ទងនឹងបញ្ហាសង្គម និង រឿងពុករលួយ វាសឹងតែលក់ដាច់រាល់ថ្ងៃ។ ហើយទស្សនៈរបស់ប្រជាជនកម្ពុជាជាច្រើននាក់បានផ្លាស់ប្តូរជឿនលឿនជាងមុន។ ពួកគេចាប់អារម្មណ៍ទៅនឹងការបោះឆ្នោតជ្រើស

រើសប្រធានាធិបតីនៅសហរដ្ឋអាមេរិក និង វិបត្តិសេដ្ឋកិច្ចពិភពលោក ។"

"កាលពីមុនអ្នកកាសែតគ្រាន់តែជាសាស្ត្រាចារ្យ និងអ្នកនិពន្ធដែលស្រឡាញ់ចូលចិត្តការសរសេរប៉ុណ្ណោះ ពួកគេអត់មានទទួលបានការបណ្ដុះបណ្ដាលដូចអ្នកកាសែតឥឡូវឡើយ។ បើសិនជាយើងគិតជាស្តង់ដារនាពេល បច្ចុប្បន្ននេះក្នុងការវាស់វិជ្ជាជីវៈរបស់ពួកគេនៅពេលមុន យើងអាចនិយាយថាពួកគេសឹងតែមិនមានវិជ្ជាជីវៈគ្រប់គ្រាន់ទាល់តែសោះនាពេលនោះ ។

"ដើម្បីឲ្យអ្នកកាសែតចៀសផុតពីបញ្ហានៅក្នុងជីវិត ដំបូងពួកគាត់ត្រូវតែមានភាពក្លាហានក្នុងជីវិត ហើយបើសិនជាពួកគាត់សរសេររឿងដែលប៉ះពាល់ដល់អំណាចរបស់អ្នកណាម្នាក់ ពួកគាត់ត្រូវតែមើលឡើងវិញ ពិនិត្យឲ្យបានច្រើនដងហើយសរសេរវាម្ដងទៀត។

## លោក ប្រាជ្ញ ស៊ីម និពន្ធនាយក ទស្សនាវដ្ដីប្រជាប្រិយ

សព្វថ្ងៃលោកជាប្រធាននិពន្ធនាយករបស់ទស្សនាវដ្ដីប្រជាប្រិយ ដែលមានប្រជាប្រិយភាពជាងគេនៅកម្ពុជា ។ លោកប្រាជ សុីម ចាប់ផ្ដើមអាជីពជាអ្នកកាសែតឲ្យ SPK ជាភ្នាក់ងារកាសែតរបស់រាជរដ្ឋាភិបាល ដែលឥឡូវគេស្គាល់ថា AKP ។ រហូតដល់ឆ្នាំ១៩៩៣ គាត់បានចាកចេញពី SPK ហើយបានក្លាយជានិពន្ធនាយករងនៅកាសែតរស្មីកម្ពុជា ដែលសព្វថ្ងៃនេះជាកាសែតនាំមុខគេនៅប្រទេសកម្ពុជា ។

នៅពេលដែលគាត់ចាប់ផ្ដើមធ្វើការឲ្យរស្មីកម្ពុជា គាត់ត្រូវបានគេបញ្ជូនទៅកាន់ប្រទេសថៃជាមួយអ្នកធ្វើការជនជាតិកម្ពុជា២៦ នាក់ផ្សេងទៀត ហើយ ត្រូវទទួលខុសត្រូវក្នុងការបោះពុម្ពកាសែតរស្មីកម្ពុជានៅទីនោះ។ កាសែតរស្មីកម្ពុជាត្រូវបានបញ្ជូនមកកាន់កម្ពុជាតាមយន្តហោះមកពីប្រទេសថៃ ។

នៅអំឡុងឆ្នាំ១៩៨៨ គេបញ្ជូនគាត់ឲ្យទៅចូលរួមវគ្គកាសែត៣ខែ នៅវិទ្យាស្ថានអន្តរជាតិមួយ នៅទីក្រុងប៊ុដាប៉េស ប្រទេសហុងគ្រី ។ នៅឆ្នាំ២០០២ គាត់

បង្កើតក្លឹបអ្នកកាសែតកម្ពុជាជាមួយលោកប៉ែនសមិទ្ធិ លោករាជសម្បត្តិ លោកកែ មុន្និត នឹង លោកសយ សុភាព ហើយសព្វថ្ងៃនេះគាត់គឺជាលេខាធិការរបស់ក្លឹប ។ គាត់បាននិយាយថា ជីវិតរបស់គាត់បែងចែកដំណាក់កាលពីរធំៗ ទីមួយគឺធ្វើជាអ្នកកាសែតនៅក្រោមរបបកុម្មុយនីស្ត និងទីពីរជានិពន្ធនាយកដែលមានសិទ្ធិសេរីភាពនៅក្នុងទីផ្សារប្រព័ន្ធផ្សព្វផ្សាយធំទូលាយជាងមុន ។

## ការអធិប្បាយ ៖ សេរីភាពសារព័ត៌មានចំពោះទស្សនៈក្នុងតំបន់

"ជាទូទៅក្នុងអតីតកាលអ្នកកាសែតមិនទៅរៀន ដើម្បីក្លាយជាអ្នកកាសែតនោះទេ។ ជាមួយនឹងបទពិសោធន៍និងការចូលរួមរបស់ខ្ញុំនៅក្នុងវគ្គសិក្សាខ្លីៗ ខ្ញុំបានក្លាយជាអ្នកកាសែត ។"

"ខ្ញុំគិតថា ទស្សនាវដ្តីនៅកម្ពុជាមានសេរីភាពជាងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត ព្រោះយើងអាចនិយាយអ្វីដែលយើងចង់និយាយ។ សិទ្ធិសេរីភាពនៃការបញ្ចេញមតិនេះ គឺជាផ្លែផ្កានៃប្រជាធិបតេយ្យ ។"

"ខ្ញុំបានអានរបាយការណ៍ធ្វើដោយអ្នកកាសែតគ្មានព្រំដែន ដែលចាត់ទុកកម្ពុជាក្នុងចំណាត់ថ្នាក់ទី១២៦ ក្នុងចំណោម១៧៣ប្រទេសទាក់ទងនឹងសេរីភាពសារព័ត៌មាន។ យើងមានការធ្លាក់ចុះ ប៉ុន្តែនៅតំបន់អាស៊ីអាគ្នេយ៍ យើងបានជាប់ចំណាត់ថ្នាក់លេខ ៣ បន្ទាប់ពីថៃលេខ ២ និង ឥណ្ឌូនេស៊ីលេខ១ ។"

"ខ្ញុំសង្កេតឃើញថាជាទូទៅប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជា មានសិទ្ធិសេរី ភាព ទោះបីជាមានការហាមប្រាមការរិះគន់ ឬបញ្ហាមួយចំនួនរវាងរាជរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយយ៉ាងណាក្តី ។ ទោះបីជាយ៉ាងណាក៏ដោយសេរីភាពដែលបានផ្តល់ឲ្យនេះគឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ស្ថានីយ៍ទូរទស្សន៍ជាច្រើនត្រូវបានគេគ្រប់គ្រង ហើយស្ថានីយ៍ទូរទស្សន៍ខ្លួនឯងផ្ទាល់ មិនបានបំពេញទំនួលខុសត្រូវក្នុងការផ្សព្វផ្សាយព័ត៌មានឡើយ ។ ភាគច្រើនព័ត៌មានដែលគេផ្សាយតាមទូរទស្សន៍ ច្រើនតែទាក់ទងនឹងការកំសាន្ត ។"

"ផលវិបាកដែលប្រព័ន្ធផ្សព្វផ្សាយនៅកម្ពុជាកំពុងប្រឈមមុខ គឺ លទ្ធភាពទទួលយកព័ត៌មានពីរាជរដ្ឋាភិបាលនៅមានកម្រិត ហើយមានការទប់ស្កាត់របស់អាជ្ញាធរកម្ពុជា នៅពេលអ្នកកាសែតចង់រាយការណ៍ពីបញ្ហាណាមួយ។ ក្លឹបអ្នកកាសែតកំពុងទាមទារនូវការពន្យល់យ៉ាងលម្អិតថា តើអ្នកកាសែតអាចទទួលបានព័ត៌មានពីរាជរដ្ឋាភិបាលក្នុងកម្រិតណា? អ្នកកាសែតទាំងអស់ ពិតជាយល់ដឹងអំពីពាក្យថា សន្តិសុខជាតិ ។"

"ចំណុចខ្លាំងរបស់ប្រព័ន្ធផ្សព្វផ្សាយសព្វថ្ងៃនេះ គឺអ្នកកាសែតជាច្រើនប្រកាន់វិជ្ជាជីវៈជាងមុន ដោយមានបុរេភព ការដកស្រង់សម្តី ការពិពណ៌នានិងការប្រៀបធៀបត្រឹមត្រូវ។ វគ្គបណ្តុះបណ្តាលខ្លីៗបន្ថែមទៀតត្រូវបានផ្តល់ដល់អ្នកកាសែតជារៀងរាល់ឆ្នាំ។ មិនត្រឹមតែប៉ុណ្ណោះទេ សេរីភាពប្រព័ន្ធផ្សព្វផ្សាយ ឬការបញ្ចេញមតិត្រូវបានផ្លាស់ប្តូរដោយនយោបាយនៅក្នុងប្រទេស ។ រដ្ឋាភិបាលក៏បានធ្វើការកែទម្រង់ល្អៗជាច្រើន ។"

"យ៉ាងណាមិញ ចំណុចខ្សោយគឺស្ថានភាពជីវភាពរស់នៅរបស់អ្នកកាសែត ។ ទីផ្សារព័ត៌មាននៅតូចនៅឡើយ។ ប្រាក់ខែទាបបានធ្វើឲ្យអ្នកកាសែតទទួលសំណូកដើម្បីផ្គត់ផ្គង់ក្រុពះគ្រួសារគេ។មិនតែប៉ុណ្ណោះ អតិផរណា នៅក្នុងប្រទេសធ្វើឲ្យជីវិតរស់នៅរបស់អ្នកកាសែតកាន់តែមានភាពយ៉ាប់យ៉ឺនដូចអ្នកដទៃ ឬជាងអ្នកដទៃទៅទៀត។ ទន្ទឹមនឹងនោះសម្លេងរបស់កាសែត ប្រឆាំងកាន់តែខ្សោយទៅៗ មិនដូចក្នុងអំឡុងពេលពីឆ្នាំ១៩៩៤ ដល់ ១៩៩៧ ទេ។"

## លោកម៉ម សូណង់ដូ ប្រធានវិទ្យុសំបុកឃ្មុំ FM 105 MHz

បន្ទាប់ពីរស់នៅក្នុងប្រទេសបារាំងអស់មួយរយៈ ដោយប្រកបមុខរបរជាឱចេ លោកម៉ម សូណង់ដូ មកកាន់ប្រទេសកម្ពុជា ហើយបន្ទាប់មកបង្កើតស្ថានីយ៍វិទ្យុសំបុកឃ្មុំនៅឆ្នាំ១៩៩៦ គាត់បានអះអាងថាវិទ្យុសំបុកឃ្មុំជាវិទ្យុមួយក្នុងចំណោមវិទ្យុដែលមានប្រជាប្រិយភាពបំផុតនៅក្នុងប្រទេសកម្ពុជា ដែលមានអ្នកស្តាប់ឡើង

ដល់ប្រមាណជា ១០០០ នាក់ ក្នុងពេលវេលាមួយ ក្នុងមួយថ្ងៃៗ។ គាត់បានហៅវិទ្យុរបស់គាត់ថាជាស្ថានីយ៍វិទ្យុស្នេហាជាតិ ដែលធ្វើឲ្យលោកម៉ម សូណង់ដូ កាន់តែមានបញ្ហា កាន់តែមានប្រជាប្រិយ ។ នៅឆ្នាំ១៩៩៨ ស្ថានីយ៍វិទ្យុរបស់គាត់ស្ទើរតែដួលរលំ ប៉ុន្តែដោយសារតែការបរិច្ចាកពីអ្នកស្តាប់ វិទ្យុនេះអាចផ្សាយម្តងទៀត ។ គាត់បានជាប់ក្នុងពន្ធនាគារពីរដង ។ លើកទីមួយ គាត់ត្រូវបានគេចោទប្រកាន់ថាបានញុះញង់បង្កឲ្យមានកូដកម្មប្រឆាំងថៃនៅភ្នំពេញ ឆ្នាំ២០០៣ នៅពេលស្ថានទូតថៃត្រូវបានបំផ្លាញដោយបាតុករកម្ពុជា ។ នៅឆ្នាំ២០០៥ គាត់ត្រូវបានដាក់ទោសឲ្យជាប់ឃុំឃាំងពីបទផ្សាយព័ត៌មានមិនពិតអំពីការសម្ភាសជាមួយសកម្មជនដែលរិះគន់សន្ធិសញ្ញាព្រំដែនថ្មីជាមួយប្រទេសវៀតណាម ។ ហើយស្ថានីយ៍វិទ្យុរបស់លោកបានលក់ម៉ោងផ្សាយទៅឲ្យអង្គការក្រៅរដ្ឋាភិបាលជាច្រើន ដែលបានផ្សព្វផ្សាយពីការងាររបស់គេ ហើយបានលក់ទៅឲ្យកម្មវិធីផ្សាយព័ត៌មានដែលមានការឧបត្ថម្ភដោយរដ្ឋាភិបាលអាមេរិកដូចជា វិទ្យុអាស៊ីសេរី និងសម្លេងសហរដ្ឋអាមេរិក ។

## ការអធិប្បាយ ៖ ប្រព័ន្ធផ្សព្វផ្សាយជាលក្ខណៈ សុនខឃ្លាំមើល ឬ សុនខឆ្កួត

"សេរីភាពប្រព័ន្ធផ្សព្វផ្សាយអាស្រ័យទៅនឹងមនុស្សរាល់គ្នាដែលផ្តល់តម្លៃដល់ប្រព័ន្ធផ្សព្វផ្សាយ។ បើសិនជាអ្នកចង់ឮព័ត៌មានស៊ីជម្រៅ អ្នកត្រូវការប្រព័ន្ធផ្សព្វផ្សាយដើម្បីប្រាប់អ្នក ។"

"ជាការពិតណាស់ឥឡូវនេះស្ថានភាពប្រព័ន្ធផ្សព្វផ្សាយ គឺប្រសើរជាងមុន ប៉ុន្តែនៅកម្ពុជាបើយើងសរសេររឿងដែលប៉ះពាល់ដល់ចំណុចខ្សោយរបស់អ្នកមានអំណាច ពួកគេមានសិទ្ធិដាក់គុកយើង ។"

"ខ្ញុំគាំទ្រសម្តេចហ៊ុន សែន សព្វថ្ងៃនេះដោយសារតែគាត់បានជម្រុញការអភិវឌ្ឍនៅក្នុងប្រទេស ប៉ុន្តែបញ្ហាសង្គមក៏កាន់តែដុនដាប ។ គាត់ប្រហែលជាត្រូវខំប្រឹងធ្វើការបន្ថែមទៀត ដើម្បីដោះស្រាយបញ្ហាសង្គមនៅក្នុងប្រទេសផងដែរ ។"

"ខ្ញុំរីករាយនឹងការប្រកួតប្រជែងរបស់វិទ្យុ។ កាលណាវិទ្យុកាន់តែបង្កើត

ឡើងច្រើន វាកាន់តែល្អប្រសើរ ។ ដូច្នេះហើយខ្ញុំគិតថាវិធីល្អមួយ ដើម្បីជំរុញឲ្យមានឯករាជភាពនោះគឺ ធ្វើឲ្យស្ថានីយ៍វិទ្យុទាំងនោះជារបស់ឯកជន ។"

**ឯកឧត្តម ប៊ុត បូរ៉ុត អគ្គនាយកផ្នែកព័ត៌មាននិងការផ្សព្វផ្សាយនៃក្រសួងព័ត៌មាន**

ពីឆ្នាំ១៩៨០ ដល់១៩៨៣ គាត់ធ្វើជាអ្នករាយការណ៍អោយកាសែតSPK ។ ជាទូទៅគាត់រាយការណ៍ពីនយោបាយ និងជំនួញនៅក្នុងប្រទេស។ នៅឆ្នាំ១៩៨៥ គាត់ក្លាយទៅជាអ្នកអធិប្បាយដំណឹងក្នុងប្រទេសអោយSPK។ នៅឆ្នាំ១៩៨៧ រដ្ឋា-ភិបាលបានតំឡើងតំណែងគាត់ធ្វើជាអនុប្រធានដំណឹងរបស់SPK។ នៅឆ្នាំ១៩៨៩ គាត់បានក្លាយទៅជានាយករងនៅSPK ដែលពេលនោះក៏បានបោះពុម្ពទស្សនាវដ្ដីមួយឈ្មោះថាកម្ពុជាដែលជាការឃោសនារបស់រដ្ឋាភិបាលកាន់អំណាចនៅពេលនោះ ហើយបានបោះពុម្ពផ្សាយជាបីភាសា គឺភាសាអង់គ្លេស បារាំង និងខ្មែរ ។

សព្វថ្ងៃនេះ ទំនួលខុសត្រូវរបស់គាត់នៅក្រសួងព័ត៌មានគឺ ត្រួតពិនិត្យប្រព័ន្ធផ្សព្វផ្សាយដើម្បីជំរុញការផ្សាយអោយមានការពិតត្រឹមត្រូវ ។

**ការអធិប្បាយ ៖ ការដាក់ច្បាប់លើប្រព័ន្ធផ្សព្វផ្សាយ**

"ច្បាប់សារព័ត៌មានរបស់យើង គឺគ្រាន់បើជាងអ្នកដទៃដោយសារតែវាទប់ស្កាត់ព័ត៌មានដែលប៉ះពាល់ដល់ស្ថេរភាពសង្គម និង ទប់ស្កាត់មាតិកាដែលអសីលធម៌ ។"

ខ្ញុំគិតអំពីការដាក់ច្បាប់លើអ៊ីនធឺណែតនៅកម្ពុជា គឺគ្រាន់បើជាងប្រទេសជិតខាងរបស់យើង ។ ប្រទេសកម្ពុជាមានទូរទស្សន៍ខ្សែកាបជាង ១០០ ប៉ុស្ដិ៍ ដែលមិនទទួលនូវការហាមប្រាមការរិះគន់ទាល់តែសោះ ដោយសារយើងមិនត្រួតពិនិត្យ ។

ប្រទេសរបស់យើងត្រូវការស្ថេរភាព នឹងការរៀបចំឲ្យបានត្រឹមត្រូវ ជាពិសេសគឺច្បាប់សារព័ត៌មាន ដែលត្រូវបង្កើតដោយអ្នកជំនាញការពីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល។ កាសែតនៅប្រទេសកម្ពុជាកម្រនឹងរកប្រាក់ចំណេញ

បានណាស់ មានតែពីរបីប៉ុណ្ណោះដែលអាចធ្វើបាន ។ កាសែតទាំងនោះមិនបាន បោះពុម្ពជាទៀងទាត់ឡើយ ។ ប៉ុន្តែខ្ញុំគិតថាពួកគេនឹងមានការប្រកួតប្រជែងមួយជាមួយនឹងប្រព័ន្ធអ៊ីនធឺណែតដែលជាប្រព័ន្ធផ្សព្វផ្សាយថ្មីមួយសម្រាប់យុវជនជំនាន់ក្រោយ ។

"ច្បាប់បរិហារកេរ្តិ៍ត្រូវបានផ្លាស់ប្តូរ ប៉ុន្តែច្បាប់ស្តីពីការផ្តល់ព័ត៌មានខុស នៅតែជាបទឧក្រិដ្ឋ ហើយអ្នកកាសែតត្រូវតែគោរពអាជីពរបស់ខ្លួនដើម្បីចៀសវាងនូវការចោទប្រកាន់ ។"

"ដំបូន្មានរបស់ខ្ញុំសម្រាប់អ្នកកាសែតដើម្បីការពារខ្លួន គឺថាពួកគេត្រូវតែស្វែងយល់ពីច្បាប់សារ ព័ត៌មានបន្ថែមទៀត ក៏ដូចជាត្រូវយល់ដឹងពីវិជ្ជាជីវៈរបស់ខ្លួន ដោយសារតែជាទូទៅច្បាប់គឺជាអន្ទាក់ដែលទាមទារឲ្យយើងគោរព និងយល់ដឹង ។"

## លោក មាស គីមសួន ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលព័ត៌មាន

ទទួលបានសញ្ញាប័ត្រជា វេជ្ជបណ្ឌិតមានចំណាប់អារម្មណ៍ខាងព័ត៌មាន ។ គាត់ក្លាយទៅជាប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលសារព័ត៌មាន នៅក្រសួងព័ត៌មានចាប់តាំងពីឆ្នាំ២០០៦ ។ គាត់ទទួលខុសត្រូវខាងរៀបចំកម្មវិធីសិក្សាទៅលើប្រព័ន្ធបោះពុម្ព ទូរទស្សន៍ វិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយថ្មី ។ នាយកដ្ឋានរបស់លោកបានផ្តល់វគ្គបណ្តុះបណ្តាលបួនដងរួចមកហើយពីឆ្នាំ ២០០៦ ដល់ ២០០៩ ហើយគាត់បានអញ្ជើញអ្នកកាសែតពីតាមខេត្តមកចូលរួម។ វគ្គបណ្តុះបណ្តាលនេះត្រូវបានឧបត្ថម្ភដោយយូនីស្កូ និង វិទ្យាស្ថានអាស៊ីប៉ាស៊ីហ្វិកនៃការអភិវឌ្ឍការផ្សាយ ។

## ការអធិប្បាយ ៖ ផលវិបាកក្នុងការបណ្តុះបណ្តាលខាងប្រព័ន្ធផ្សព្វផ្សាយ

"យើងមិនមានគ្រូគ្រប់គ្រាន់សម្រាប់បណ្តុះបណ្តាលទេហើយយើងពិត ជាខ្វះខាតនូវអ្នកប្រឹក្សាខាងផ្នែកសារព័ត៌មានសព្វថ្ងៃនេះ។ យើងក៏មានគំរោងដើម្បីទំនាក់ទំនងសាលាសារព័ត៌មាននៅក្រៅប្រទេសដើម្បីសហការគ្នា ។"

## លោក មឿន ឈានណារិទ្ធ អ្នកបណ្តុះបណ្តាលខាងសារព័ត៌មាន

ក្រោយពីបានទទួលការបណ្តុះបណ្តាលខាងផ្នែកសារព័ត៌មានពីUNTAC លោកណារិទ្ធ បានចាប់ផ្តើមអាជីពជាអ្នកកាសែតភ្នំពេញប៉ុស្តិ៍នៅឆ្នាំ១៩៩២ ។ គាត់បានរៀនកាសែតនៅប្រទេសថៃ ឡាវ ហ្វីលីពីន ស៊ុយអែដ និង សហរដ្ឋអាមេរិក ។ បន្ទាប់ពីចាកចេញពីកាសែតភ្នំពេញប៉ុស្តិ៍ លោកណារិទ្ធធ្វើការជាអ្នកបណ្តុះបណ្តាលសារព័ត៌មានឲ្យអង្គការអន្តរជាតិឈ្មោះ Internews ដែលបណ្តុះបណ្តាលអ្នកសារព័ត៌មាន ប៉ុន្តែ Internews បានឈប់ដំណើរការនៅកម្ពុជាតាំងពីឆ្នាំ២០០៨ ។ គាត់ល្បីខាងការរាយការណ៍ពីបញ្ហាសុខភាព សង្គម ទាក់ទងនឹងជំងឺអេដ៍ជាដើម ។

## ការអធិប្បាយ ៖ អតីតកាល និង បច្ចុប្បន្នកាល

"កាលពីអតីតកាល អ្នកកាសែតមានការលំបាកក្នុងការធ្វើការណាស់ ពីព្រោះអ៊ីនធឺណែតមិនទាន់មានការប្រើប្រាស់នៅឡើយ។ គ្រាន់តែរកព័ត៌មានទាក់ទងនឹងប្រវត្តិបន្តិចបន្តួចក៏ពិបាកដែរមុនពេលយើងត្រូវសម្ភាសន៍អ្នកណាម្នាក់ ។ ហើយអ្វីដែលពិបាកនោះគឺការសុំសម្ភាសន៍គេ ។"

"ទោះបីក្រោយការបោះឆ្នោតប្រជាធិបតេយ្យឆ្នាំ១៩៩៣ កម្ពុជានៅតែទទួលឥទ្ធិពលពីការិយាធិបតេយ្យយ៉ាងខ្លាំង ដូច្នេះហើយមន្ត្រីមានឋានៈខ្ពស់មួយចំនួន គឺមិនងាយស្រួលសុំសម្ភាសន៍ឡើយ ។ ពួកគេមិនគិតថានេះជាទំនួលខុសត្រូវរបស់គេក្នុងការនិយាយជាមួយអ្នកកាសែតទេ ។ ពួកគេបែរជាគិតថាវាជាជម្រើសផ្ទាល់ខ្លួនទៅវិញ ថាតើត្រូវនិយាយ ឬ មិននិយាយជាមួយយើង ។"

"ពេលនោះយើងមានច្បាប់សារព័ត៌មានមួយ ដែលអ្នកកាសែតត្រូវទទួលការឆ្លើយតបពីមន្ត្រីរដ្ឋាភិបាលអំឡុងពេល៣០ ថ្ងៃ ប៉ុន្តែច្បាប់នោះមិនបានដាក់ទោស ឬ មានចន្លោះខ្វះខាតត្រង់ចំណុចថា មន្ត្រីរដ្ឋាភិបាលមានសិទ្ធិមិនបាច់ឆ្លើយតប ។"

"បញ្ហាមួយទៀតគឺវប្បធម៌នៃនិទណ្ឌភាព។ ជនដៃដល់មិនត្រូវបានគេចាប់

ខ្លួនក្រោយពីសម្លាប់អ្នកកាសែត ដូច្នេះហើយវាធ្វើឲ្យអ្នកកាសែតកម្ពុជាទាំងអស់មានការខ្វល់ខ្វាយយ៉ាងខ្លាំងដោយសារតែវប្បធម៌នៃនិទណ្ឌភាពនៅកម្ពុជា ។"

សព្វថ្ងៃនេះសារព័ត៌មានមានភាពប្រសើរជាងមុន ដោយសារមន្ត្រីរាជការជាច្រើនបានចាប់ផ្តើមសហការជាមួយអ្នកកាសែត ។ ហើយភាពងាយស្រួលមួយទៀតគឺប្រព័ន្ធអ៊ីនធឺណែតបានសម្រួលកិច្ចការងារ និង ជីវិតរស់នៅរបស់យើង ។

ការអភិវឌ្ឍដែលខ្ញុំសង្កេតឃើញមកទល់សព្វថ្ងៃនេះ គឺការយល់ដឹងពីប្រជាធិបតេយ្យ និងសេរីភាពសារព័ត៌មានក្នុងចំណោមមន្ត្រីរដ្ឋាភិបាលកម្ពុជាមានការកើនឡើង។ ចំណុចទីពីរគឺការសហការរបស់យើងជាមួយនឹងមន្ត្រីក៏កាន់តែប្រសើរដោយសារតែប្រភពរបស់យើងចាប់ផ្តើមជឿទុកចិត្ត និង ដោយសារអ្នកកាសែតទាំងឡាយកាន់តែគោរពវិជ្ជាជីវៈរបស់ខ្លួន ដូចជាសរសេរគ្មានភាពលំអៀង និងគោរពក្រមសីលធម៌ ។

## ការអធិប្បាយ ៖ ការគំរាមកំហែងទៅកាន់អ្នកកាសែត

"មានអ្នកកាសែតជាច្រើនមកពីប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ទទួលបានការគំរាមកំហែងជាច្រើន។ ឧទាហរណ៍អ្នកកាសែតម្នាក់មកពីកម្មវិធីវិទ្យុមួយ រាយការណ៍ពីរបាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាលមួយ អំពីការកាប់ព្រៃឈើខុសច្បាប់ តាមការពិតជាអ្នកកាសែតពួកយើងត្រូវជឿជាក់លើរបាយការណ៍ ប៉ុន្តែត្រូវតែអះអាងវាម្តងទៀតដើម្បីការពិត ។"

"យើងត្រូវតែធ្វើការងារអោយមានវិជ្ជាជីវៈត្រឹមត្រូវ ហើយមុនពេលរាយការណ៍ពីព័ត៌មានរសើបដែលជះឥទ្ធិពលដល់សុវត្ថិភាពរបស់យើង យើងត្រូវតែមើលថាតើដំណឹងនោះនឹងយកជីវិតយើងរឺអត់?"

"បើសិនជារឿងនោះជះឥទ្ធិពលដល់សុវត្ថិភាព ប្រហែលជាយើងត្រូវលះបង់វា ឬបើសិនជាវាមានសារសំខាន់ យើងគួរផ្តល់វាអោយដល់សារព័ត៌មានអន្តរជាតិ។ ម៉្យាងទៀត បើសិនជាកាសែត៥បោះពុម្ពផ្សាយរឿងតែមួយដូចគ្នាក្នុង

ពេលតែមួយ នោះវានឹងកាត់បន្ថយការប្រថុយប្រថានចំពោះ អ្នកកាសែត។ "

## អ៊ុង ចាន់សុភា, កាសែតកំបូដស្ទ័រ និង វិទ្យុបារាំងអន្តរជាតិ

កញ្ញាសុភា រាយការណ៍អោយកាសែតកំបូដស្ទ័រ ជាកាសែតភាសាបារាំងនៅកម្ពុជា ហើយជាអ្នកកាសែតអោយវិទ្យុបារាំងអន្តរជាតិ សុភារៀនភាសាបារាំងនៅសកលវិទ្យាល័យភ្នំពេញ ហើយបន្ទាប់ពីរៀនភាសាអង់គ្លេសបានល្អ សុភារៀនសារព័ត៌មានអស់រយៈពេល ២ឆ្នាំ នៅសកលវិទ្យាល័យ។

គាត់ច្រើនរាយការណ៍ពីដំណឹងសង្គម និងនយោបាយ ។ នៅឆ្នាំ២០០៧ គាត់ទទួលបានការបណ្តុះបណ្តាលសារព័ត៌មាននៅប្រទេសថៃអស់រយៈពេលមួយឆ្នាំ តាមរយៈកម្មវិធីសារព័ត៌មានមួយរបស់មូលនិធិ Indochina Media Memorial ។ នៅឆ្នាំ២០០៨ គាត់ត្រូវបានផ្តល់រង្វាន់ខាងការងារក្នុងសារព័ត៌មានស៊ើបអង្កេតនៅក្នុងកម្មវិធីដែលរៀបចំដោយទូតអាមេរិក និង ក្លឹបអ្នកកាសែតកម្ពុជា។

## ការអធិប្បាយ ៖ ស្ត្រី ក្នុងការងាររបស់មនុស្សប្រុស

"ខ្ញុំត្រូវបានគេរើសអើងនៅពេលរាយការណ៍លើរឿងនយោបាយ ដោយទាំងអ្នកកាសែតប្រុសៗ និងអាជ្ញាធរកម្ពុជា។ ពួកគេនិយាយថា ខ្ញុំគួររាយការពីការកំសាន្ត និងដំណឹងសង្គមដែលសមរម្យសំរាប់ស្ត្រី ប៉ុន្តែមិនមែនដំណឹងនយោបាយទេ។"

ខ្ញុំយល់ឃើញថាមានការរីកចំរើនខាងផ្នែកសេរីភាពសារព័ត៌មាន។ អ្នកកាសែតឥឡូវអាចទទួលប្រតិកម្ម ឬដំណឹងបានពីមន្ត្រីរាជការ។ ពួកគេអាចផ្តល់ព័ត៌មានខ្លះៗដែលយើងត្រូវការ ហើយហ៊ានឆ្លើយសំណួររបស់យើងជាអ្វីដែលគេមិនធ្លាប់ធ្វើពីមុនជាពិសេស៣ទៅ៤ ឆ្នាំមុន ។

ខ្ញុំឃើញអ្នកកាសែតមួយចំនួនទទួលយកសំណូក ដោយសារពួកគេត្រូវការផ្គត់ផ្គង់គ្រួសាររបស់គេ។ វិទ្យាស្ថានប្រព័ន្ធផ្សព្វផ្សាយមួយចំនួនគួរតែផ្តល់ប្រាក់ខែដ៏

សមរម្យមួយសំរាប់អ្នកកាសែត ដូច្នេះពួកគេអាចសរសេរព័ត៌មានដែលមានតុល្យភាព និងមានអព្យាក្រឹត។

**សយ សុភាព, ទូរទស្សន៍ CTN**

លោក សយ សុភាព ធ្វើជាអ្នករាយការណ៍ព័ត៌មានអោយទូរទស្សន៍ CTN ចាប់តាំងពីឆ្នាំ ២០០៤ មកម្ល៉េះ។ ពីមុនលោកធ្វើជាអ្នកកាសែតអោយទីភ្នាក់ងារសារព័ត៌មាន Kyodo របស់ជប៉ុនជាភាសាអង់គ្លេស។ គាត់ត្រូវបានគេស្គាល់ពីទស្សនៈចំៗរបស់គាត់ ហើយមនុស្សជាច្រើននិយាយថា គាត់តែងធ្វើការរាយការណ៍គាំទ្ររាជរដ្ឋាភិបាលខ្មែរ ។

ថ្មីៗនេះលោកសុភាព ជាអ្នកផ្សះផ្សារវាងព្រះអង្គម្ចាស់ នរោត្តម រណឫទ្ធ និងនាយករដ្ឋមន្ត្រី ហ៊ុន សែន នៅឆ្នាំ២០០៨ ដែលធ្វើអោយមានការជជែកវែកញែកក្នុងចំណោមអ្នកកាសែតថា តើពួកគេគួរចូលរួមក្នុងព្រឹត្តិការណ៍នយោបាយបែបណា។

**ការអធិប្បាយ៖**

ចំពោះខ្ញុំមិនខ្វាយខ្វល់ចំពោះអ្នកដទៃគេថាយ៉ាងម៉េចនោះទេ ពីការគាំទ្ររបស់ខ្ញុំចំពោះរាជរដ្ឋាភិបាល ប៉ុន្តែខ្ញុំគិតអំពីប្រទេសរបស់ខ្ញុំហើយខ្ញុំចង់ជួយប្រទេសអោយកាន់តែមានការអភិវឌ្ឍថែមទៀត ។

នៅក្នុងជំលោះរឿងព្រះវិហារ ខ្ញុំព្យាយាមរាយការណ៍អោយអស់ពីសមត្ថភាពហើយខ្ញុំមានមោទន ភាពធ្វើជាខ្មែរ ។

បើសិនជាអ្នកកាសែតទទួលលុយពីសន្និសីទកាសែត ឬការប្រជុំនោះ ពួកគេមិនខុសទេ។ អ្នកកាសែតអាចយកលុយនោះ ប្រសិនបើក្រុមទាំងនោះស្ម័គ្រចិត្តនឹងអោយគ្មានការបង្ខិតបង្ខំ។ វាមិនជាបញ្ហាអ្វីទេ ពីព្រោះអ្នកកាសែតទាំងនោះមិនគំរាមអ្នកដទៃដើម្បីយកប្រាក់។

ទោះបីជានរណានិយាយពីគោលការណ៍នេះក៏ដោយ មានតែនាយក

រដ្ឋមន្ត្រីហ៊ុន សែនទេ ដែលអាចធ្វើអោយប្រទេសកម្ពុជាមានការផ្លាស់ប្តូរ ។ នៅពេលខ្ញុំឃើញអ្នកដឹកនាំល្អ ខ្ញុំសរសើរអ្នកដឹកនាំនោះ។

## ស៊ិន សុផាត ប៉ុស្តិ៍លេខ៥

លោក ស៊ិន សុផាតបានធ្វើជាអ្នកកាសែតយោធាអោយវិទ្យុរដ្ឋអស់រយៈពេលច្រើនឆ្នាំពីឆ្នាំ១៩៧៩ដល់ ១៩៩៣ ហើយល្បីខាងការរាយការណ៍អំពីសង្គ្រាមរវាងរាជរដ្ឋាភិបាល និងខ្មែរក្រហម។ សព្វថ្ងៃនេះគាត់ជាអ្នកគ្រប់គ្រងនៅប៉ុស្តិ៍លេខ ៥ ហើយតែងផ្តល់នូវវីដេអូទាក់ទងនឹងយោធាទៅអោយទូរទស្សន៍ដទៃ ឬអ្នកដែលចង់បាន។ នៅប៉ុស្តិ៍លេខ៥ មាតិកាដែលរសើបត្រូវត្រួតពិនិត្យមើលដោយលោក ស៊ិន សុផាត មុនពេលចាក់ផ្សាយ ដោយលោកបានអះអាងថាដំណឹងអាទិភាពគឺ ដំណឹងទាក់ទងទៅនឹងកងយោធពលខេមរភូមិន្ទ។ លោក សុផាត ធ្លាប់ចូលរួមការបណ្តុះបណ្តាលនៅប្រទេស សឹង្ហបុរី និង ប្រទេស វៀតណាម ហើយធ្លាប់បង្រៀនកាសែតដោយ លោក ខៀវ កញ្ញារិទ្ធ ពីមុន។

## ការអធិប្បាយ៖ ការរាយការណ៍ក្នុងសង្គ្រាម

អ្នកកាសែតមួយចំនួនត្រូវគេហៅថា អ្នកកាសែតជើង ៦ ពីព្រោះពួកគេមិនទៅយកដំណឹងទេ។ តាមពិតពួកគេបែរជាទៅអង្គុយនៅក្នុងការិយាល័យ ហើយសរសេររឿងទៅវិញ។ អ្នកកាសែតគួរសរសេរព័ត៌មានអោយស៊ីជម្រៅ ហើយពួកគេគួរតែបង្កើតមិត្តជាមួយប្រភពរបស់គេ មិនមែនធ្វើជាសត្រូវនោះទេ។

សារព័ត៌មានសព្វថ្ងៃនេះ គឺមានសិទ្ធិសេរីភាពពីព្រោះកាសែតឥឡូវអាចរិះគន់រាជរដ្ឋាភិបាលបាន។ ឥឡូវប្រព័ន្ធផ្សព្វផ្សាយក៏មានភាពក្លាហានក្នុងការសរសេររឿងទូទាំងប្រទេស។ ទោះជាយ៉ាងណាអ្នកកាសែតគួរទទួលខុសត្រូវចំពោះអ្វីដែលគេសរសេរ រឺ និយាយ។

**ឯក ហុង អេហ្សអេម ១០២**

បន្ទាប់ពីទទួលបានបរិញ្ញាប័ត្រផ្នែកទីផ្សារមកពីវិទ្យាស្ថានជាតិគ្រប់គ្រងបច្ចុប្បន្នជាសកលវិទ្យាល័យជាតិគ្រប់គ្រង និងសញ្ញាប័ត្រកាសែតមកពីសកលវិទ្យាល័យភូមិន្ទភ្នំពេញមក ឯក ហុង ស្ម័គ្រចិត្តធ្វើជាអ្នកកាសែតអោយមណ្ឌលព័ត៌មានស្ត្រីកម្ពុជា ១០២។

នៅឆ្នាំ២០០៦គាត់ក្លាយទៅជាអ្នកផលិតកម្មវិធីផ្សាយឈ្មោះថា ជាតិស្ត្រី ដែលផ្តោតលើសុខភាពបន្តពូជរបស់ស្ត្រី ។ ថ្មីៗនេះគាត់ធ្វើការលើកម្មវិធីឯកសារវិទ្យុឈ្មោះថាការកាន់តែយល់ច្បាស់ពីធនាគារពិភពលោក ភេទនិងការអភិវឌ្ឍ។

**ការអធិប្បាយ៖ ការគំរាមកំហែងនិងទំនួលខុសត្រូវក្នុងផ្នែកសារព័ត៌មាន**

ស្ថានីយ៍វិទ្យុភាគច្រើនមិនសូវមានតុល្យភាពទេ ហើយសឹងតែទាំងអស់សុទ្ធសឹងផ្តោតទៅលើការរកស៊ី និងមានទំនាក់ទំនងនយោបាយ ។

ស្ថានីយ៍វិទ្យុភាគច្រើនក៏មិនហ៊ានផ្សាយព័ត៌មានរសើប ឬដំណឹងដែលប៉ះពាល់រាជរដ្ឋាភិបាលដែរ។ បើសិនមនុស្សម្នាក់ចង់រាយការណ៍ពីរឿងរសើបណាមួយដូចជា អំពើពុករលួយនោះពួកគេត្រូវតែច្បាស់លាស់អំពីអ្វីដែលពួកគេសរសេរ ។ ជាងនេះទៅទៀតពួកគេត្រូវតែមានតុល្យភាពដោយព្យាយាមយកដំណឹងពីគ្រប់ប្រភពទាំងអស់ ។

ខ្ញុំមិនដែលទទួលការគំរាមកំហែងពីខាងណាឡើយ ពីព្រោះខ្ញុំតែងតែព្យាយាមធ្វើអោយរឿងខ្ញុំច្បាស់លាស់ និងមានតុល្យភាព ។

ការគំរាមកំហែងគឺជាផលវិបាកដ៏ធំមួយ ដែលធ្វើអោយអ្នកកាសែតមិនអាចសរសេររឿងពិតប្រាកដបាន។

បើសិនជារាជរដ្ឋាភិបាលពិតជាមានសុឆន្ទៈមែន ពួកគេគួរតែពិចារណានូវចំនុចដែលរសើបទាំងឡាយដែលអ្នកកាសែតសរសេរ ហើយធ្វើការផ្លាស់ប្តូរនូវចំនុចណាដើម្បីអោយបានសមរម្យ ។

ការហាមប្រាមការរិះគន់ចំពោះខ្លួនឯងគឺមិនតែងតែអាក្រក់នោះទេ។ ជួន

កាលវាល្អចំពោះអ្នកកាសែតដែលខ្វាយខ្វល់ពីអាយុជីវិតរបស់ខ្លួន និង ប្រទេសជាតិ ដូច្នេះហើយពួកគេគួរតែរក្សាលំនឹងអោយបានល្អ ។

មន្ត្រីរាជរដ្ឋាភិបាលជាប្រភពដែលពិបាកទាក់ទងបំផុត ជាពិសេសចំពោះរឿងរសើប។

## ងួន សេរ៉ាត់ កាសែតរស្មីកម្ពុជា

លោក សេរ៉ាត់ ចាប់ផ្តើមធ្វើជាអ្នកបកប្រែអោយកាសែតរស្មីកម្ពុជា ហើយបន្ទាប់ពីទស្សនកិច្ចនៅប្រទេសជប៉ុន ដើម្បីទៅមើលស្ថានភាពប្រព័ន្ធផ្សព្វផ្សាយនៅទីនោះ ក្នុងឆ្នាំ១៩៨៨ លោកបានក្លាយទៅជាអ្នកកាសែតអោយកាសែតនោះ។

គាត់ល្បីល្បាញខាងរាយការណ៍លើការបោះឆ្នោត ហើយត្រូវបានបញ្ជូនទៅប្រទេសអាល្លឺម៉ង់រៀនពីវគ្គសិក្សាទាក់ទងនឹងការបោះឆ្នោត។ គាត់រាយការណ៍លើការបោះឆ្នោតប្រធានាធិបតីរបស់សហរដ្ឋអាមេរិកក្នុងឆ្នាំ២០០៤ អោយរស្មីកម្ពុជា។

លោក សេរ៉ាត់ ទទួលបានបរិញ្ញាប័ត្រអនុបណ្ឌិតមកពីមហាវិទ្យាល័យនៅប្រទេសហ្វីលីពីនឈ្មោះថា Ateneo de Manila ក្នុង ឆ្នាំ ២០០៩ ហើយក្លាយទៅជានិពន្ធនាយកអោយរស្មីកម្ពុជា។

## ការអធិប្បាយ ៖ ការត្រួតពិនិត្យខ្លួនឯង

ស្ថានភាពប្រព័ន្ធផ្សព្វផ្សាយនៅប្រទេសកម្ពុជាសព្វថ្ងៃនេះ គឺមានភាពប្រសើរជាងមុន ហើយមិនមានការគំរាមកំហែងមកលើអាយុជីវិតដូចពីមុនទេ។ លក្ខខណ្ឌនៃការរាយការណ៍វិញ ក៏មានការប្រសើរដូចគ្នាដែរ ដោយសារតែអ្នកកាសែតអាចសុំសម្ភាសន៍ទាក់ទងមន្ត្រីធំៗ និងអ្នកនយោបាយមួយចំនួន។ទោះបីជាយ៉ាងណាក៏ដោយ អ្នកកាសែតនៅមានការលំបាកក្នុងការស្វែងរកឯកសារផ្លូវការពីរាជរដ្ឋាភិបាល។ ហើយការខ្វះខាតខាងឯកសារទាំងនេះមានឥទ្ធិពលមិនល្អទៅលើការរាយការណ៍ព័ត៌មានស៊ើបអង្កេតរបស់អ្នកកាសែត ដោយសារតែពួកគេមិនអាចរកទិន្នន័យត្រឹមត្រូវ និងភស្តុតាងគ្រប់គ្រាន់មកអះអាង។

ជាទូទៅគេនិយាយថា ការដែលមានការហាមប្រាមខ្លួនឯងមិនអោយរិះគន់ធ្វើអោយអ្នកកាសែតបាត់បង់ស្តង់ដារវិជ្ជាជីវៈ ។ ប៉ុន្តែខ្ញុំគិតថានៅកម្ពុជា ការដែលមានការហាមប្រាមខ្លួនឯងមិនអោយរិះគន់ គឺមិនមែនសុទ្ធតែខុសនោះទេ។ យើងគួរគិតពីស្ថានភាពផ្ទាល់ខ្លួនវិញ។ ការសំរេចចិត្តតែងតែពិបាកជានិច្ច ជាពិសេសនៅពេលយើងព្យាយាមរក្សាលំនឹងរវាងវិជ្ជាជីវៈ និងជីវិតរបស់យើង។

ការហាមប្រាមខ្លួនឯងមិនអោយរិះគន់គឺមិនគួរអោយទទួលយកទេនៅពេលមនុស្សម្នាក់ធ្វើឡើងដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន។ នៅប្រទេសកម្ពុជាការហាមប្រាមខ្លួនឯងមិនអោយរិះគន់តែងតែកើតឡើង ចំពោះអ្នកកាសែតដែលត្រូវទាក់ទងជាមួយមន្ត្រីប៉ូលីស ឬទាហាន។

ការរាយការណ៍ពីវិបត្តិនានាគឺមានការរីកចំរើនជាងមុន។ យ៉ាងណា មិញអ្នកកាសែតជាច្រើននៅតែមានភាពភ័យខ្លាច នឹងការរាយការណ៍ពីរឿងមិនល្អរបស់អ្នកណាម្នាក់ដោយសារកត្តាបីគឺៈ ទីមួយអ្នកកាសែតមិនអាចទទួលបានឯកសារផ្លូវការបាន ទី២ អ្នកកាសែតក៏ត្រូវថែរក្សាអាយុជីវិតរបស់គេដែរ ទី៣ ទាក់ទងនឹងចំណេះដឹងរបស់អ្នកកាសែតទៅលើអាជីពរបស់គេ។

អ្នកកាសែតត្រូវតែគោរពការស្នើសុំរបស់ប្រភពរបស់គេ បើប្រភពនោះសុំមិនអោយបញ្ចេញអត្តសញ្ញាណរបស់ពួកគេ។ ប៉ុន្តែនៅពេលអ្នកកាសែត ព្យាយាមធ្វើដូចនោះ អ្នកកាសែតផ្ទាល់អាចត្រូវភូតភរកុហកដោយប្រភពទាំងនោះដែរ។ ដូចនេះហើយអ្នកកាសែតត្រូវត្រួតពិនិត្យឡើងវិញនូវព័ត៌មានដែលផ្តល់ដោយប្រភពទាំងនោះ។ ប៉ុន្តែការដែលមិនបញ្ចេញអត្តសញ្ញាណរបស់ប្រភពគួរតែជាជំរើសចុងក្រោយ។

បើប្រៀបធៀបជាមួយប្រទេសអាស៊ីអាគ្នេយ៍វិញ ប្រទេសកម្ពុជាមានសេរីភាពសារព័ត៌មានជាងគេ ជាពិសេសនៅពេលច្បាប់បរិហារកេរ្តិ៍ត្រូវគេដកទៅវិញ។ ប៉ុន្តែនៅមានច្បាប់មួយផ្សេងទៀតដែលទាក់ទងនឹងការផ្តល់ដំណឹងខុស។ តាមទស្សនៈរបស់ខ្ញុំច្បាប់ទាំងអស់ដែលទាក់ទងនឹងការដាក់គុកអ្នកកាសែតគួរតែលុប

ចោល ។

អ្នកកាសែតមិនគួររាយការណ៍ពីអ្វីដែលផ្អែកលើអារម្មណ៍របស់គេទេ។ បើទោះជាគេខឹងជាមួយនរណាក៏ដោយ ក៏ពួកគេមិនគួរធ្វើអោយរឿងតូចក្លាយទៅជារឿងធំ ធ្វើអោយប៉ះពាល់កេរ្តិ៍ឈ្មោះរបស់អ្នកដទៃ។

យោបល់របស់ខ្ញុំចំពោះយុវជនជំនាន់ក្រោយជាអ្នកកាសែតគឺថា ទី១អ្នកកាសែតត្រូវប្រើប្រាស់អំណាចសារព័ត៌មានដែលគេមានមកធ្វើអំពើល្អ។ ពួកគេត្រូវបង្កើតទំនុកចិត្តជាមួយទស្សនិកជន។ ទី២អ្នកកាសែតគួរព្យាយាមរាយការណ៍ឲ្យស៊ីជម្រៅលើបញ្ហានានា ហើយយកដំណឹងពីអ្នកដែលមានសម្លេងទៅដល់អ្នកមិនមានសំឡេង ឬអ្នកដែលមិនមានសំឡេងទៅដល់អ្នកមានសំឡេង។ទី៣ អ្នកកាសែតគួរទទួលបាននូវការបណ្តុះបណ្តាលអោយបានច្រើន។ ទី៤ ពួកគេត្រូវព្យាយាមសំរបខ្លួនទៅតាមបរិយាកាសផ្សេងៗអោយបាន ហើយទី៥ ពួកគេគួរតែមានចំណេះដឹងអោយបានច្រើនអំពីច្បាប់ ត្រួតពិនិត្យម្តងហើយម្តងទៀត លើដំណឹងរបស់គេរួចគិតពីផលវិបាករបស់រឿងនោះ។

## ការបណ្តុះបណ្តាលផ្នែកសារព័ត៌មាននៅតែមានកង្វះខាត ប៉ុន្តែមានការរីកចំរើនសង្ឃឹមៗ

ការបណ្តុះបណ្តាលផ្នែកសារព័ត៌មាននៅកម្ពុជា នៅតែមានកង្វះខាត ចាប់តាំងពីដើមទសវត្សឆ្នាំ៩០ ដោយមកដល់សព្វថ្ងៃនេះមានត្រឹមតែសាកលវិទ្យាល័យមួយប៉ុណ្ណោះដែលផ្តល់នូវវគ្គសិក្សាផ្នែកសារព័ត៌មាននេះ។ បើទោះបីជាកន្លងមកសហគមន៍អន្តរជាតិ បានផ្តល់ជំនួយឧបត្ថម្ភដល់វគ្គសិក្សាជាច្រើន យ៉ាងណាក៏ដោយក៏ការបណ្តុះបណ្តាលកំរិតឧត្តមសិក្សាផ្នែកសារព័ត៌មាននៅតែត្រូវការបន្ថែម ដើម្បីពង្រឹងនូវក្រមសីលធម៌ចំពោះវិស័យសារព័ត៌មាននេះ។

មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ បានឧបត្ថម្ភគាំទ្រក្នុងការបង្កើតឡើងនូវសមាគមគាំពារសារព័ត៌មាន ដោយការបង្កើតនូវក្រមសីលធម៌

ជារួមមួយ។ បញ្ហាក្រមសីលធម៌នេះក្នុងបទសម្ភាសន៍ជាមួយអ្នកសារព័ត៌មាននិងអ្នកដែលធ្វើការជាប់ទាក់ទងនឹងវិជ្ជាជីវៈមួយចំនួនកន្លងមក គឺជាសេចក្តីកង្វល់មួយរបស់ពួកគេ។

ការអប់រំវិស័យសារព័ត៌មានមានដំណើរការសន្សឹមៗ នៅកម្ពុជាក្រោមការឧបត្ថម្ភភាគច្រើនពីសហគមន៍ផ្តល់ជំនួយអន្តរជាតិ។ ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ដែលស្ថិតនៅក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ គឺជាកន្លែងតែមួយគត់ នៅក្នុងប្រទេសដែលផ្តល់នូវបរិញ្ញាប័ត្រផ្នែកប្រព័ន្ធផ្សព្វផ្សាយ។ ចំណែកឯអង្គការ និងសាកលវិទ្យាល័យដទៃទៀត ក៏មានបំណងឈោងចាប់យកនូវការបណ្តុះបណ្តាលផ្នែកសារព័ត៌មានដែលពោរពេញទៅដោយសក្តានុពលភាពទីផ្សារមួយនេះ ប៉ុន្តែពួកគេខ្វះខាតនូវធនធាន និងជំនួយ ព្រោះបច្ចុប្បន្ននេះម្ចាស់ជំនួយយកចិត្តទុកដាក់ក្នុងការជួយទៅលើវិស័យផ្សេងទៀតដូចជា វិស័យសុខាភិបាល និងវិស័យកសិកម្ម។

កាសែតមួយមានឈ្មោះថា ឃែមបូឌាញូស៍ បានផ្លាស់ប្តូរទៅជាមជ្ឈមណ្ឌលបង្រៀនផ្នែកប្រព័ន្ធផ្សព្វផ្សាយ ដោយផ្តោតជាពិសេសទៅលើការបង្វឹកបង្ហាត់មន្ត្រីសារព័ត៌មាន។ នេះគឺជាការចូលរួមមួយយ៉ាងចំបងក្នុងការបណ្តុះបណ្តាលមន្ត្រីសារព័ត៌មានដែលកំពុងតែមានតំរូវការពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសចំពោះអ្នកកាសែតដែលតែងតែត្អូញត្អែអំពីកង្វះខាតអ្នកផ្តល់ព័ត៌មានពីភាគីរដ្ឋាភិបាល។

យ៉ាងណាមិញ បើយោងតាមកិច្ចសម្ភាសន៏ជាមួយភាគីរាជរដ្ឋាភិបាលបានអោយដឹងថាខាងក្រសួងមួយចំនួនមានគំរោងបណ្តុះបណ្តាល និងបង្កើតអោយមានមន្ត្រីសារព័ត៌មានប្រចាំក្រសួងនីមួយៗ។

មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មាន នៅក្នុងក្រសួងព័ត៌មានកំពុងតែធ្វើការបង្វឹកបង្ហាត់វិជ្ជាជីវៈជំនាញដល់មន្ត្រីរបស់ខ្លួន ដែលធ្វើការនៅតាមស្ថានីយ៍វិទ្យុ និងទូរទស្សន៍នៅតាមខេត្ត។

វិបត្តិសេដ្ឋកិច្ចពិភពលោក បានបណ្តាលអោយអ្នកផ្តល់ជំនួយកាត់បន្ថយ

រីបញ្ឈប់នូវការផ្តល់ជំនួយ ដល់វិស័យប្រព័ន្ធផ្សព្វផ្សាយដែលមានទំហំតូចរបស់កម្ពុជានេះបើយោងទៅតាមប្រភពមួយចំនួន។ អ្នកផ្តល់ជំនួយមាននិន្នាការផ្តោតលើការផ្តល់ជំនួយទៅលើវិស័យធំៗ ដូចជាវិស័យកសិកម្ម នៅពេលដែលពួកគេត្រូវតែពិចារណាយ៉ាងល្អិតល្អន់ជាងមុនលើការប្រើប្រាស់កញ្ចប់ថវិកាជំនួយរបស់ពួកគេ។

ចំណែកឯមជ្ឈមណ្ឌលដទៃទៀត ត្រូវបង្ខំចិត្តក្នុងការពឹងផ្អែកលើមូលនិធិផ្ទាល់ខ្លួន ដោយការរកនូវអ្នកស្ម័គ្រចិត្ត និងរកប្រាក់ចំណូលពីការបង្រៀនផ្ទាល់ខ្លួន។ វិទ្យាស្ថានកម្ពុជាសម្រាប់ការសិក្សាផ្នែកសារព័ត៌មានដែលបាន ចាប់ផ្តើមឡើងនៅឆ្នាំ២០០៨ បន្ទាប់ពីអង្គការInternews ដែលជាអង្គការដើម បានបញ្ចប់គំរោងនៅកម្ពុជារហូតមកដល់ពេលឥឡូវ វិទ្យាស្ថានកម្ពុជាសម្រាប់ការសិក្សាផ្នែកសារព័ត៌មាននៅពុំទាន់ស្វែងរកអ្នកផ្តល់ជំនួយចំបងនៅឡើយទេ។ ហើយគោលការណ៍ក្នុងការផ្តល់ជំនួយដល់វិស័យអប់រំសារព័ត៌មាននេះក៏បានត្រូវផ្លាស់ប្តូរដែរ។ ម្ចាស់ជំនួយបានប្តូរពីការជួយឧបត្ថម្ភគាំទ្រដល់វគ្គសរសេរព័ត៌មានមូលដ្ឋាន ទៅការជួយដល់វគ្គសរសេរព័ត៌មានជំនាញ។

ដោយមានការខ្វះជំនួយ កម្មវិធីសិក្សាជាច្រើននៃមជ្ឈមណ្ឌលបណ្តុះបណ្តាលសារព័ត៌មានមួយចំនួនបានសំរេចចិត្តយកថ្លៃឈ្នួលបង្រៀន បញ្ហានេះបានធ្វើអោយអ្នកកាសែតមួយចំនួនដែលរកប្រាក់បានត្រឹមតែ៦ដុល្លារ ក្នុងមួយរឿងមិនមានលទ្ធភាពសិក្សាបាន។

ក្លឹបអ្នកកាសែតកម្ពុជាគឺជាមជ្ឈមណ្ឌលទីមួយដែលចាប់ផ្តើមយកថ្លៃឈ្នួលក្នុងវគ្គសិក្សា។ហើយដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ ក៏មានគំរោងផ្តល់នូវថ្នាក់សិក្សាឯកជនពេលយប់ដល់អ្នកសារព័ត៌មាន និងសិស្សទូទៅដែរ។

ទោះបីជាយ៉ាងនេះក៏ដោយ ទិដ្ឋភាពទូទៅនៃការអប់រំផ្នែកសារព័ត៌មាននៅកម្ពុជាកំពុងតែចាប់ផ្តើមនូវការរីកដុះដាលដ៏ធំ។ ឃែមបូឌាញូស៍ និង វិទ្យាស្ថានកម្ពុជាសម្រាប់ការសិក្សាផ្នែកសារព័ត៌មានកំពុងតែអភិវឌ្ឍន៍ខ្លួន ពីវគ្គសិក្សាខ្លីៗអោយទៅជាវគ្គសិក្សាវិជ្ជាជីវៈសារព័ត៌មានថ្នាក់ឧត្តម ខណៈពេលដែលដេប៉ាតឺម៉ង់ប្រព័ន្ធ

ផ្សព្វផ្សាយ និងសារគមនាគមន៍មានគំរោងផ្តល់វគ្គសិក្សាថ្នាក់ឧត្តមដល់ផ្នែកមន្ត្រីសារព័ត៌មាន។

ម្យ៉ាងវិញទៀត អ្នកសារព័ត៌មានកម្ពុជានៅតែមិនទាន់បង្រួបបង្រួមគ្នាជាក្រុមតែមួយនៅឡើយទេ។ សព្វថ្ងៃនេះមានសមាគមអ្នកសារព័ត៌មានចំនួន១៨ ដែលជាចំនួនដ៏ច្រើនលើសពីចំនួនសមាគមសារព័ត៌មាននៅប្រទេសដទៃទៀតនៅក្នុងទ្វីបអាស៊ី។ សមាគមដែលមានទ្រង់ទ្រាយធំជាងគេមានពីរ គឺក្លឹបអ្នកកាសែតកម្ពុជា និងសមាគមកម្ពុជាការពារអ្នកកាសែត។ សមាគមទាំងពីរនេះមានសកម្មភាពជាច្រើនក្នុងការបណ្តុះបណ្តាល និងការពារអ្នកកាសែតកម្ពុជា។ ចំនួនដ៏ច្រើននៃសមាគមសារព័ត៌មានទាំងនេះធ្វើអោយមានការ លំបាកសំរាប់អ្នកកាសែតកម្ពុជាក្នុងការទាក់ទងជាមួយគ្នាទូទាំងប្រទេស ក៏ដូចជាក្នុងតំបន់នេះបើយោងទៅតាមបទសម្ភាសន៏។

សមាគមសារព័ត៌ទាំងពីរសុទ្ធសឹងតែមានកម្មវិធីប្រហាក់ប្រហែល ក្នុងការគាំពារអ្នកកាសែតដែលប្រឈមមុខនឹងការគំរាមកំហែង ឬ ការប្តឹងផ្តល់។ ក្រៅពីសេចក្តីថ្លែងការជាសាធារណៈ ទាមទារសិទ្ធិសេរីភាពរបស់អ្នកសារព័ត៌មាន ក្លឹបអ្នកកាសែតកម្ពុជាក៏បានផ្តល់ផងដែរនូវការប្រឹក្សាផ្លូវច្បាប់ ដល់អ្នកកាសែតដែលទទួលរងពាក្យបណ្តឹង។

ការស្វែងរកការសំរបសំរួលមុនពេលតតាំងគ្នានៅតុលាការ ជាវិធីសាស្ត្រមួយដ៏ប្រសិទ្ធិភាពរបស់ក្លឹបអ្នកកាសែតកម្ពុជា ដើម្បីដោះលែងអ្នកកាសែតដែលត្រូវគេប្តឹងចោទប្រកាន់អោយចេញពីគុកជាមុនសិន មុននឹងប្រឈមមុខនឹងការសំរេចសាលក្រម។ ក្លឹបអ្នកកាសែតកម្ពុជាបានប្រើវិធីនេះ យ៉ាងមានប្រសិទ្ធិភាពក្នុងការដោះលែងលោក ដាំ សិទ្ធិ ដែលជានិពន្ធនាយកនៃកាសែតប្រឆាំងមនសិការខ្មែរ ដែលត្រូវបានចោទប្រកាន់ថាបានបោះពុម្ព នូវឃ្លាមួយប្រឆាំងនឹងលោករដ្ឋមន្ត្រីហោ ណាំហុង។ ហើយក្នុងឆ្នាំ២០០៧ ក្លឹបក៏បានផ្តល់នូវការសំរបសំរួលមួយដល់ពាក្យបណ្តឹងចោទប្រកាន់ទៅលើ ក្រុមអ្នកកាសែតមួយក្រុម ដែលចោទពីបទគំរាម

កំហែងតារាចំរៀង រ៉ាង ស្រីណូ ដោយប្រើប្រាស់វីដេអូអាសអាភាសទៅផ្សព្វផ្សាយ ។ដោយមានត្រឹមតែសមាគម អ្នកថតរូបតែមួយនៅក្នុងប្រទេសអ្នកថតរូបសារព័ត៌មាន មានធនធានបន្តិចបន្តួចក្នុងការស្វែងរក និងទទួលការការពារខណៈពេលដែលពួកគេត្រូវបំពេញ នូវកិច្ចការគ្រោះថ្នាក់មួយចំនួនដូចអ្នកសរសេរអត្ថបទកាសែតដែរ។

ចំពោះអ្នកកាសែតនៅតាមខេត្ត ពិតជាត្រូវការការបណ្តុះបណ្តាលជាច្រើន ខណៈដែលប្រាក់ចំណូលពីវិជ្ជាជីវៈរបស់ពួកគេមានមិនដល់៤០ដុល្លាក្នុងមួយខែផង ។

ម្យ៉ាងវិញទៀតអ្នកសារព័ត៌មាន គួរទទួលការលើកកំពស់ជីវភាពរស់នៅ បង្កើនប្រាក់ខែ និងបង្កើនគុណភាពវគ្គសិក្សានេះ បើយោងតាមបទសម្ភាសន៍ជាច្រើន។

## ក្លឹបអ្នកកាសែតកម្ពុជា

ក្លឹបអ្នកកាសែតកម្ពុជាត្រូវបានបង្កើតឡើងនៅខែសីហា ឆ្នាំ២០០០ បន្ទាប់ពីមានការពិភាក្សារយៈ ពេលយូររវាងអ្នកសារព័ត៌មានមកពីស្ថាប័នជាតិ និងអន្តរជាតិ និង និពន្ធនាយក ព្រមទាំងម្ចាស់ស្ថាប័នសារព័ត៌មាននានា ដើម្បីបង្កើតសមាគមសារព័ត៌មានមួយដែលឯករាជ្យពីនយោបាយ។

បើយោងតាមលោកប្រធានក្លឹប ក្លឹបនេះបង្កើតឡើងបន្ទាប់ពីសមាគមសារព័ត៌មានចំនួនពីរ មុនការផ្ទុះអាវុធឆ្នាំ១៩៩៧។ សមាគមទាំងពីនេះគឺសមាគមអ្នកសារព័ត៌មានខ្មែរ Khmer Journalists Association និងសម្ព័ន្ធ អ្នកសារព័ត៌មានកម្ពុជា the League of Cambodian Journalist ដែលពីមុនទទួលឥទ្ធិពលនយោបាយយ៉ាងជោគជាំ។

សមាជិកនៃក្លឹបដែលជាអ្នកកាសែតមកពីប្រភពផ្សេងៗគ្នា ដូចជាកាសែតគាំទ្រ និងប្រឆាំងរដ្ឋាភិបាល កាសែតជាភាសាខ្មែរ និងបរទេស និងទីភ្នាក់ងារសារព័ត៌មានផ្សេងៗ។សមាជិកត្រូវមានបទពិសោធន៏ក្នុងវិស័យព័ត៌មាន យ៉ាងហោច

ណាស់ចំនួនពីរឆ្នាំព្រមទាំងជាបុគ្គលនៅស្ថាប័នព័ត៌មានណាមួយ។

ក្លឹបមានសកម្មភាពបីធំៗដូចជា ការបោះពុម្ពផ្សាយសេចក្តីប្រកាសព័ត៌មានប្រឆាំងនឹងការរំលោភសិទ្ធិសារព័ត៌មាន បង្កើតវគ្គសិក្សាសារព័ត៌មាន ដើម្បីពង្រឹងវិជ្ជាជីវៈ និងបង្កើតអោយមានឡើងនូវការជួបជុំគ្នារវាងអ្នកកាសែតក្នុងស្រុក ដើម្បីបង្កើនអោយមានការសហការគ្នា។

យ៉ាងណាមិញក្លឹបបានទទួលរងនូវការរិះគន់ពីសំណាក់សមាគមសារព័ត៌មានដទៃទៀតថាបាន ប្រមែប្រមូលយកជំនួយផ្នែកសារព័ត៌មានពីអ្នកផ្តល់ជំនួយអន្តរជាតិផ្សេងៗ។

លោកប៉ែន សមិទ្ធិ ដែលជានិពន្ធនាយករបស់កាសែតប្រចាំថ្ងៃក្នុងស្រុកមួយបានក្លាយជាប្រធាននៃក្លឹបនេះ តាំងពីក្លឹបចាប់ដំណើរការនៅឆ្នាំ ២០០០ ម្ល៉េះ។

## មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មាន

ចាប់ផ្តើមឡើងនៅឆ្នាំ២០០៣ មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មានបានបណ្តុះបណ្តាលអ្នកសារព័ត៌មាន លើបច្ចេកទេសក្នុងការយកព័ត៌មាន និងក្រមសីលធម៌។ មជ្ឈមណ្ឌលនេះបានបណ្តុះបណ្តាលអ្នកសារព័ត៌មានដែលនៅតាមបណ្តាខេត្តនានា ហើយមិនមានលទ្ធភាពក្នុងទទួលបាននូវ ធនធានសារព័ត៌មាននៅក្នុងទីក្រុង នេះបើតាមសំដីរបស់លោក មាស គឹមសួន ដែលជាប្រធាននៃមជ្ឈមណ្ឌលនេះ។

ក្រសួងព័ត៌មានចាត់ចែង និងគ្រប់គ្រងមជ្ឈមណ្ឌលនេះ។ បន្ទាប់ពីវិទ្យាស្ថានសារគមនាគមន៍កម្ពុជា Cambodia Communication Institute បានប្តូរទីតាំងមកកាន់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នៅក្នុងឆ្នាំ២០០៣ក្រោមជំនួយពី Korad Adenauer Foundation ក្រសួងព័ត៌មានបានផ្លាស់ប្តូរទីតាំង វិទ្យាស្ថានសារគមនាគមន៍កម្ពុជា អោយទៅជាមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសារព័ត៌មាន។

សិក្ខាសាលាមួយចំនួនដែលផ្តោតលើក្រមសីលធម៌អ្នកសារព័ត៌មាន និង

គោលដៅក្នុងការផ្សព្វផ្សាយ បានប្រព្រឹត្តឡើងក្រោមជំនួយពីអង្គការ UNESCO។ បើតាមលោក គឹមសួន ថាវគ្គសិក្សាបណ្តុះបណ្តាលអោយអ្នកសារព័ត៌មានអាចស្វែងរកវិធីរស់រានដោយខ្លួនឯង ដោយមិនចាំបាច់ពឹង លើការគាំទ្រពីអ្នកនយោបាយ ទោះបីជាយ៉ាងណាមជ្ឈមណ្ឌលនេះដែល គ្រប់គ្រងដោយរដ្ឋាភិបាលព្យាយាមសំរបសំរួលរកនូវជំហរមួយ។

ក្នុងឆ្នាំ២០០៦ មជ្ឈមណ្ឌលនេះ សហការជាមួយ Asia Pacific Institute for Broadcasting Development (AIBD) ក្នុងការបណ្តុះបណ្តាលផលិតករក្នុងកម្មវិធីវិទ្យុ។

## សាកលវិទ្យាល័យភូមិន្ទភ្នំពេញៈ ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍

ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍ គឺជាសាលាលើកដំបូងគេតែមួយគត់ដែល ផ្តល់នូវថ្នាក់សិក្សាបរិញ្ញាប័ត្រផ្នែកសារព័ត៌មាននៅក្នុងប្រទេសកម្ពុជា។ ថ្នាក់សិក្សាចំនួន៤ឆ្នាំនៅសាលានេះមានគោលបំណងបណ្តុះបណ្តាលនិស្សិតអោយមានអាជីពចំរុះទូទៅក្នុងវិស័យសារព័ត៌មាន។

ស្ថិតនៅក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍នេះ បានចាប់ផ្តើមដំណើរការឡើងនៅឆ្នាំ២០០១ បន្ទាប់ពីរដ្ឋាភិបាលកម្ពុជា និងសាកលវិទ្យាល័យទទួលស្គាល់នូវកង្វះខាតសាលាបណ្តុះបណ្តាលផ្នែកសារព័ត៌មានសំរាប់អ្នកសារព័ត៌មានកម្ពុជា នេះបើយោងតាមវិបសាយរបស់សាកលវិទ្យាល័យ។

ចាប់តាំងពីបង្កើតដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍បានបណ្តុះបណ្តាលនិស្សិតចំនួន២០នាក់រៀងរាល់ឆ្នាំ អោយអាចចូលបំរើក្នុងស្ថាប័នសារព័ត៌មានផ្សេងៗ ក៏ដូចជានិស្សិតមួយចំនួនបានបន្តការសិក្សានៅបរទេស នេះបើយោងតាម Caroline Schidt-Gross ដែលជាសហនាយិកានៃដេប៉ាតេម៉ង់នេះ។

យ៉ាងណាមិញ ដេប៉ាតឺម៉ង់នេះមានធនធានកំណត់ក្នុងការជ្រើសរើស

និស្សិតចំនួន៣០រូបតែប៉ុណ្ណោះជារៀងរាល់ឆ្នាំតាមរយៈការប្រលង។ ចំនួន៣០នាក់នេះមិនគ្រប់គ្រាន់ ក្នុងការប្រយុទ្ធប្រឆាំងនឹងបញ្ហាក្រមសីលធម៌នៅក្នុងប្រទេសកម្ពុជាឡើយ។

ទោះបីជាយ៉ាងដេប៉ាតឺម៉ង់ប្រព័ន្ធផ្សព្វផ្សាយ និងសារគមនាគមន៍នេះបានទាក់ទាញចំណាប់អារម្មណ៍ពីអ្នកផ្តល់ជំនួយអន្តរជាតិមួយចំនួនដូចជា Korad Adenauer Foundation, Ateneo de Manila University in the Philippines, និងOhio University in the US។

## ឃែមបូឌាញូស៍

ឃែមបូឌាញូស៍ កើតចេញពីកាសែតប្រចាំសប្តាហ៍ជាពីរភាសា ពោលគឺភាសាអង់គ្លេស និងភាសាខ្មែរ ហើយចាប់ផ្តើមតាំងពីឆ្នាំ២០០៣ ប៉ុន្តែនៅឆ្នាំ២០០៨ កាសែតមួយនេះបានផ្លាស់ប្តូរទៅជាមជ្ឈមណ្ឌលបណ្តុះបណ្តាលសារព័ត៌មានដែលផ្តោតសំខាន់ទៅលើការបណ្តុះបណ្តាលមន្ត្រីសារព័ត៌មាន។

មជ្ឈមណ្ឌលឃែមបូឌាញូស៍ នេះគឺជាមជ្ឈមណ្ឌលដែលស្វែងរកប្រាក់ចំណូល ប៉ុន្តែផ្តល់នូវវគ្គសិក្សាដោយឥតគិតថ្លៃដល់អ្នកសារព័ត៌មាន និងមន្ត្រីព័ត៌មានរបស់រដ្ឋាភិបាល។

ការបណ្តុះបណ្តាលមន្ត្រីសារព័ត៌មាន គឺជាការរួមចំនែកយ៉ាងសំខាន់ដល់ទីផ្សារសារព័ត៌មាននៅកម្ពុជា។ ស្ទើរតែគ្រប់មន្ទីរក្រសួងទាំងអស់របស់រដ្ឋាភិបាលមិនមានមន្ត្រីសាធារណៈផ្នែកព័ត៌មានទេ ដែលជាមូលហេតុមួយបង្កើតការស្មុគស្មាញសំរាប់អ្នកកាសែត ក្នុងការស្វែងរកព័ត៌មានជាទូទៅពីប្រភពរដ្ឋាភិបាល។

ប្រធានមជ្ឈមណ្ឌលនេះ បាននិយាយថាវគ្គសិក្សាមន្ត្រីសារព័ត៌មាន ក៏បានបញ្ចូលផងដែរនូវមេរៀនមូលដ្ឋានគ្រឹះនៃសារព័ត៌មាន។ ហើយលោកក៏បាននិយាយថាបើមន្ត្រីសារព័តមានមិនយល់ពីសារព័ត៌មាននោះទេ ពួកគេនឹងមិនអាចនិយាយជាមួយអ្នកសារព័ត៌មានបានឡើយ។ លោក ឆាយ សុផល ដែលជាអ្នកយកព័ត៌មាន

អោយទីភ្នាក់ងារ Reuters បានចាប់ផ្តើមធ្វើជាប្រធានរបស់យែមបូឌាញស៍តាំងពីឆ្នាំ២០០៣។ លោកសុផល មានគំរោងប្រែក្លាយមជ្ឈមណ្ឌលនេះអោយទៅជាមហាវិទ្យាល័យមួយ ព្រមទាំងផ្តល់នូវការសិក្សាថ្នាក់អនុបណ្ឌិតផងដែរ។

## យោបល់របស់លោក ឆាយ សុផល

សេរីភាពសារព័ត៌មានគឺយើងបែងចែកជាពីរ ទីមួយគឺសេរីភាពផ្នែកបោះពុម្ព ទីពីរសេរីភាពតាមរលកធាតុអាកាស។ ហើយសេរីភាពតាមការបោះពុម្ពមានច្រើនហួសពីការស្មាន តាំងពីមុនរហូតមកដល់ឥឡូវក៏អញ្ចឹងដែរ ក៏ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ក៏ត្រូវបានកំណត់ដោយច្បាប់ ហើយច្បាប់ធ្វើអោយយើងមានការត្បិតត្បៀត ឧទាហរណ៏ច្បាប់ទាក់ទងនឹងព័ត៌មានមិនពិត។

ទីពីរគឺទាក់ទងជាមួយនឹងសន្តិសុខជាតិ យើងកំពុងតែសុំអោយរដ្ឋាភិបាលបញ្ជាក់អោយបានច្បាស់ថា តើរដ្ឋាភិបាលកំណត់ព័ត៌មានបែបណាទៅដែលទាក់ទងនឹងសន្តិសុខជាតិ?

ចំនុចទីបី ប្រព័ន្ធតុលាការមិនឯករាជ្យក៏ធ្វើអោយអ្នកកាសែតមានការលំបាកដែរ។ ជួនកាលពេលអ្នកកាសែតសរសេររឿងរសើបខ្លាំងពេកទៅធ្វើអោយមានការប្តឹងផ្តល់គ្នារវាងអ្នកមានអំណាចនិងអ្នកកាសែត ហើយកាលណាបើមានការប្តឹងផ្តល់គ្នារវាងអ្នកកាសែត និងអ្នកមានអំណាចមិនដែលមានពេលណាអ្នកកាសែតឈ្នះទេ ជាពិសេសទាក់ទងនឹងរឿងធំៗ។

ចំណែកឯរឿងផ្សព្វផ្សាយតាមរលកធាតុអាកាសវិញ សេរីភាពមានខ្លះដែរ បើយើងនិយាយពីវិទ្យុដែលផ្សាយពីខាងក្រៅមក ដែលមានអ្នកគ្រប់គ្រង នៅបរទេសគេឃើញថាមានសេរីភាពគ្រប់គ្រាន់ដែរ ហើយរដ្ឋាភិបាលក៏ផ្តល់ឱកាសអោយវិទ្យុក្នុងស្រុកមួយចំនួនលក់ម៉ោងផ្សាយទៅអោយវិទ្យុទាំងនោះដែរ គឺយើងសង្កេតឃើញថាមានសេរីភាពខ្លះដែរ ប៉ុន្តែវិទ្យុ ឬទូរទស្សន៍ក្នុងស្រុកខ្លួនឯងហ្នឹងមិនហ៊ានផលិតរឿងដោយខ្លួនឯងទេ ព្រោះគាត់ខ្លាចការប្តឹងផ្តល់។

ហើយម្យ៉ាងវិញទៀត ភាគច្រើនម្ចាស់ទូរទស្សន៍មួយចំនួនគាត់ជាអ្នកជំនួញ ភាគច្រើនគាត់បើក ស្ថានីយ៍ទូរទស្សន៍ទាំងនោះសំរាប់តែផ្សព្វផ្សាយនូវផលិតផលរបស់ខ្លួនតែប៉ុណ្ណោះ។អញ្ចឹងផ្នែកព័ត៌មានជារឿងបន្ទាប់បន្សំតែប៉ុណ្ណោះ ដូច្នេះហើយ ព័ត៌មានខ្លះគាត់ដាក់បន្ទុកខ្លួនឯង។

## សមាគមអ្នកថតរូបកម្ពុជា

សមាគមអ្នកថតរូបកម្ពុជា គឺជាសមាគមមួយប្រមូលផ្តុំទាំងអ្នកថតរូបអាជីពនិងមិនអាជីពដើម្បីធ្វើពិធីតាំងពិព័ណ៌រូបថតក្នុងពិធីបុណ្យជាតិផ្សេងៗ។

បន្ទាប់ពីសមាគមនេះ ចាប់ផ្តើមដំណើរការនៅខែសីហា ឆ្នាំ២០០៨ សមាគមនេះបានរៀបចំនូវការតាំងពិព័ណ៌ចំនួនពីរលើកធំៗ នៅថ្ងៃបុណ្យឯករាជ្យជាតិ និងថ្ងៃជ័យជំនះ ៧មករា។

លោកយឹម សំអែល ដែលជាប្រធាននៃសមាគមនេះ គឺជាអ្នកថតរូបរបស់ព្រះមហាក្សត្រ ហើយបានរក្សាទុកនូវឯកសាររូបថតជាច្រើនពាន់សន្លឹក នេះបើតាមលោកខៀវ កូឡា លេខាសមាគម។

សមាគមអ្នកថតរូបមួយនេះក៏មានគំរោងតាំងពិព័ណ៌រូបថតមួយចំនួនដែលទាក់ទងនឹងពិធីបុណ្យ ចូលឆ្នាំប្រពៃណីខ្មែរ។

សមាគមនេះមានគំរោងបង្កើតនូវសិក្ខាសាលា ទាក់ទងនឹងវិជ្ជាជីវៈជាអ្នកថតរូបដើម្បីលើកកំពស់ការយល់ដឹងផ្នែកថតរូបនៅក្នុងប្រទេសកម្ពុជា នេះបើតាមប្រសាសន៍របស់លោកខៀវ កូឡា។ ប៉ុន្តែលោកមិនបានបញ្ជាក់អោយដឹងពីការលើកទឹកចិត្ត និងការបង្កើតអោយអ្នកថតរូបអាជីពស្រាប់មានកំរិតខ្ពស់ជាងមុននោះទេ។

ក្រុមរបស់លោកមានសមាជិក២០រូប រាប់បញ្ចូលទាំងអ្នកថតរូបអាជីព និងមិនមែនអាជីពនេះបើ តាមសំដីរបស់លោកខៀវ កូឡា។

យ៉ាងណាមិញ ក្រៅពីចំនួនសមាជិកតិច និងទំហំនៅមានកំណត់ សមាគម

នេះក៏ជួបប្រទះនូវបញ្ហាកង្វះខាតធនធាន ដូចសមាគមសារព័ត៌មានដទៃទៀតដែរ ព្រមទាំងបញ្ហាមួយទៀត គឺការទាក់ទាញអោយមានប្រជាប្រិយភាពពីសំណាក់អ្នកថតរូបទាំងឡាយ។ លោកខៀវ កូឡា បានបន្ថែមទៀតថា ដើម្បីជំនះអោយបាននូវការខ្វះខាតធនធាន និងការបណ្តុះបណ្តាលអ្នកថតរូប សមាគមមានគំរោងនឹងបើកជាវិទ្យាស្ថានថតរូបមួយនាថ្ងៃអនាគត។

## សមាគមកម្ពុជាការពារអ្នកកាសែត

សមាគមនេះអះអាងថាជាសមាគមដែលមានសមាជិកចំនួន៦០នាក់ ដែលមកពីស្ថាប័នសារព័ត៌មានចំនួន៣០ផ្សេងៗគ្នា ។

សមាគមកម្ពុជាការពារអ្នកកាសែតអះអាងថា ជាសមាគមសារព័ត៌មានមួយដែលសំបូរទៅដោយអ្នកកាសែតដែលធ្វើការអោយស្ថាប័នសារព័ត៌មានបរទេសនៅក្នុងប្រទេសកម្ពុជា។

លោកអ៊ុំ សារិន ដែលជាអ្នកយកព័ត៌មាននៅវិទ្យុអាស៊ីសេរី ដឹកនាំសមាគមនេះជាមួយនឹងប្រធានក្រុមប្រឹក្សាភិបាលចំនួនប្រាំបួនរូបផ្សេងៗទៀត។ សមាគមនេះគឺជាសមាជិកនៃសហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ IFJ និងSoutheast Asian Press Alliance (SEAPA)។

ចាប់តាំងពីការបង្កើតនៅឆ្នាំ២០០០ សមាគមនេះបានរៀបចំអោយមានការជួបជុំគ្នានៅថ្ងៃសេរីភាពសារព័ត៌មាន និងបង្កើតវគ្គសិក្សាស្តីពីការយកព័ត៌មានជំនាញជាច្រើនសំរាប់អ្នកកាសែត។ កាលពីឆ្នាំមុនសមាគមនេះបានធ្វើសិក្ខាសាលាទាក់ទងនឹងការយកព័ត៌មានផ្នែកអេដស៍ និងការថែទាំសុខភាពចំនួន១០លើក។

សមាគមនេះអះអាងថាជាសមាគមដែលទទួលយកអ្នកសារព័ត៌មានដែលគោរពនូវក្រមសីលធម៌ គឺអ្នកសារព័ត៌មានដែលមិនផ្សព្វផ្សាយព័ត៌មានមិនពិត។

## វិទ្យាស្ថានកម្ពុជាសម្រាប់ការសិក្សាផ្នែកសារព័ត៌មាន(CIMS)

គឺជាអង្គការក្នុងស្រុកមួយដែលកើតឡើងបន្ទាប់ពីអង្គការ Internews ដែល

ជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិមួយបានបញ្ចប់គំរោងរបស់ខ្លួននៅកម្ពុជាក្នុងឆ្នាំ ២០០៨។

វិទ្យាស្ថាននេះ មានវគ្គសិក្សាបី ដែលក្នុងវគ្គនីមួយៗមានរយៈពេល៣ សប្តាហ៍ ដែលដឹកនាំដោយ លោក មឿន ឈានណារិទ្ធ ដែលជាអតីតអ្នកយកព័ត៌មាននៅការសែតភ្នំពេញប៉ុស្ដិ៍ Phnom Penh Post។

ក្នុងវគ្គសិក្សាទាំងនេះវិទ្យាស្ថាន ក៏ផ្តោតលើការបណ្តុះបណ្តាលផ្នែកប្រព័ន្ធអ៊ីនធឺណេត ដែលជាការចាប់ផ្តើមមួយដើម្បីបំពាក់បំប៉នអោយ មានការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណេតពីសំណាក់អ្នកសារព័ត៌មាន។ ក្រៅពីនេះសមាគមក៏មានបំណងផ្តោតទៅលើការយកព័ត៌មានទៅលើជំនាញនីមួយៗដូចជាការយកព័ត៌មានលើការថែទាំសុខភាព និងបញ្ហាបរិស្ថាន។

លោកណារិទ្ធបានអះអាងថាអ្នកផ្តល់ជំនួយអន្តរជាតិបានកាត់បន្ថយប្រាក់ជំនួយរបស់ខ្លួនដោយមូលហេតុមកពីបញ្ហាវិបត្តិសេដ្ឋកិច្ចពិភពលោក។ ដោយបញ្ហានេះហើយ ទើបធ្វើអោយអង្គការសារព័ត៌មានជាអង្គការដែលទទួលរងផលប៉ះពាល់មុនគេ។ លោកបានបន្ថែមថាម្ចាស់ជំនួយមួយចំនួនផ្តោតទៅលើការផ្តល់ជំនួយលើផ្នែកថែទាំសុខភាព និងបរិស្ថាន ។

## មូលនិធិអ្នកសារព័ត៌មានឯករាជ្យ

មូលនិធិអ្នកសារព័ត៌មានឯករាជ្យផ្តួចផ្តើមឡើង ដោយក្រុមនិពន្ធនាយកនៃកាសែត New York Times និងអតីតអនុប្រធានទស្សនាវដ្តី Time ក្នុងឆ្នាំ១៩៩១ ។ មូលនិធិអ្នកសារព័ត៌មានឯករាជ្យមានសកម្មភាពជាច្រើនក្នុងការតស៊ូមតិ និងបណ្តុះបណ្តាលដល់អ្នកកាសែតក្នុងតំបន់អាស៊ីអាគ្នេយ៍ និង អឺរ៉ុបខាងកើត។

ចាប់ពីឆ្នាំ២០០១ ដល់ ឆ្នាំ២០០៤ មូលនិធិអ្នកសារព័ត៌មានឯករាជ្យបានជួយឧបត្ថម្ភ១៣សិក្ខាសាលា ដែលមានរយៈពេល៣ខែ ដែលធ្វើឡើងជាភាសាអង់គ្លេសដល់អ្នកកាសែតខ្មែរ ឡាវ ភូមា និងវៀតណាមចំនួន២០០នាក់។ បន្ទាប់មក

ក្នុងឆ្នាំ២០០៤ មូលនិធិអ្នកសារព័ត៌មានឯករាជ្យយកចិត្តទុកដាក់ជាចំបងទៅលើប្រទេសវៀតណាម និង កម្ពុជា។ កន្លងមកមូលនិធិអ្នកសារព័ត៌មានឯករាជ្យបានបើកវគ្គសិក្សាការយកព័ត៌មានជំនាញផ្នែកអេដស៍ បរិស្ថាន និងសាលាក្ដីខ្មែរក្រហម។

មូលនិធិអ្នកសារព័ត៌មានឯករាជ្យមានផលលំបាកយ៉ាងខ្លាំង ក្នុងការបណ្ដុះ-បណ្ដាលអ្នកសារព័ត៌មានអោយអនុវត្តន៍ទៅតាមច្បាប់ និងក្រមសីលធម៌របស់អ្នក-សារព័ត៌មាន ខណៈពេលដែលការលំបាករបស់រដ្ឋាភិបាលដ៏ធំគឺ ការតែងតាំងអ្នកនាំពាក្យ ដែលមានការបណ្ដុះបណ្ដាលត្រឹមត្រូវនៅមន្ទីរក្រសួងនានា នេះបើយោងតាមការលើកឡើងរបស់តំណាងមូលនិធិអ្នកសារព័ត៌មានឯករាជ្យ។

(ចប់)